# សម័យប្រជុំពេញអង្គលើកទី២០

ក្រោមអធិបតីភាពរបស់សហប្រធាន

**ឯកឧត្តម សៃ៊ហ្ស ម៉ូស្សូរ៉ា**
ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព
ស្ថានទូតបារាំង

**ឯកឧត្តម យូយី គូម៉ាម៉ារូ**
ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព
ស្ថានទូតជប៉ុន

សៀមរាប ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣ - សណ្ឋាគារ សុខា អង្គរ សៀមរាប

# លេខាធិការដ្ឋាន

| | | |
|---|---|---|
| ការិយាល័យអង្គការយូណេស្កូ | អាសយដ្ឋាន | អគារលេខ៣៨ មហាវិថី សម្តេចសុធារស<br>ប្រអប់សំបុត្រលេខ២៩<br>ទីក្រុងភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| | លេខទូរស័ព្ទ | +(៨៥៥)(២៣)៧២៥០៧១<br>+(៨៥៥)(២៣)៧២៣០៥៤ |
| | លេខទូរសារ | +(៨៥៥)(២៣)៤២៦១៦៣<br>+(៨៥៥)(២៣)២១៧០២២ |
| | អ៊ីមែល | bh.lim@unesco.org<br>cskacacya@gmail.com |
| លេខាធិការដ្ឋានអចិន្ត្រៃ | ក្រុងប៉ារីស៍ | សាស្ត្រាចារ្យ អាហ្សេឌីន បេសាអ៊ូស<br>លេខាធិការវិទ្យាសាស្ត្រអចិន្ត្រៃ |
| | ក្រុងភ្នំពេញ | លោក លឹម ប៊ុនហុក<br>(អង្គការយូណេស្កូ)<br>លោកជំទាវ ចៅស៊ុន កិរិយា<br>(អាជ្ញាធរអប្សរា) |

# មាតិកា

**១. ពិធីបើកអង្គប្រជុំ** ........ 5

*១.១. សុន្ទរកថាសហប្រធានបារាំង ឯកឧត្តម ស៊ែហ្ស ម៉ូស្ទូរ៉ា ឯកអគ្គរដ្ឋទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា* ........ 5

*១.២. សុន្ទរកថាតំណាងរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម បណ្ឌិត សុខ អាន ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរអប្សរា* ........ 8

*១.៣. សុន្ទរកថាតំណាងអគ្គនាយិកាអង្គការយូណេស្កូ លោក គីស័រ រ៉ាវ នាយកមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក* ........ 14

**២. របាយការណ៍** ........ 17

*២.១. បទបង្ហាញដោយសាស្ត្រាចារ្យ អាហ្សេឌីន បេសាអ៊ីស លេខា វិទ្យាសាស្ត្រ អាយ ស៊ី ស៊ី អង្គរ ស្តីអំពី ផ្លូវក្នុងឧទ្យានអង្គរ* ........ 17

*២.២. បទបង្ហាញដោយលោក ហ្សង់ បាទីស្ត៍ ស៊ីវ៉េង់ស៍ ប្រធានមូលនិធិបុរាណវិទ្យានិងអភិវឌ្ឍន៍ និង លោកស្រី សុវណ្ណា ហ្គោនឡែត្ត ប្រធានអង្គការ* Wildlife Alliance *ស្តីអំពី គ្រោះថ្នាក់ដែលគំរាមកំហែងលើបេតិកភណ្ឌនិងបរិស្ថាននៅភ្នំគូលែន* ........ 21

**៣. គម្រោងថ្មីៗ** ........ 29

*៣.១. បទបង្ហាញដោយសាស្ត្រាចារ្យ គួ ហ័រតុង ស្តីអំពីគម្រោងតាមដានបរិស្ថាននៅក្នុងឧទ្យានអង្គរ ផ្តល់ហិរញ្ញប្បទានដោយមជ្ឈមណ្ឌលអន្តរជាតិបច្ចេកវិទ្យាលំហ សម្រាប់បេតិកភណ្ឌវប្បធម៌ និង ធម្មជាតិ ហៅកាត់ថា* HIST *របស់ប្រទេសចិន គាំទ្រដោយអង្គការយូណេស្កូ* ........ 29

*៣.២. បទបង្ហាញដោយឯកឧត្តម រស់ បូរ៉ាត់ អគ្គនាយករងអាជ្ញាធរអប្សរា ស្តីអំពីគម្រោងជួសជុលប្រាសាទព្រះពិធូរ និងប្រាសាទអង្គរវត្ត* ........ 33

*៣.៣. បទបង្ហាញដោយឯកឧត្តម ហង់ ពៅ អគ្គនាយករងអាជ្ញាធរអប្សរា និងលោក ព្យែរ ក្លេម៉ង់ ប្រធានសមាគមមិត្តភក្តិអង្គរ ស្តីអំពី ការរៀបចំនិងគ្រប់គ្រងប្រព័ន្ធទឹកនៅក្នុងឧទ្យានអង្គរ និង សៀមរាប* ........ 40

**៤. ចក្ខុវិស័យសម្រាប់ទសវត្សថ្មី**......44
*៤.១. បទបង្ហាញអំពីប្រធានបទសម្រាប់អនាគត*......44
*៤.២. បទបង្ហាញអំពីពង្រាងអនុសាសន៍និងសេចក្តីថ្លែងការណ៍របស់សន្និសីទអន្តររដ្ឋាភិបាលលើកទីបីស្តីពីអង្គរ*......44
**៥. ផ្សេងៗ**......46
*៥.១. ព័ត៌មានផ្សេងៗ*......46
**៦. អនុសាសន៍របស់ គណៈកម្មាធិការ អាយ ស៊ី ស៊ី**......54
*៦.១. ការអនុម័តពង្រាងអនុសាសន៍ដែលបានពិនិត្យដោយសម័យប្រជុំបច្ចេកទេសកន្លងទៅ*......63
*៦.២. កាលបរិច្ឆេទសម័យប្រជុំបច្ចេកទេសលើកក្រោយ*......64
**៧. ពិធីបិទអង្គប្រជុំ**......66
*៧.១. សុន្ទរកថាសហប្រធានជប៉ុន ឯកឧត្តម យូយី គូម៉ាម៉ារូ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*......66
**បញ្ជីអ្នកចូលរួម**......69
**របាយការណ៍អាជ្ញាធរអប្សរាឆ្នាំ២០១៣**......88

# សម្រង់មតិពិភាក្សា

## ១. ពិធីបើកអង្គប្រជុំ

សហប្រធានជប៉ុន៖
យើងនឹងចាប់ផ្តើមសម័យប្រជុំពេញអង្គ អាយស៊ីស៊ី របស់យើង។ ខ្ញុំឈ្មោះ គូម៉ាម៉ារូ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ហើយខ្ញុំជាសហប្រធានមួយរូបក្នុងចំណោមសហប្រធានទាំងពីរ។ ក្នុងនាមសហការីរបស់ខ្ញុំ និងជាសហប្រធាន ឯកឧត្តម ស៊ែហ្ស ម៉ូស្នូរ៉ា ឯកអគ្គរដ្ឋទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្វាគមន៍ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់គ្នានៅក្នុងពេលប្រជុំនេះ។ ជាបឋម ខ្ញុំសូមអនុញ្ញាតផ្តល់វេទិកានេះជូនសហការីរបស់ខ្ញុំ គឺឯកឧត្តមសហប្រធាន ឯកអគ្គរដ្ឋទូត ស៊ែហ្ស ម៉ូស្នូរ៉ា។ ឯកឧត្តម សូមអញ្ជើញ។

### ១.១. សុន្ទរកថាសហប្រធានបារាំង ឯកឧត្តម ស៊ែហ្ស ម៉ូស្នូរ៉ា ឯកអគ្គរដ្ឋទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា

សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី។
សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព។

នៅឆ្នាំ១៩៩១ ក្រោយពីបានឆ្លងកាត់សង្គ្រាមអស់រយៈពេល២០ឆ្នាំ ព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះអង្គបានអំពាវនាវដល់អង្គការយូណេស្កូ ឲ្យជួយអភិរក្សឧទ្យានអង្គរ។ នៅក្នុងការចុះឧទ្យានអង្គរជាបន្ទាន់ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់មនុស្សជាតិនៅឆ្នាំ១៩៩២ សហគមន៍អន្តរជាតិត្រូវបានចលនាឲ្យចូលរួម ហើយនៅក្នុងឱកាសនៃការប្រារព្ធសន្និសីទអន្តររដ្ឋាភិបាលលើកទី១ ដែលបានប្រព្រឹត្តទៅនៅឆ្នាំ១៩៩៣នៅទីក្រុងតូក្យូ ក្រោមសហប្រធានបារាំងនិងជប៉ុន សហគមន៍អន្តរជាតិបានកំណត់គោលគំនិតក្របខណ្ឌនិងបែបបទនៃជំនួយអន្តរជាតិដោយបានអនុម័តសេចក្តីថ្លែងការណ៍ក្រុងតូក្យូ។

នៅក្នុងទសវត្សទី១របស់ខ្លួន គណៈកម្មាធិការអន្តរជាតិសម្របសម្រួលដែលត្រូវបានបង្កើតឡើង ដើម្បីជួយជំរុញតាមដាន និងវាយតម្លៃជំនួយអន្តរជាតិបានផ្តល់អាទិភាពដល់វិស័យអភិរក្សរមណីយដ្ឋាន។ ដំណើររួមគ្នាជាមួយ

រាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសដែលបានចូលរួមទាំងអស់ គឺសំដៅទៅកសាងរចនាសម្ព័ន្ធនៃកិច្ចខិតខំប្រឹងប្រែងអភិរក្សឧទ្យានអង្គរតាមវិធីសាស្ត្រមួយ ដែលមានលក្ខណៈអន្តរជំនាញ ដើម្បីដោះស្រាយរាល់បញ្ហានានា រួមមាន វិធានការច្បាប់និងបទដ្ឋានផ្សេងៗ ក្របខណ្ឌស្ថាប័ននៃការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលបុគ្គលិកកម្ពុជាក្នុងគ្រប់កម្រិត។ គោលដៅភាគច្រើនត្រូវបានសម្រេចជោគជ័យ ហើយជាពិសេស យើងនៅចាំបានថា មានការបង្កើតកាលពីឆ្នាំ១៩៩៥ នូវអាជ្ញាធរអប្សរាដែលជាស្ថាប័នសាធារណៈមួយទទួលបន្ទុកការគ្រប់គ្រងឧទ្យានអង្គរ។

សន្និសីទអន្តរជាតិលើកទី២ ដែលបានប្រារព្ធឡើងនៅទីក្រុងប៉ារីស៍នៅឆ្នាំ២០០៣ បានចេញសេចក្តីថ្លែងការណ៍ថ្មីមួយទៀត។ អាយស៊ីស៊ី ត្រូវបានបន្តបេសកកម្មរបស់ខ្លួន ហើយការដ្ឋានរួមគ្នានៅអង្គរត្រូវបានតម្រង់ទៅរកទិសថ្មី ក្រោមប្រធានបទការអភិវឌ្ឍប្រកបដោយចីរភាព និងសមាហរណកម្មកាន់តែប្រសើរឡើងនៃប្រជាជននៅតាមមូលដ្ឋានទៅក្នុងគម្រោងផ្សេងៗតាមរយៈការលើកស្ទួយទេសចរណ៍ប្រកបដោយសមធម៌ និងនិរន្តរភាព។ ជាអាទិ៍ វិធីសាស្ត្រនោះ បាននាំទៅដល់ការបង្កើតគណៈកម្មាធិការបច្ចេកទេសពិសេសមួយទទួលបន្ទុកការអភិវឌ្ឍប្រកបដោយចីរភាព ដែលបានធ្វើឲ្យសមត្ថភាពរបស់អាជ្ញាធរអប្សរាកាន់តែទូលំទូលាយឡើង។

នៅក្នុងពេលជាមួយគ្នានោះ វិស័យបុរាណវិទ្យាបានជួបប្រទះនឹងជោគជ័យល្អៗជាច្រើន។ ក្នុងនាមខ្ញុំជាតំណាងប្រទេសបារាំង ខ្ញុំអាចលើកជាឧទាហរណ៍នូវការងាររបស់សាលាបារាំងចុងបូព៌ាប្រទេស ជាអាទិ៍ មានការជួសជុលប្រាសាទបាពួនដែលត្រូវបានបញ្ចប់ទៅនៅឆ្នាំ២០១១ និងការជួសជុលដែលកំពុងតែប្រព្រឹត្តទៅនៅពេលសព្វថ្ងៃនេះ នៅប្រាសាទមេបុណ្យខាងលិច ឬក៏ការដ្ឋានកំណាយបុរាណវិទ្យាបង្ការរបស់ស្ថាប័ន Inrap។

ដូច្នេះ វាជាទសវត្សមួយដែលយើងបានធ្វើរួមគ្នាឲ្យការងារទាំងអស់កាន់តែស៊ីជម្រៅ ព្រមទាំងបានលើកតម្លៃរមណីយដ្ឋានដែលបានបញ្ចប់ទៅនៅឆ្នាំនេះ ហើយ អាយស៊ីស៊ី អាចមានមោទនភាពចំពោះការងារដែលខ្លួនបានបំពេញកន្លងរួចមកហើយនេះ។ រមណីយដ្ឋានអង្គរ បច្ចុប្បន្ននេះមិនមែនជារមណីយដ្ឋានស្ថិតក្នុងសភាពគ្រោះថ្នាក់ទៀតទេ ហើយ អាយស៊ីស៊ី ខ្លួនឯងផ្ទាល់ ហាក់ដូចជាបានក្លាយជាគំរូមួយ សម្រាប់កិច្ចការសហប្រតិបត្តិការអន្តរជាតិ។ កិត្តិយសនេះស័ក្តិសមជារបស់បណ្តាប្រទេសដែលបានចូលរួម ហើយជាដំបូងបង្អស់នោះ គឺព្រះរាជាណាចក្រកម្ពុជានេះឯង។

គឺការប្តេជ្ញាចូលរួមរបស់បណ្តាប្រទេស អ្នកប្រាជ្ញនានានិងអ្នករដ្ឋបាលរបស់បណ្តាប្រទេសជាសមាជិកទាំងនេះឯង

ព្រមទាំងការប្តេជ្ញារបស់ពួកគេដែលមានទាំងការចូលរួមជាប់ជាប្រចាំយ៉ាងម៉ឺងម៉ាត់ក៏ដូចជាចំនួននិងភាពសម្បូរបែបនៃជំនាញទាំងអស់រួមគ្នានោះហើយ ដែលបានអនុញ្ញាតឲ្យយើងទទួលបានជោគជ័យបែបនេះ។

នៅពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញមានប្រទេសចំនួន១៤ ដែលបានចូលរួមតាមរយៈគម្រោងចំនួន៣៧ គឺគម្រោងដែលកំពុងតែអនុវត្តនៅក្នុងឧទ្យានអង្គរ។ ចំណុចនេះមានន័យថា បន្ទាប់ពីបានធ្វើការអស់រយៈពេលជាង ២០ឆ្នាំកន្លងមក ការអំពាវនាវដែលធ្វើឡើងដោយព្រះមហាក្សត្រ សីហនុ នៅតែបន្ត និងត្រូវបានសហគមន៍អន្តរជាតិយកចិត្តទុកដាក់ឆ្លើយតបនៅឡើយ។

ជាមួយនឹងទសវត្សថ្មីមួយខាងមុខ យើងនឹងប្រឈមនឹងបញ្ហាប្រឈមថ្មីៗ ដែលកំពុងរង់ចាំ អាយស៊ីស៊ី បញ្ហាប្រឈមទាំងនោះ គឺយើងត្រូវដើរតាមការវិវត្តនៃការចូលមកទស្សនារបស់ភ្ញៀវនៅក្នុងរមណីយដ្ឋានមួយដែលទទួលភ្ញៀវទេសចរប្រមាណជា៤លាននាក់ក្នុងមួយឆ្នាំ។ វាជាការដែលត្រូវបន្តចាត់ទុករមណីយដ្ឋាននេះនៅក្នុងតក្កវិទ្យាមួយនៃការអភិវឌ្ឍប្រកបដោយចីរភាព ទាញយកប្រយោជន៍ពីប្រធានបទស្រាវជ្រាវថ្មីៗ ដែលអាចធ្វើទៅបានដោយបច្ចេកវិទ្យាថ្មីៗ និងចុងក្រោយ ទាញយកប្រយោជន៍ឲ្យបានល្អបំផុតពីស្វ័យភាពកាន់តែខ្ពស់ឡើងរបស់អ្នកបច្ចេកទេសនិងអ្នកជំនាញជនជាតិខ្មែររបស់អាជ្ញាធរអប្សរាដែលលក្ខណៈវិជ្ជាជីវៈត្រូវបានពង្រឹងយ៉ាងខ្លាំង។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី

ពីរទសវត្សដែលទើបតែកន្លងផុតទៅនេះត្រូវបានកត់សម្គាល់ដោយជោគជ័យរបស់គណៈកម្មាធិការអន្តរជាតិសម្របសម្រួលដើម្បីអង្គរ។ ក្នុងនាមសហប្រធានខ្ញុំសូមសម្តែងនូវការកោតសរសើរនិងថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិករបស់គណៈកម្មាធិការនេះ ហើយដែលការតស៊ូប្តូរផ្តាច់និងជំនាញផ្សេងៗបានអនុញ្ញាតពីមួយថ្ងៃទៅមួយថ្ងៃឲ្យមានការជួសជុលអង្គរឡើងវិញ ព្រមទាំងលើកតម្លៃរមណីយដ្ឋាននេះរហូតដល់កម្រិតមួយដែលធ្វើឲ្យវាក្លាយទៅជារមណីយដ្ឋានមួយដែលមាននិមិត្តរូបខ្ពស់ ជាគំរូមួយនាពេលបច្ចុប្បន្ននេះ បើនិយាយអំពីការគ្រប់គ្រងបេតិកភណ្ឌពិភពលោករបស់មនុស្សជាតិ។ តួនាទីដ៏សំខាន់បំផុតរបស់អាជ្ញាធរ នៃរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរអប្សរា ពិតជាចូលប្រលូកយ៉ាងពេញទំហឹងនៅក្នុងបេសកកម្មរបស់ខ្លួនហើយដែលស័ក្តិសមនឹងគួសបញ្ជាក់ព្រមទាំងកោតសរសើរជាពិសេស។

ចំណែកឯថ្ងៃអនាគត ដោយសារថា នៅថ្ងៃស្អែកយើងនឹងប្រារព្ធសន្និសីទអន្តររដ្ឋាភិបាលលើកទី៣ ដូច្នេះយើង

នឹងចាប់ផ្តើមទសវត្សថ្មីមួយទៀត ខ្ញុំជឿថាតាមរយៈភ្លើងបំភ្លឺផ្លូវដែលបានដើរកន្លងរួចទៅហើយ គណៈកម្មាធិការនេះមានហេតុផលគ្រប់គ្រាន់ក្នុងការបង្ហាញសុទិដ្ឋិនិយមរបស់ខ្លួន និងមានជំនឿទុកចិត្តទៅលើសមត្ថភាពរបស់សមាជិកទាំងអស់គ្នាក៏ដូចជាសមត្ថភាពរបស់កម្ពុជាក្នុងការដោះស្រាយឲ្យបានប្រសើរបំផុតនូវបញ្ហាប្រឈមនានាដែលកំពុងរង់ចាំ។ សូមអរគុណ។

សហប្រធានបារាំង៖ នៅពេលនេះ ខ្ញុំសូមផ្តល់វេទិកាជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ប្រធានអាជ្ញាធរអប្សរា។ សូមអញ្ជើញឯកឧត្តម។

## ១.២. សុន្ទរកថាតំណាងរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម បណ្ឌិត សុខ អាន ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរអប្សរា

សូមគោរពឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត ភារធារី ជាទីគោរព។
សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រីជាសាស្ត្រាចារ្យ ប្រធានបេសកកម្មបេតិកភណ្ឌជាទីគោរព។
សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រី និងសហការីទាំងអស់ជាទីគោរព។

សម័យប្រជុំពេញអង្គ អាយស៊ីស៊ី នៅពេលនេះគឺជាការបញ្ចប់ប្រកបដោយសេចក្តីរីករាយនូវអភិក្រមពីរក្នុងពេលតែមួយ។ ម្យ៉ាងគឺជាអភិក្រមនៃការប្រព្រឹត្តទៅនូវទសវត្សទី១ ដែលបានប្រព្រឹត្តិទៅដោយគោរពតាមអនុសាសន៍របស់សន្និសីទស្ថាបនិកនៅទីក្រុងតូក្យូដែលបានប្រារព្ធឡើងនៅថ្ងៃទី១២ និងថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៣។ ពិតណាស់ថា នៅសម័យនោះ ពេលខ្លះមានការលំបាក ប៉ុន្តែដំណើរស្រុះស្រួលគ្នានៃសមាជិករបស់ អាយស៊ីស៊ី និងចេតនាតែមួយរួមគ្នាចង់ធ្វើឲ្យឧទ្យានអង្គរចេញផុតពីសភាពគ្រោះថ្នាក់នាំឲ្យយើងទទួលបាននូវការរីកចម្រើន និងជោគជ័យដ៏ធំធេង។

អភិក្រមមួយទៀតនោះ មានសារៈសំខាន់ខ្លាំងដែរ គឺជាអភិក្រមនៃការប្រព្រឹត្តទៅនៅក្នុងទសវត្សទី២ ដែលសំដៅទៅគោរពតាមនៅក្នុងលក្ខខណ្ឌដ៏ល្អបំផុតនូវអនុសាសន៍នានារបស់សន្និសីទទីក្រុងប៉ារីស៍ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៤ និងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៣។ ដូច្នេះគឺយើងមានមោទនភាពដោយស្របច្បាប់និងមានតុល្យាការវិជ្ជមានយ៉ាងធំធេង ដែលថ្ងៃនេះ យើងប្រារព្ធខួបគម្រប់២០ឆ្នាំនៃការងាររួមគ្នារបស់សហគមន៍អន្តរជាតិដែលមានវត្តមាននៅទីនេះជាប់រហូតមក ហើយដែលសម្រេចបាននូវសមិទ្ធផលធំធេងនានានៅក្នុងមជ្ឈដ្ឋានបេតិកភណ្ឌជុំវិញពិភពលោក ក្រោមការគាំទ្ររបស់ អាយស៊ីស៊ី អង្គរ ស្ថិតក្រោមសហប្រធានដ៏ថ្លៃថ្លារបស់បារាំងនិងជប៉ុននិង

ជាមួយដៃគូអាជ្ញាធរអប្សរាប្រកបដោយផ្លែផ្កា។

ដូច្នេះខ្ញុំសូមសំដែងការកោតសរសើរដល់សហប្រធានទាំងពីរ គឺឯកឧត្តម ឯកអគ្គរដ្ឋទូតបារាំង ស៊ែហ្ស ម៉ូស្ទូរ៉ា និងឯកឧត្តមឯកអគ្គរាជទូតជប៉ុន យូយី គូម៉ាម៉ារ៉ូ។ ក្នុងនាមរាជរដ្ឋាភិបាលនិងក្នុងនាមអាជ្ញាធរអប្សរាដែលខ្ញុំមានកិត្តិយសធ្វើជាប្រធាននេះ ខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ថ្លៃថ្លា និងខ្លាំងក្លាបំផុតដល់បារាំងនិងជប៉ុន និងសូមសម្តែងនូវការកោតសរសើរយ៉ាងកក់ក្តៅដ៏ស័ក្តិសមបំផុត។

ឯកឧត្តមសហប្រធានទាំងពីរ ក្នុងរយៈពេល២០ឆ្នាំកន្លងទៅនេះ ឯកឧត្តមឯកអគ្គរដ្ឋទូតមុនៗទាំងអស់គ្នាបានទទួលភារកិច្ចនិងបន្ទុកធ្វើជាសហប្រធានប្រកបដោយភាពថ្លៃថ្នូរគួរឲ្យកោតសរសើរនិងប្រកបដោយថាមភាពដ៏ល្អ។ ពួកគេបានធ្វើជាសហប្រធានប្រកបដោយសុខដុមនីយកម្មយ៉ាងពេញទំហឹងរវាងពួកគេ ក៏ដូចជាជាមួយសហការីឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត និងជាមួយប្រធានបេសកកម្មវិទ្យាសាស្ត្រផ្សេងៗទៀតនៅអង្គរដែរ។ ការនោះគឺជារឿងមួយដ៏កម្រនិងស័ក្តិសមនឹងគូសបញ្ជាក់នាពេលនេះ។ វាបានផ្តល់នូវតម្លៃមួយបន្ថែមទៀតដល់ការឃោសនាអន្តរជាតិសម្រាប់ការអភិរក្សនិងអភិវឌ្ឍឧទ្យានអង្គរប្រកបដោយចីរភាព។

យើងសុទ្ធតែយល់គ្រប់គ្នាថា យើងសុទ្ធតែមិនចង់ឈប់ធ្វើដំណើរទៅមុខនៅតាមផ្លូវមួយដ៏ល្អបែបនេះទេ ហើយសង្ឃឹមចង់ឲ្យប្រទេសបារាំងនិងប្រទេសជប៉ុនបន្តទទួលបន្ទុកសហប្រធាន អាយស៊ីស៊ី តទៅទៀត។ ប្រទេសរបស់ឯកឧត្តមបានឆ្លើយតបជាវិជ្ជមានដល់សំណើរបស់យើងហើយគ្រប់គ្នាសុទ្ធតែពេញចិត្ត។ ដូច្នេះអនាគតរបស់ អាយស៊ីស៊ី នៅក្នុងទសវត្សក្រោយនេះ ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២៤ នឹងស្ថិតនៅក្នុងដៃដែលល្អ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ព្រមទាំងកោតសរសើរដល់លេខាធិការដ្ឋានអចិន្ត្រៃយ៍ អាយស៊ីស៊ី ជារួម។ លេខាធិការដ្ឋាន គឺជាផ្ទាំងនៃស្មារតីចងចាំរបស់យើង ហើយលេខាធិការដ្ឋានតែងតែប្រុងប្រយ័ត្ន មិនធ្វេសប្រហែស ធ្វើយ៉ាងណារៀបចំការងារប្រជុំរបស់យើងឲ្យបានល្អ។ ខ្ញុំសូមនិយាយសំដៅជាពិសេសដល់លេខាធិការវិទ្យាសាស្ត្ររបស់យើង គឺលោកសាស្ត្រាចារ្យ អាហ្សេឌីន បេសាអ៊ូស ដែលអស់រយៈពេល២០ឆ្នាំមកនេះ តែងតែបន្តដំណើរជាមួយ អាយស៊ីស៊ី យ៉ាងទៀងទាត់ អស់ពីចិត្តពីថ្លើម និងប្រកបដោយប្រសិទ្ធភាព។ សូមជូនពរលោកនូវបវរមហាប្រសើរ។

ឯកឧត្តម លោកជំទាវ សហការីទាំងអស់ជាទីរាប់អាន!

២០ឆ្នាំបន្ទាប់ពីបានចុះឧទ្យានអង្គរចូលក្នុងបញ្ជីបេតិកភណ្ឌរបស់មនុស្សជាតិ ដោយអង្គការ យូណេស្កូ ប្រាង្គប្រាសាទ ប្រវត្តិសាស្ត្រ និងវប្បធម៌ ព្រមទាំងរមណីយដ្ឋានបុរាណវិទ្យា និងអេកូប្រវត្តិសាស្ត្រ នេះមិនត្រឹមតែជានិមិត្តរូបជាតិរបស់ព្រះរាជាណាចក្រកម្ពុជានិងសម្រាប់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជានិមិត្តសញ្ញាដ៏ល្បីល្បាញនៃបេតិកភណ្ឌរបស់ពិភពលោកទាំងមូលទៀតផង។ យើងទាំងអស់គ្នាដែលជាសមាជិករបស់អាយស៊ីស៊ី យើងពិតជាស្គាល់ច្បាប់នូវតុល្យាការវិជ្ជមាននៃកិច្ចការអន្តរជាតិដែលជាប្រយោជន៍ដល់ការអភិរក្សនិងការលើកតម្លៃអង្គរ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងត្រូវតែបន្តធ្វើ ដើម្បីបញ្ចូលទៅក្នុងវប្បធម៌ទូទៅរបស់សាធារណជន ឬអាចនិយាយបានថារបស់ភ្ញៀវមកពីគ្រប់ទិសទី នូវចំណេះដឹងទាំងឡាយស្តីអំពីលទ្ធផលដ៏ធំធេងដែល ម្យ៉ាងសម្រេចបានដោយបេសកកម្មស្រាវជ្រាវបុរាណវិទ្យាទាំងឡាយនិងម្យ៉ាងទៀតដោយការងារពង្រឹងនិងជួសជុលធំៗ។

តាមពិត បើយើងគ្រាន់តែក្រឡេកមើលរូបថតដែលគេបានថតកាលពី២០ឆ្នាំមុននោះ យើងប្រាកដជាឃើញយ៉ាងច្បាស់នូវវិសាលភាពនៃការផ្លាស់ប្តូរបាត់ទៅហើយ។ ទេសភាពអង្គរពិតជាបានផ្លាស់ប្តូរ។ ព្រៃឈើប្រកបដោយគ្រោះថ្នាក់ បានក្លាយទៅជាព្រៃដែលមានសុវត្ថិភាពដែលគេអាចដើរកំសាន្តប្រកបដោយអារម្មណ៍ស្រស់ថ្លា។ ជាបឋម គឺមានប្រាង្គប្រាសាទធំៗ ដែលងាយចូលទស្សនាជាងមុន បន្ទាប់មកភាពស្អាតបាត អនាម័យរមណីយដ្ឋានមិនត្រឹមតែជាកំហិតមួយដែលត្រូវមានប៉ុណ្ណោះទេ ប៉ុន្តែចាប់ពីពេលនេះតទៅគឺជាការពិតមួយដែលគេអាចសង្កេតឃើញជាក់ស្តែង។

ដូច្នេះយើងចាំបាច់ត្រូវធ្វើការខិតខំប្រឹងប្រែងផ្តល់ជាព័ត៌មាន ហើយទន្ទឹមនឹងនោះ ត្រូវធ្វើការផ្សព្វផ្សាយវប្បធម៌ថែមទៀតផង។ ខ្ញុំបាននិយាយថា ការងារទាំងនេះត្រូវផ្តោតទៅលើអ្នកទស្សនាមកពីគ្រប់ទិសទីផ្សេងៗ មានន័យថា ដំបូងគឺត្រូវផ្តោតទៅលើសាលារៀន បន្ទាប់មក មជ្ឈដ្ឋានសាកលវិទ្យាល័យ មហាវិទ្យាល័យ ប៉ុន្តែវាក៏ចាំបាច់ដែរដែលត្រូវផ្តោតទៅលើភ្ញៀវទេសចរ និងក្រៅពីអ្នកបច្ចេកទេសខាងផ្នែកទីផ្សារ ធ្វើឲ្យពួកគេយល់ដឹងពីទិន្នន័យថ្មីៗស្តីអំពីដែនដីដ៏ធំល្វឹងល្វើយនៃឧទ្យានអង្គរ ពោលគឺព័ត៌មានស្តីអំពីកាលប្បវត្តិដ៏វែងឆ្ងាយ ស្តីអំពីភាពសម្បូរបែបនៃវប្បធម៌និងសិល្បៈដែលជារបស់កេរ្តិ៍ដំណែលបុរាណវិទ្យា។

នោះហើយគឺជាការដ្ឋានដ៏ធំដែលផលប៉ះពាល់ទៅលើសេដ្ឋកិច្ចកម្ពុជាមិនមែនតូចតាចនោះទេ ហើយដែលនឹងអនុញ្ញាតឲ្យយុវជនធ្វើការបណ្តុះបណ្តាលខ្លួនឯងនៅក្នុងបច្ចេកទេសនៃការលើកស្ទួយសោតទស្សន៍ និងការផ្សព្វផ្សាយវប្បធម៌។ នៅក្នុងន័យនេះ ខ្ញុំសូមអំពាវនាវដល់ អាយស៊ីស៊ី របស់យើង ដល់បណ្តាប្រទេស និងស្ថាប័នដែលជាសមាជិករបស់ អាយស៊ីស៊ី។ ខ្ញុំសូមអញ្ជើញអ្នកជំនាញទាំងអស់ឲ្យចាប់អារម្មណ៍ទៅលើវិស័យនេះនិង

សូមជួយធ្វើឲ្យយុវជនរបស់យើងបានរៀនសូត្រ ក្រេបជញ្ជក់ជំនាញរបស់ពួកគេ។ កិច្ចសហប្រតិបត្តិការប្រភេទនេះអាចនឹងធ្វើឲ្យតួនាទីនិងជំនាញរបស់ អាយស៊ីស៊ីអង្គរ កាន់តែសម្បូរបែបឡើងនៅក្នុងទសវត្សថ្មីខាងមុខនេះ។

ឯកឧត្តមសហប្រធាន ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរព

ជាថ្មីម្តងទៀតខ្ញុំសូមផ្តោតការយកចិត្តទុកដាក់ជាពិសេសដល់អាទិភាពដែលរាជរដ្ឋាភិបាលបានកំណត់ជូនអាជ្ញាធរអប្សរា។

ជាបឋមគឺការងារជាពាសាស្ត្រ។ បទបង្ហាញដែលធ្វើឡើងនៅក្នុងសម័យប្រជុំបច្ចេកទេសលើកទី២២ បានបង្ហាញរួចមកហើយ៖ វាជារឿងដែលចាំបាច់ដែលមិនអាចអាក់ខានបាន ដោយត្រូវបន្តការប្រយុទ្ធប្រឆាំងនឹងហានិភ័យនៃគ្រោះទឹកជំនន់នៅក្នុងប្រាសាទ ក្នុងតំបន់អាកាសយានដ្ឋាន និងនៅក្នុងទីរួមខេត្តសៀមរាប។ រហូតមកទល់ពេលនេះ ដោយសារហិរញ្ញប្បទានពិសេសដែលផ្តល់ជូនដោយ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី អាជ្ញាធរអប្សរាបានបញ្ចៀសគ្រោះថ្នាក់នៃទឹកជំនន់បានដោយជោគជ័យ ក្រោមការដឹកនាំរបស់បណ្ឌិត ហង់ ពៅ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងត្រូវតែបន្តធ្វើទៀត។ ប្រព័ន្ធជាពាសាស្ត្រខ្វាត់ខ្វែងក្នុងសម័យអាណាចក្រខ្មែរត្រូវតែរក្សាសុវត្ថិភាពឲ្យបានដាច់ខាត រួមមានអូរ ស្ទឹង បារាយណ៍និងកសិណទឹកជាដើម។ ការសិក្សាអំពីវិស្វកម្មជាពាសាស្ត្រនិងការងារពង្រឹងប្រព័ន្ធជាពាសាស្ត្រនេះតម្រូវឲ្យមានហិរញ្ញប្បទានមួយដ៏ច្រើនសន្ធឹកសន្ធាប់ និងត្រូវធ្វើការងារថែទាំជាប់ជាប្រចាំ។ បំពេញបន្ថែមលើធនធានផ្ទាល់របស់យើង យើងខ្ញុំសូមអំពាវនាវដល់កិច្ចសហប្រតិបត្តិការអន្តរជាតិផ្សេងទៀត។ វាគឺជាកម្មវិធីមួយដែលមានលក្ខណៈស្លាប់រស់។ នៅក្នុងន័យនេះ ខ្ញុំមិនអាចថាមិនលើកឡើងបានទេ អំពីពិធីចុះហត្ថលេខានាពេលថ្មីៗនេះរវាងអាជ្ញាធរអប្សរា និងសមាគមមិត្តភ័ក្តិអង្គរ ព្រមទាំងសមាគមដៃគូពីរផ្សេងទៀតក្នុងគម្រោងសហប្រតិបត្តិការថ្មីមួយដែលពាក់ព័ន្ធនឹងរឿងទឹកផ្សារភ្ជាប់ទៅនឹងបេតិកភណ្ឌ។ ខ្ញុំគិតថា វា ជាជំហានមួយទៅមុខដ៏សំខាន់សម្រាប់អាជ្ញាធរអប្សរានៅក្នុងការងារជាពាសាស្ត្ររបស់ខ្លួនពាក់ព័ន្ធនឹងបេតិកភណ្ឌ។

ចំនុចទី២ដែលជាប្រយោជន៍បេតិកភណ្ឌដែរនោះ ពាក់ព័ន្ធនឹងទេសចរណ៍វប្បធម៌។ ដូចឯកឧត្តម លោកជំទាវជ្រាបស្រាប់ហើយ យើងបានអនុម័តផែនការគ្រប់គ្រងទេសចរណ៍ ដែលហៅកាត់ជាភាសាអង់គ្លេសថា TMP សម្រាប់ឧទ្យានអង្គរ និងតំបន់អង្គរ។ ផែនការនេះគឺជាផ្នែកមួយក្នុងគម្រោងក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌដែលហៅកាត់ថា HMF ហើយដែលត្រូវបានរៀបចំឡើងដោយក្រុមហ៊ុនពិគ្រោះយោបល់អូស្ត្រាលីមួយ ដែលហៅកាត់ថា GML ដោយសហការជាមួយអង្គការយូណេស្កូ និងអាជ្ញាធរអប្សរា និងមានជំនួយហិរញ្ញវត្ថុរបស់រដ្ឋាភិបាល

អូស្ត្រាលីនិងរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្រសួងទេសចរណ៍ អ្នកជំនាញរបស់អាជ្ញាធរអប្សរា និងវិស័យឯកជននៅសៀមរាបអង្គរ បានសហការគ្នាយ៉ាងជិតស្និទ្ធនៅក្នុងការងារត្រៀមរៀបចំផែនការនេះ។ ខ្ញុំមានសេចក្តីសោមនស្ស សូមប្រកាសជូនឯកឧត្តម លោកជំទាវថានៅក្នុងអាជ្ញាធរអប្សរាខ្ញុំបានបង្កើតក្រុមអ្នកជំនាញវ័យក្មេងមួយក្រុមដែលខ្ញុំឲ្យទទួលបន្ទុកអនុវត្តផែនការនេះចាប់ពីខែមករា ឆ្នាំ២០១៤ទៅ។ ខ្ញុំសូមបន្ថែមថា ផែនការគ្រប់គ្រងទេសចរណ៍នេះធ្វើឲ្យអង្គការទេសចរណ៍ពិភពលោកចាប់អារម្មណ៍ ពោលគឺអង្គការទេសចរណ៍ពិភពលោករបស់អង្គការសហប្រជាជាតិ។ អគ្គលេខាធិការរបស់អង្គការនេះ គឺឯកឧត្តម តាឡិប រីហ្វៃ (Taleb Rifai) បានធ្វើជាប្រធានជាមួយយើងខ្ញុំនៅថ្ងៃទី១ ខែធ្នូ កន្លងទៅនេះ នៅសៀមរាប ក្នុងពិធីបើកកិច្ចប្រជុំថ្នាក់តំបន់មួយស្តីអំពីទេសចរណ៍។ លោកបានប្តេជ្ញាយ៉ាងម៉ឺងម៉ាត់ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរបស់អង្គការទេសចរណ៍ពិភពលោក ជាមួយក្រសួងទេសចរណ៍សម្រាប់អង្គរ និងសម្រាប់កម្ពុជាទាំងមូល។ ជាធម្មតាទេ អាជ្ញាធរអប្សរាពិតជារីករាយនឹងចូលរួមនៅក្នុងភាពជាដៃគូនេះ។ ខ្ញុំលើកអំពីចំណុចនេះឡើង ពីព្រោះយើងមានផែនការគ្រប់គ្រងទេសចរណ៍និងគម្រោង HMF នៅក្នុងដៃរួចហើយ ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះគឺការអនុវត្តផែនការទាំងនេះជាក់ស្តែង។ យើងបានពិភាក្សាយ៉ាងលំអិតជាមួយថ្នាក់ដឹកនាំរបស់អង្គការទេសចរណ៍ពិភពលោកសំដៅទៅបង្កើតកិច្ចសហប្រតិបត្តិការមួយយ៉ាងជិតស្និទ្ធពាក់ព័ន្ធនឹងការអនុវត្តក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌនិងផែនការគ្រប់គ្រងទេសចរណ៍នេះ។

អាទិភាពទី៣ គឺពាក់ព័ន្ធនឹងគម្រោង HMF មានន័យថា ក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌដែលខ្ញុំទើបបានលើកឡើងអម្បាញ់មិញនេះ។ ពាក់ព័ន្ធនឹងគម្រោងនេះ ខ្ញុំសូមរំលឹកថាវាជាគម្រោងនៃកិច្ចសហប្រតិបត្តិការជាមួយអង្គការយូណេស្កូនិងប្រទេសអូស្ត្រាលី។ កាលពីម្សិលមិញ គឺនៅថ្ងៃទី០២ ខែធ្នូ យើងខ្ញុំបានអនុម័តជាផ្លូវការនូវឯកសារនានាពាក់ព័ន្ធនឹងគម្រោងដ៏ល្អនេះ។ អាជ្ញាធរអប្សរានៅឆ្នាំក្រោយនេះ នឹងខិតខំបញ្ចប់ក្របខណ្ឌគ្រប់គ្រងនេះតាមរយៈការអនុវត្ត និងប្រតិបត្តិការជាក់ស្តែង។ នៅក្នុងគម្រោងនេះទៀត យើងនឹងស្វែងរកដៃគូអន្តរជាតិនិងហិរញ្ញប្បទានផ្សេងទៀត ដើម្បីអនុវត្តអ្វីដែលនឹងក្លាយជាផែនការគ្រប់គ្រងអង្គរនិងតំបន់សៀមរាបដ៏ពិតប្រាកដ។

ចំណុចដែលជាប្រយោជន៍ទី៤ គឺស្តីអំពីការគ្រប់គ្រងបរិស្ថានដ៏សំខាន់មួយ ពោលគឺចំណុចដែលពាក់ព័ន្ធនឹងបញ្ហាអភិរក្សព្រៃឈើនៅតំបន់ភ្នំគូលែន លក្ខខណ្ឌនៃការការពារ និងការលើកតម្លៃបេតិកភណ្ឌវប្បធម៌។ ខ្ញុំបានអញ្ជើញឯកឧត្តម រដ្ឋមន្ត្រីបរិស្ថានថ្មី ដើម្បីឲ្យយើងបានស្វែងយល់អំពីគំនិតរបស់ក្រសួងស្តីអំពីការការពារនិងការងារដែលឯកឧត្តមបម្រុងនឹងធ្វើពាក់ព័ន្ធទៅនឹងភ្នំគូលែន។ ការងារបន្ទាន់មួយចាំ គឺបាច់ត្រូវធ្វើ ដើម្បីប្រយុទ្ធប្រឆាំងនឹងការ

កាប់ព្រៃឈើ ព្រមទាំងទប់ទល់នឹងការប៉ះពាល់ដល់បេតិកភណ្ឌនៅទីនោះ។

ជាថ្មីម្តងទៀត ខ្ញុំសូមនិយាយសំដៅទៅអាជ្ញាធរមូលដ្ឋាន ជាពិសេសអភិបាលខេត្តសៀមរាប ឯកឧត្តម ឃឹម ប៊ុនសុង ដែលគួរតែមានវត្តមាន នៅទីនេះ ប៉ុន្តែឯកឧត្តមប្រហែលជាយឺត ពីព្រោះឯកឧត្តមត្រូវត្រឡប់មកពីភ្នំពេញវិញនៅព្រឹកនេះ បន្ទាប់ពីត្រូវចូលរួមប្រជុំនៅក្រសួងមហាផ្ទៃដែលឯកឧត្តមត្រូវមានវត្តមានជាចាំបាច់ ឯកឧត្តមខំត្រឡប់មកវិញឲ្យទាន់ពេល ប៉ុន្តែមើលទៅ ទោះជាយ៉ាងណាក៏ឯកឧត្តមនៅតែយឺត។ ខ្ញុំចង់សុំឲ្យឯកឧត្តមចាត់វិធានការការពារដែលចាំបាច់ត្រូវតែចាត់ឡើងដោយសហការជាមួយក្រសួងបរិស្ថាន និងអាជ្ញាធរអប្សរា បើតាមព័ត៌មានដែលខ្ញុំទទួលបាន អាជ្ញាធរអប្សរាបានចាត់វិធានការខ្លះៗរួចហើយ។ ខ្ញុំគិតថា អភិបាលខេត្តអាចបញ្ចេញយោបល់ខ្លះអំពីវិធានការដំបូងមួយចំនួនដែលបានចាត់ឡើងពាក់ព័ន្ធនឹងភ្នំគូលែន។

ឯកឧត្តមសហប្រធាន ឯកឧត្តម លោកជំទាវ លោក លោកស្រី

មុននឹងធ្វើសេចក្តីសន្និដ្ឋាន ខ្ញុំសូមសំដែង ក្នុងនាមសមាជិករបស់ អាយស៊ីស៊ី ទាំងមូល នូវការពេញចិត្តពេញថ្លើមយ៉ាងខ្លាំង។ បន្ទាប់ពីធ្វើការងារអស់រយៈពេល២០ឆ្នាំកន្លងមក អាយស៊ីស៊ី របស់យើងនៅតែជាស្ថាប័នមួយដ៏រស់រវើក សកម្ម និងរុងរឿង។ មិនត្រឹមតែមានគម្រោងថ្មីៗ ដែលនឹងត្រូវប្រកាសសម្រាប់ថ្ងៃអនាគតនោះទេ ពោលគឺមានគម្រោងជួសជុលប្រាសាទព្រះពិធូ ដោយសាធារណរដ្ឋកូរ៉េ និងគម្រោងជួសជុលស្ពានហាលអង្គរវត្តដែលជាគម្រោងបន្តមួយរបស់ជប៉ុន និងគម្រោងជួសជុលប្រាសាទព្រះខ័នកំពង់ស្វាយដោយប្រទេសឥណ្ឌា ការអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ដោយអាជ្ញាធរអប្សរា ការសិក្សាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងទឹកនៅអង្គរ ដែលជាកិច្ចសហប្រតិបត្តិការមួយរវាងអាជ្ញាធរអប្សរា និងស្ថាប័ន SIAVB ស្ថាប័ន SIAAP និងសមាគម AAA។

ប៉ុន្តែក៏មានការប្តេជ្ញាថ្មីៗដែរក្នុងការបន្តផ្តល់ហិរញ្ញប្បទានទៅលើគម្រោងសំខាន់ៗផ្សេងទៀត រួមមានគម្រោងខ្សែក្រវាត់បៃតងពីសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គម្រោងបន្តពាក់ព័ន្ធនឹងបេតិកភណ្ឌសហគមន៍របស់ប្រទេសនូវែលហ្សេឡង់ ដែលទើបបានបញ្ជាក់កាលពីពេលថ្មីៗនេះថា នឹងបន្តក្នុងរយៈពេល៥ឆ្នាំទៀត។ កាលពីព្រឹកមិញ ឯកឧត្តម ឃួន ឃុននាយ បានធ្វើបទបង្ហាញមួយស្តីអំពីការងារដែលសម្រេចបានកន្លងមកនៅក្នុងបរិវេណឧទ្យានអង្គរ ពាក់ព័ន្ធនឹងសហគមន៍ក្នុងស្រុក។

យើងអាចនិយាយបានដោយមិនស្ទាក់ស្ទើរថា អាយស៊ីស៊ី របស់យើង ទោះបីជាមានអាយុកាល២០ឆ្នាំហើយក៏

ដោយ នៅតែជាស្ថាប័នមួយដ៏រស់រវើកបើប្រៀបធៀបទៅនឹងស្ថាប័នផ្សេងទៀតក្នុងពិភពលោក ដែលមានភារកិច្ចអភិរក្សនិងជួសជុលបេតិកភណ្ឌ។ យើងអាចមានមោទនភាពចំពោះបទពិសោធន៍ដ៏វែងឆ្ងាយរបស់ អាយស៊ីស៊ី យើងនេះ ដែលមិនត្រឹមតែនៅមានវត្តមានតទៅទៀតនោះទេ ប៉ុន្តែថែមទាំងនៅតែអាចបង្កើតគម្រោងថ្មីៗដែលតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរអប្សរានៅក្នុងក្របខណ្ឌ អាយស៊ីស៊ី របស់យើងនេះទៀតផង។ វាគឺជាប្រភពនៃមោទនភាពមួយ ពោលគឺ អាយស៊ីស៊ី នៅបន្តមានវត្តមានតទៅទៀត និងរីកចម្រើនថែមទៀត។ បែបនេះយើងឃើញអំពីប្រយោជន៍របស់ អាយស៊ីស៊ី អង្គរ។ ស្ថាប័នសម្រាប់ការពិចារណា តាមដាន ពិគ្រោះយោបល់ និងធ្វើសេចក្តីសម្រេចមួយនេះ ធ្វើឲ្យយើងបានជួបជុំគ្នា ហើយយើងសូមឲ្យស្ថាប័ននេះបន្តមានសុខភាពល្អតទៅទៀត។ សូមឲ្យ អាយស៊ីស៊ី របស់យើងមានអាយុវែងតទៅទៀត។ សូមអរគុណ។

**សហប្រធានបារាំង៖** សូមអរគុណឯកឧត្តមឧបនាយករដ្ឋមន្ត្រីចំពោះទស្សនវិស័យដែលឯកឧត្តមបានគូសវាសមកនេះ។ ខ្ញុំក៏សូមអរគុណផងដែរចំពោះពាក្យពេចន៍កោតសរសើររបស់ឯកឧត្តមចំពោះសហប្រធានទាំងពីរក៏ដូចជាចំពោះសមាជិករបស់គណៈកម្មាធិការនិងលេខាធិការដ្ឋានអចិន្ត្រៃយ៍។ ខ្ញុំជឿថា យើងទាំងអស់គ្នាប្រាកដជាពេញចិត្តជាពិសេសចំពោះពាក្យពេចន៍ទាំងនេះ។ នៅពេលនេះ ខ្ញុំសូមផ្តល់វេទិកានេះជូនតំណាងអគ្គនាយិកាអង្គការយូណេស្កូ លោក គីស៊័រ វ៉ាវ នាយកមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក។ លោកនាយក សូមអញ្ជើញ។

## ១.៣. សុន្ទរកថាតំណាងអគ្គនាយិកាអង្គការយូណេស្កូ លោក គីស៊័រ វ៉ាវ នាយកមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក

សូមគោរពឯកឧត្តមបណ្ឌិត សុខ អាន ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
សូមគោរពលោក សែហ្ស ម៉ូស្ទូរ៉ា ឯកអគ្គរដ្ឋទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា។
សូមគោរពលោក យូឃី គូម៉ាម៉ារ៉ូ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំសូមចាប់ផ្តើមដោយសូមសម្តែងនូវក្តីរីករាយដែលបានមកចូលរួមជាមួយឯកឧត្តម លោកជំទាវនៅពេលនេះ។ នេះគឺជាលើកទី២ហើយ ដែលខ្ញុំ បានមកកម្ពុជា ក្នុងរយៈពេល៦ខែ បន្ទាប់ ពីបានចំណាយពេលអស់ជាងពីរសប្តាហ៍ធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រីក្នុងនាមជាប្រធានសម័យប្រជុំលើកទី៣៧នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក។ ក្តីរីករាយនេះ ខ្ញុំពិតជាមានសារជាថ្មីម្តងទៀត នៅក្នុងខួបលើកទី២០នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលដែលជាយន្តការមួយដ៏ពិតប្រាកដ ល្អគ្មានពីរ ដែលបានបង្ហាញនូវជោគជ័យដ៏ធំនៅក្នុងការអនុវត្តការងារអភិរក្សរមណីយដ្ឋាន មួយក្នុងចំណោមរមណីយដ្ឋាន បេតិកភណ្ឌ

ពិភពលោកដ៏សំខាន់ៗបំផុត។ យើងខ្ញុំសូមសម្តែងអំណរគុណដល់ដៃគូទាំងអស់ ស្ថាប័ននិងប្រទេសផ្តល់ជំនួយ ព្រមទាំងអ្នកបច្ចេកទេសដែលបានចូលរួមដល់ជោគជ័យរបស់ អាយស៊ីស៊ី និងជោគជ័យរបស់រមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ។

នៅឆ្នាំ២០០៤ ពោលគឺកាលពី១០ឆ្នាំមុន យើងបានប្រារព្ធពិធីដករមណីយដ្ឋានអង្គរចេញពីបញ្ជីបេតិកភណ្ឌពិភពលោកប្រកបដោយសភាពគ្រោះថ្នាក់ ហើយទោះបីជាបច្ចុប្បន្ននេះរមណីយដ្ឋានអង្គរនៅតែប្រឈមនឹងបញ្ហាប្រឈមទូទៅ ដូចជារមណីយដ្ឋានពិភពលោកដទៃទៀតក៏ដោយ ក៏អង្គរនៅតែក្លាយជាគំរូមួយដ៏ពិតប្រាកដនៃការអនុវត្តល្អៗ ដោយសារមានការគាំទ្រផ្នែកបច្ចេកទេស និងការចូលរួមវិភាគទានហិរញ្ញវត្ថុដែលអាចធ្វើទៅបានដោយសារយន្តការរបស់ អាយស៊ីស៊ី នេះឯង។

សម័យប្រជុំនៅថ្ងៃនេះពិតជាមានរយៈពេលខ្លី ដូច្នេះខ្ញុំមិននិយាយវែងពេកនោះទេ។ ខ្ញុំគ្រាន់តែចង់គូសបញ្ជាក់នូវទិដ្ឋភាពមួយចំនួនៈ ជាអាទិ៍គឺថាអង្គរតែងតែជាមុខមាត់មួយគំរូក្នុងវិស័យអភិរក្សបេតិកភណ្ឌ ហើយបើនិយាយឲ្យកាន់តែពិសេសទៅទៀតនោះ គឺការអភិរក្សនេះប្រព្រឹត្តទៅនៅក្នុងក្របខណ្ឌនៃអនុសញ្ញាបេតិកភណ្ឌពិភពលោក។ ថ្ងៃនេះគឺជាឱកាសមួយដែលធ្វើឲ្យយើងបញ្ជាក់ឡើងវិញ និងបង្កើតនូវចក្ខុវិស័យមួយសម្រាប់អង្គរដែលមានលក្ខណៈនវានុវត្តន៍ តាមរយៈការដោះស្រាយបញ្ហាសំខាន់ៗដែលកំណត់ការអភិរក្សបេតិកភណ្ឌ។

ឆ្នាំទៅមិញគឺជាឆ្នាំគម្រប់ខួប៤០ឆ្នាំនៃអនុសញ្ញាបេតិកភណ្ឌពិភពលោក ហើយប្រធានបទដែលបានជ្រើសរើសសម្រាប់ខួបគម្រប់៤០ឆ្នាំនោះគឺ *បេតិកភណ្ឌពិភពលោកនិងការអភិវឌ្ឍប្រកបដោយចីរភាពៈ តួនាទីរបស់សហគមន៍ក្នុងស្រុក*។ ខ្ញុំដូចជាយល់ថា រមណីយដ្ឋានអង្គរជានិមិត្តសញ្ញាមួយដ៏ល្អជាងគេនៃទំនាក់ទំនងនេះ ពោលគឺទំនាក់ទំនងរវាងការអភិរក្ស ការអភិវឌ្ឍប្រកបដោយចីរភាព និងការគ្រប់គ្រងសហគមន៍ក្នុងស្រុកប្រកបដោយចីរភាព។

ចក្ខុវិស័យនេះក៏ត្រូវបានបញ្ជាក់ផងដែរនៅក្នុងចក្ខុវិស័យក្យូតូ ដែលត្រូវបានតាក់តែងឡើងនៅក្នុងសេចក្តីសន្និដ្ឋាននៃខួបគម្រប់៤០ឆ្នាំនៃអនុសញ្ញាបេតិកភណ្ឌពិភពលោក។ ខួបនោះត្រូវបានទទួលរៀបចំឡើងប្រកបដោយសន្តានចិត្តជ្រះថ្លាពីរដ្ឋាភិបាលជប៉ុននៅទីក្រុងក្យូតូកាលពីឆ្នាំទៅ។

យើងខ្ញុំបានសាកល្បងផ្សព្វផ្សាយ ឲ្យបានទូលំទូលាយជាទូទៅនូវខ្លឹមសារនៃការអភិវឌ្ឍប្រកបដោយចីរភាព

សម្រាប់ការអភិរក្សរមណីយដ្ឋានបេតិកភណ្ឌពិភពលោកនៅក្នុងពិភពលោកទាំងមូល ហើយខ្ញុំជឿថា កម្ពុជាអាចចែករំលែកបទពិសោធន៍របស់ខ្លួនជាមួយពិភពលោកទាំងមូលស្ដីអំពីប្រធានបទនេះ។ ស្ថាប័នអន្តររដ្ឋាភិបាលដែលត្រួតពិនិត្យពីលើលើការអនុវត្តអនុសញ្ញានេះ ពោលគឺគណៈកម្មាធិការបេតិកភណ្ឌពិភពលោក បានស្នើសុំឲ្យកម្ពុជា រៀបចំក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌមួយដោយរួមបញ្ចូលគ្រប់ទិដ្ឋភាព ហើយខ្ញុំ ពិតជារីករាយដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានបញ្ជាក់ប្រាប់យើងទាំងអស់គ្នាថា ដោយសារមានជំនួយនិងហិរញ្ញប្បទានពីរដ្ឋាភិបាលអូស្ត្រាលី ក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌត្រូវបានធ្វើចប់រួចរាល់ជាស្ថាពរហើយ ព្រមទាំងនឹងត្រូវអនុវត្តចាប់ពីដើមឆ្នាំក្រោយនេះទៅ។ ខ្ញុំអាចបញ្ជាក់ជូនឯកឧត្តមអំពីការប្ដេជ្ញា យ៉ាងពេញទំហឹងរបស់ការិយាល័យអង្គការយូណេស្កូនៅភ្នំពេញ និងរបស់ទីស្នាក់ការអង្គការយូណេស្កូ ក៏ដូចជាមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក ដើម្បីធានាឲ្យការអនុវត្តក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌនេះទទួលបានជោគជ័យ។

ខ្ញុំក៏មានសេចក្ដីរីករាយជាអនេកផងដែរ ដែលបានកត់សម្គាល់ឃើញថាមានឧទាហរណ៍ផ្សេងៗទៀតនៃការអនុវត្តកាលពីពេលថ្មីៗនេះនូវគម្រោងជាច្រើនពាក់ព័ន្ធនឹងប្រធានបទនៃការអភិវឌ្ឍប្រកបដោយចីរភាពនៅអង្គរ។ ខ្ញុំបានទទួលព័ត៌មានថា ដៃគូមួយក្នុងចំណោមដៃគូទាំងអស់របស់យើង អស់រយៈពេលជាយូរមកហើយនោះ នៅក្នុងវិស័យឯកជន ក្នុងការអនុវត្តអនុសញ្ញាបេតិកភណ្ឌពិភពលោក គឺក្រុមហ៊ុន Panasonic កាលពីម្សិលមិញក្នុងពេលប្រារព្ធពិធីមួយ បានផ្ដល់ជាអំណោយនូវអំពូលដើរដោយកាំរស្មីព្រះអាទិត្យចំនួន១៥០០អំពូលសម្រាប់ចែកជូនប្រជាជននៅតាមភូមិចំនួន៤៣នៅក្នុងឧទ្យានអង្គរ។ ខ្ញុំគិតថាវាជាវិភាគទានមួយដ៏ពិសេសសម្រាប់ជាប្រយោជន៍ដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

នៅពេលដែលយើងផ្សារភ្ជាប់វិភាគទាននៃការអភិរក្សបេតិកភណ្ឌជាប្រយោជន៍ដល់ការអភិវឌ្ឍប្រកបដោយចីរភាព យើងចាំបាច់ត្រូវចែករំលែកនូវលទ្ធផលនៃការសិក្សានិងព័ត៌មានផ្សេងៗដែលបង្ហាញនូវប្រសិទ្ធភាពនិងភស្តុតាងផ្សេងៗ ព្រមទាំងបង្ហាញថា ជាការពិត ការអភិរក្សបេតិកភណ្ឌពិតជារួមចំណែកដល់ការអភិវឌ្ឍ។ ការបង្កើតកាលពីពេលថ្មីៗនេះនូវមជ្ឈមណ្ឌលប្រភេទទី២នៃបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូនៅប្រទេសអ៊ីតាលី ជំនាញខាងសេដ្ឋកិច្ចនៃការអភិរក្សបេតិកភណ្ឌ ខ្ញុំគិតថាវាជាមធ្យោបាយជោគជ័យមួយបន្ថែមទៀត។ បើសិនជាខ្ញុំមិនច្រឡំទេនោះ គេបានស្នើឡើងនូវគម្រោងធ្វើការវិភាគសេដ្ឋកិច្ចមួយដ៏ស៊ីជម្រៅអំពីការងារដែលកំពុងប្រព្រឹត្តទៅនៅអង្គរដើម្បីផ្ដល់នូវព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយស្ដីអំពីការសិក្សាស្រាវជ្រាវប្រភេទនេះ។ ខ្ញុំគិតថា វាប្រហែលជាមានប្រយោជន៍ដែលគួរបង្កើតដៃគូមួយជាមួយស្ថាប័ននេះ (*នៅអ៊ីតាលី*)។

វិស័យជាច្រើនផ្សេងទៀតក៏ពាក់ព័ន្ធផងដែរនឹងគម្រោងជាច្រើនដូចជាការអប់រំអំពីបេតិកភណ្ឌនៅតាមសាលារៀននានានៅក្នុងតំបន់។ សម្រាប់ខ្ញុំការបង្កើតក្រុមអ្នកមានវិជ្ជាជីវៈវ័យក្មេងនិងការបំផុសបំផុលយុវជននិងកុមារអំពីតម្រូវការនៃការអភិរក្សបេតិកភណ្ឌដើម្បីអាចកសាងនូវទំនាក់ទំនងរវាងប្រវត្តិសាស្ត្រនិងអត្តសញ្ញាណរបស់ពួកគេម្នាក់ៗគឺជាទិដ្ឋភាពមួយដ៏សំខាន់បំផុតនៃការអភិរក្សបេតិកភណ្ឌ។ យើងនៅតែអាចផ្តោតទៅលើទិដ្ឋភាពបច្ចេកទេសនៃការអភិរក្ស ប៉ុន្តែទន្ទឹមនឹងគ្នានោះ ត្រូវពង្រីកទស្សនវិស័យនិងធានាថា មនុស្សជំនាន់ក្រោយក៏អាចប្តេជ្ញាចូលរួមនៅក្នុងការងារប្រកបដោយសេចក្តីថ្លៃថ្នូរនេះដែរ។

គឺបែបនេះហើយ ឯកឧត្តមសហប្រធានទាំងពីរ ដែលខ្ញុំចង់បញ្ចប់សុន្ទរកថានេះ ហើយខ្ញុំសូមជូនពរឲ្យកិច្ចប្រជុំនេះបានទទួលជោគជ័យ។ សូមអរគុណ។

**សហប្រធានបារាំង៖** សូមអរគុណ លោកនាយកចំពោះពាក្យពេចន៍ជួយលើកទឹកចិត្តនេះ។ គណៈកម្មាធិការបានបង្ហាញនូវសមត្ថភាពរបស់ខ្លួនក្នុងការសម្របទៅតាមបច្ចេកវិទ្យាថ្មីៗនិងដោះស្រាយបញ្ហាផ្សេងៗ នៅពេលនេះខ្ញុំអាចផ្តល់វេទិកាប្រកបដោយសេចក្តីទុកចិត្តដល់សាស្ត្រាចារ្យ អាហ្សេឌីន បេសាអ៊ូស លេខាធិការវិទ្យាសាស្ត្ររបស់អាយស៊ីស៊ីអង្គរ។ កាលពីមុនគេនិយាយថា ផ្លូវទាំងអស់គឺសំដៅទៅទីក្រុងរ៉ូម នៅពេលនេះ លោកសាស្ត្រាចារ្យបេសាអ៊ូស នឹងពន្យល់យើងទាំងអស់គ្នា នៅ ថ្ងៃនេះថា គ្រប់ផ្លូវទាំងអស់គឺសំដៅទៅអង្គរ។ លោកសាស្ត្រាចារ្យសូមអញ្ជើញ។

# ២. របាយការណ៍

## ២.១. បទបង្ហាញដោយសាស្ត្រាចារ្យ អាហ្សេឌីន បេសាអ៊ូស លេខា វិទ្យាសាស្ត្រ អាយ ស៊ី ស៊ី អង្គរ ស្តីអំពី ផ្លូវក្នុងឧទ្យានអង្គរ

សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី។
សូមគោរពឯកឧត្តម លោកជំទាវ សហការី លោក លោកស្រីជាទីគោរព។

[ស្លាយ] នៅក្នុងសម័យអភិរក្សអង្គរ ការធ្វើដំណើរនៅក្នុងឧទ្យានប្រព្រឹត្តទៅបានយ៉ាងងាយតាមវង់ទស្សនាចំនួនពីរ។ នៅពេលដែលយើងបានចាប់ផ្តើមចលនានេះ កាលពី២០ឆ្នាំមុន យើងបាននិយាយអំពីវង់ធំនិងវង់តូច ដែល

បិតាស្ថាបនិកបុរាណវិទ្យាខ្មែរបានបន្សល់ទុកឲ្យយើង។ ដោយមិនបានទាំងនឹកគិតដល់សម័យនោះផង យើងនៅតែបន្តប្រើវង់ទស្សនាទាំងពីរនេះដដែល។ ប៉ុន្តែលក្ខខណ្ឌផ្សេងៗបានធ្វើឲ្យមានការផ្លាស់ប្តូរខ្លះ។ នៅសម័យនោះពោលគឺកាលពីប្រមាណជា៥០ឆ្នាំមុន ប្រជាជននៅក្នុងឧទ្យាន មានន័យថាប្រជាជនដែលរស់នៅក្នុងឧទ្យានផ្ទាល់តែម្តង មិនលើសពី៣ម៉ឺន ទៅ៤ម៉ឺននាក់ទេ នេះបើតាមការស្រាវជ្រាវរបស់សហការីយើង ជាពិសេសគឺ ឯកឧត្តម ឃួន ឃុននាយ ដែលទទួលខុសត្រូវខាងប្រជាជននៅក្នុងឧទ្យាន។ បច្ចុប្បន្ននេះ យើងរាប់ឃើញមានចំនួន ១១២ ភូមិ ហើយប្រជាជនមានលើសពី១០ម៉ឺននាក់ឯណោះ។ ប្រជាជនទាំងនេះហើយដែលជាអ្នកប្រើប្រាស់ដំបូងគេនូវផ្លូវថ្នល់ទាំងឡាយនៅក្នុងឧទ្យាន។

នៅសម័យនោះដែរ ចំនួនភ្ញៀវទាំងភ្ញៀវជាតិ និងទេសចរណ៍ មិនលើសពី៣ម៉ឺនទៅ៧ម៉ឺននាក់នោះទេ។ ខ្ញុំបានឃើញស្ថិតិនៅសម័យនោះអស់រយៈពេល៤០ឆ្នាំ។ ដើម្បីឆ្លុះបញ្ចាំងថា តើគេគិតគូរបែបណា នៅសម័យនោះ មានពាក្យមួយម៉ាត់ដែលអ្នកអភិរក្សនៅសម័យនោះបាននិយាយថាៈ "ក្រោមសំពាធដ៏ខ្លាំងរបស់ភ្ញៀវ"។ ពេលនោះគឺមិនលើសពី៧ម៉ឺននាក់ទេ ដូច្នេះឯកឧត្តម លោកជំទាវ យល់ហើយថា សំពាធខ្លាំងនៅសម័យនោះប៉ុណ្ណា។

បច្ចុប្បន្ននេះ ទាំងភ្ញៀវជាតិនិងទេសចរណ៍បរទេសមានចំនួនឡើងដល់៣លាននាក់ ឬក៏លើសផង។ ដូច្នេះ គឺត្រូវមានឡានតូច ឡានធំ ឡានកាំមីញ៉ុងសម្រាប់ប្រជាជន ការដឹកជញ្ជូននានាសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ យើងក៏សង្កេតឃើញផងដែរឃើញមានមធ្យោបាយដឹកជញ្ជូនដូចជារ៉ឺម៉កដែលអ្នកខ្លះហៅថាតុកតុក និងកង់ម៉ូតូជាដើម។ ខ្ញុំសូមសារភាពថា ខ្ញុំក៏ស្ថិតនៅក្នុងចំណោមមនុស្សម្នាក់ដែលធ្លាប់រាប់ចំនួនកង់ ម៉ូតូ ដែលខ្ញុំឃើញច្រើនគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ដែរ។ ខ្ញុំអាចជម្រាបជូនឯកឧត្តម លោកជំទាវថា ចំនួនឡាន ម៉ូតូនេះបានកើនឡើងស្មើរតែគុណនឹង១០០ដងក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ។ ដូច្នេះយើងគួរតែប្រញាប់ប្រញាល់។

ទាំងនេះគឺដើម្បីជម្រាបជូនឯកឧត្តម លោកជំទាវថា យើងពិតជាមានបញ្ហាមួយដ៏ពិតប្រាកដគឺបញ្ហាចរាចរណ៍នៅក្នុងឧទ្យានអង្គរ ហើយ អាយស៊ីស៊ី បានស្នើជាច្រើនដងរួចមកហើយ ឲ្យយើងធ្វើការសិក្សាមួយស្តីអំពីប្រធានបទនេះ។ អាជ្ញាធរអប្សរាបានប្រមែប្រមូលអ្នកជំនាញមួយចំនួន ហើយបានសិក្សាអំពីបញ្ហានេះជាញឹកញាប់ជាមួយអគ្គនាយកផ្ទាល់គឺឯកឧត្តម ប៊ុន ណារិទ្ធ ហើយយើងបានបញ្ជូនរបាយការណ៍ទៅប្រធានអាជ្ញាធរអប្សរា គឺឯកឧត្តម បណ្ឌិត សុខ អាន។

[ស្លាយ] អ្វីដែលយើងចង់និយាយពេលនេះគឺសំខាន់ខ្លាំងណាស់ ពីព្រោះនៅពេលនេះយើងមានផែនទីមេមួយ

ដែលគួរតែជាផែនទីចរាចរណ៍ទៅថ្ងៃអនាគត វាជួយអភិរក្សរមណីយដ្ឋាន។ យើងខ្ញុំចង់ឲ្យមានផ្លូវវាងឲ្យផុតពីរមណីយដ្ឋានទាំងស្រុងតែម្តង។

[ស្លាយ] ឯកឧត្តម លោកជំទាវឃើញនៅកន្លែងនេះ យើងមានលទ្ធភាពដែលអាចធ្វើបាន។ ផ្លូវនេះមានស្ថានភាពល្អ មានន័យថា ផ្លូវនេះអាចឲ្យគេវាងរមណីយដ្ឋានបាន ហើយធ្វើដំណើរទៅដល់ផ្លូវជាតិលេខ៦ ដោយមិនចាំបាច់ឆ្លងកាត់តាមរមណីយដ្ឋានបុរាណវិទ្យាដែលចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកឡើយ។ អ្វីដែលយើងនៅខ្វះគឺនៅត្រង់ផ្នែកនេះ មានន័យថា តើធ្វើយ៉ាងណាដើម្បីឲ្យយើងអាចភ្ជាប់កំណាត់ផ្លូវទាំងពីរនេះបាន។ ពីព្រោះនៅក្នុងពេលនេះ កំណាត់ផ្លូវនេះមិនល្អទេ យើងឃើញថា មានគំនូសដានស្នាមផ្លូវហើយ ប៉ុន្តែផ្លូវនេះមិនទាន់ល្អ មិនអាចធ្វើដំណើរបាន ហើយយើងចង់ធ្វើយ៉ាងណាឲ្យកំណាត់ផ្លូវនេះទៅភ្ជាប់នឹងផ្លូវជាតិលេខ៦ បញ្ចៀសតំបន់បុរាណវិទ្យា លើកលែងតែត្រង់ចំនុចនេះ ដែលវាធ្វើអំពីថ្មបាយក្រៀម ហើយមិនប៉ះពាល់ដល់ដីបុរាណវិទ្យាទេ។

ដូចឯកឧត្តម លោកជំទាវ ឃើញស្រាប់ហើយ បើសិនជាយើងអាចធ្វើបានជាមួយអាជ្ញាធរអប្សរាធ្វើយ៉ាងណាគឺសំដៅទៅទិសខាងកើត និងទៅទិសខាងលិច យើងអាចធ្វើកំណាត់ផ្លូវទាំងពីរនេះបាន ពេលនោះ យើងនឹងអាចនិយាយបានថា ផ្លូវវាងគឺអាចធ្វើបាន។ តើនៅសល់អ្វីទៀត?

[ស្លាយ] នៅសល់ផ្លូវធំមួយនេះ ដែលឯកឧត្តម លោកជំទាវឃើញហើយ គឺជាផ្លូវដែលធ្វើឲ្យគេភ័យគ្រប់គ្នា។ គ្មានឡានកាំមីញ៉ុងធំៗបើកបរកាត់ផ្លូវនេះទៀតទេ។ ផ្លូវធំនេះគឺជាផ្លូវដែលឆ្លងកាត់តាមរមណីយដ្ឋានធំៗចំនួនពីរនោះគឺរមណីយដ្ឋានដែលផ្ទុកទឹកមានន័យថា គឺបារាយណ៍ខាងលិច និងមហាបុរីអង្គរធំរបស់យើង។ ផ្លូវនេះយើងនឹងធ្វើយ៉ាងណាដើម្បីទុកវាសម្រាប់តែឡានទេសចរណ៍តែប៉ុណ្ណោះ ហើយអាជ្ញាធរអប្សរាក៏ឯកភាពផងដែរជាមួយអាជ្ញាធរពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ហើយយើងសង្ឃឹមថានៅថ្ងៃណាមួយ នឹងមានតែឡានទេសចរណ៍ដែលមិនបំពុលបរិស្ថានប៉ុណ្ណោះដែលបើកកាត់ផ្លូវនេះ។

[ស្លាយ] ជម្រើសចុងក្រោយ៖ នៅពេលនេះមានផ្លូវមួយ ឬក៏មានផ្លូវពីរទៀតផងដែលឆ្លងកាត់កន្លែងដែលពីមុនគឺជាបារាយណ៍ខាងកើត បច្ចុប្បន្ន បារាយណ៍នេះស្ងួតទឹកអស់ហើយ ប៉ុន្តែអ្នកជំនាញដ៏ធំអំពីទឹកគឺបណ្ឌិត ហាង់ ពៅ ដែលចាប់អារម្មណ៍ខ្លាំងទៅលើការស្រាវជ្រាវរបស់លោក ហើយដែលខ្ញុំបានតាមដានជាមួយលោកជាប់ជារៀងរហូតមកដែរ នៅពេលមួយនោះ លោកបានមានប្រសាសន៍ថា លោកនឹងធ្វើឲ្យបារាយណ៍ខាងជើងមានទឹកឡើងវិញ ហើយគ្រប់គ្នាសុទ្ធតែមើលលោកដូចជាមនុស្សម្នាក់មិនប្រក្រតី ប៉ុន្តែខ្ញុំ ខ្ញុំកោតសរសើរលោក ហើយខ្ញុំនិយាយ

ថា "គាត់នឹងអាចធ្វើបាន" ហើយចុងបញ្ចប់គាត់ពិតជាធ្វើបានមែន។ មានទឹកនៅក្នុងបារាយណ៍នេះ លោក លោកស្រីឃើញស្រាប់ហើយ ហើយទឹកនេះនឹងមានជារៀងរហូត។ [ស្លាយ] លោក ហាង់ ពៅ បាននិយាយប្រាប់យើងថា គាត់នឹងបញ្ចូលទឹកទៅក្នុងបារាយណ៍ខាងកើត ប៉ុន្តែដើម្បីធ្វើបែបនោះបាន គឺអ្នកភូមិដែលកំពុងរស់នៅក្នុងបារាយណ៍នាពេលបច្ចុប្បន្ននេះត្រូវផ្លាស់ទៅរស់នៅកន្លែងផ្សេងវិញ ហើយផ្លូវទាំងនេះដែលឆ្លងកាត់ចំកណ្តាលបារាយណ៍តែម្តង និងជិតបារាយណ៍ខាងកើតត្រង់កន្លែងនេះ ត្រូវពង្វាងចេញ។

[ស្លាយ] នេះគឺជាអ្វីដែលយើងចង់ ស្នើជូនឯកឧត្តម លោកជំទាវទាំងអស់គ្នា៖ ផ្លូវនេះត្រូវធ្វើបំពេញបន្ថែមរហូតដល់ត្រង់ចំនុចនេះ ហើយបន្ទាប់មកវានឹងបែកចេញជាពីរ និងឆ្លងកាត់តំបន់នេះ។ ដើម្បីកុំឲ្យវាឆ្លងកាត់ទៀត យើងត្រៀមរៀបចំលទ្ធភាពមួយនេះ។ សំណើគឺធ្វើផ្លូវនេះបន្តទៅទិសបន្ទាយស្រី។ ផ្លូវនេះនឹងមានផលប្រយោជន៍បី។ ទី១គឺវាមិនឆ្លងកាត់បារាយណ៍ទៀតទេ ទី២គឺវាឆ្លងកាត់ជិតប្រាសាទបន្ទាយសំរែ ដែលអនុញ្ញាតឲ្យភ្ញៀវទៅទស្សនាប្រាសាទនេះបានយ៉ាងងាយ ពីព្រោះបច្ចុប្បន្ននេះ ប្រាសាទបន្ទាយសំរែមិនសូវមានភ្ញៀវទៅទស្សនាទេ។ រីឯផលប្រយោជន៍ទី៣ គឺធ្វើយ៉ាងណាកុំឲ្យផ្លូវនេះឆ្លងកាត់ប្រាសាទប្រែរូបទៀត។ បច្ចុប្បន្ននេះ នៅប្រាសាទប្រែរូបដីមួយផ្នែកធំត្រូវបានឆ្លងកាត់ដោយផ្លូវថ្នល់។ យើងនឹងធ្វើឲ្យផ្លូវទាំងនេះវាងប្រាសាទប្រែរូប ហើយពេលនោះយើងនឹងមានលទ្ធភាពសាងសង់មជ្ឈមណ្ឌលបដិសណ្ឋារកិច្ចមួយ ឬរចនាសម្ព័ន្ធណាមួយដែលធ្វើឲ្យភ្ញៀវអាចទស្សនាប្រាសាទប្រែរូបក្នុងលក្ខខណ្ឌមួយប្រសើរជាងនេះ។

ឯកឧត្តម លោកជំទាវឃើញស្រាប់ហើយ បញ្ហាបច្ចុប្បន្ននេះមិនមែនជាបញ្ហាដែលយើងធ្លាប់ជួបកាលពីមុននោះទេ មានន័យថា យើងកំពុងមានសំពាធមួយដ៏ធំ ប៉ុន្តែយើងនឹងសាកល្បងនៅក្នុងរយៈពេល២ ទៅ៣ឆ្នាំខាងមុខធ្វើយ៉ាងណាឲ្យអាជ្ញាធរអប្សរាដែលមានការឯកភាពពីរាជរដ្ឋាភិបាល ធ្វើកិច្ចការទាំងនេះឲ្យបានសម្រេច។ នៅពេលនោះ យើងនឹងអាចនិយាយថា អ្វីដែលឯកឧត្តម លោកជំទាវចង់បាន អ្វីដែលរមណីយដ្ឋានតម្រូវឲ្យធ្វើ មានន័យថា មិនឲ្យមានឡានកាំមីញ៉ុង និងលុបបំបាត់ចោលនូវសំពាធទាំងឡាយ គឺធ្វើបានសម្រេច។ ប្រសិនបើយើងមានសំណាង ហើយចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាសុបិន្តចង់បានបែបនេះ ខ្ញុំខ្លួនឯងមិនចេះបើកបរទេ ដូច្នេះឯកឧត្តម លោកជំទាវឃើញហើយថា ខ្ញុំមិនផ្សាយពាណិជ្ជកម្មទេ ប៉ុន្តែខ្ញុំឃើញឡានអគ្គិសនីមួយនៅខាងក្រៅ ឡាននោះធ្វើឲ្យខ្ញុំនឹកឃើញដល់រឿងអតីតកាលមួយចំនួន ខ្ញុំនិយាយប្រាប់ខ្លួនឯងថា "ហេតុអ្វីបានជាខ្ញុំមិនដែលរៀនបើកបរទាល់តែសោះ?" នោះគឺធ្វើឲ្យខ្ញុំចង់ឆ្លងកាត់រមណីយដ្ឋានមួយដែលគ្មានបរិយាកាសពុល ខ្ញុំសង្ឃឹមថាការនេះនឹងអាចធ្វើបានទៅថ្ងៃអនាគត។ សូមអរគុណ។

**សហប្រធានបារាំង៖** សូមអរគុណ លោកសាស្ត្រាចារ្យចំពោះបទអន្តរាគមន៍របស់លោក។ នៅពេលនេះខ្ញុំសុំផ្តល់វេទិកាជូនលោក ហ្សង់ បាទីស្ត៍ សឺវ៉ង់ស៍ ប្រធានមូលនិធិបុរាណវិទ្យានិងអភិវឌ្ឍន៍ និងលោកស្រី សុវណ្ណា ហ្គោនឡែត្ត ប្រធានអង្គការ Wildlife Alliance ដែលនឹងលើកឡើងអំពីគ្រោះថ្នាក់ដែលគំរាមកំហែងលើបេតិកភណ្ឌនិងបរិស្ថាននៅភ្នំគូលែន។ សូមអញ្ជើញ។

## ២.២. បទបង្ហាញដោយលោក ហ្សង់ បាទីស្ត៍ សឺវ៉ង់ស៍ ប្រធានមូលនិធិបុរាណវិទ្យានិងអភិវឌ្ឍន៍ និងលោកស្រី សុវណ្ណា ហ្គោនឡែត្ត ប្រធានអង្គការ Wildlife Alliance ស្តីអំពី គ្រោះថ្នាក់ដែលគំរាមកំហែងលើបេតិកភណ្ឌនិងបរិស្ថាននៅភ្នំគូលែន

**លោក ហ្សង់ បាទីស្ត៍ សឺវ៉ង់ស៍៖**
សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី។
សូមគោរពឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ជាទីគោរព។

នេះគឺជាបទបង្ហាញលើកទី៣ហើយរបស់ខ្ញុំស្តីអំពីគ្រោះថ្នាក់ដែលគំរាមកំហែងលើបេតិកភណ្ឌបុរាណវិទ្យានិងបរិស្ថាននៅភ្នំគូលែន។ ដោយចាប់ដៃគូជាមួយអាជ្ញាធរអប្សរា មូលនិធិបុរាណវិទ្យានិងអភិវឌ្ឍន៍ ហៅកាត់ថា ADF ធ្វើការស្រាវជ្រាវអភិរក្សនិងអភិវឌ្ឍន៍តាំងពីឆ្នាំ២០០៨មកនៅភ្នំគូលែន ហើយយើងខ្ញុំពិតជាដឹងច្បាស់អំពីបញ្ហាជាច្រើនដែលចោទឡើងនៅទីនោះ។

ក្រោយពីមូលនិធិ ADF បានប្រកាសអាសន្នកាលពីឆ្នាំ២០១២កន្លងមក នៅក្នុងសម័យប្រជុំពេញអង្គ និងសម័យប្រជុំបច្ចេកទេសរបស់ អាយស៊ីស៊ី អង្គការយូណេស្កូបានទទួលស្គាល់ថា ភ្នំគូលែនគឺជាប្រភព "និមិត្តរូបរបស់អង្គរ" ហើយបានផ្តល់អនុសាសន៍ឲ្យពង្រីកតំបន់បេតិកភណ្ឌពិភពលោកអង្គរ ដើម្បីបញ្ចូលភ្នំគូលែនផងដែរ។ ខ្ញុំសូមអញ្ជើញឯកឧត្តម លោកជំទាវ អានអនុសាសន៍ពិសេសទី២នៃសម័យប្រជុំរបស់ អាយស៊ីស៊ី ពេលនោះ។ ខ្ញុំសូមសម្តែងនូវអំណរគុណដល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីដែលបានបង្កើតនាពេលនោះ នូវគណៈកម្មាធិការមួយទទួលបន្ទុកភ្នំគូលែន។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបង្ហាញជូនឯកឧត្តម លោកជំទាវ នូវស្ថានភាពពេលបច្ចុប្បន្ននេះ។

[ស្លាយ] ខ្ញុំសូមរំលឹកថាភ្នំគូលែនស្ថិតនៅចម្ងាយ៤០គីឡូម៉ែត្រពីឧទ្យានអង្គរ ហើយវាជាជួរភ្នំដ៏ធំជាងគេនៅក្នុងតំបន់នេះ និងជាប្រភពនៃអាងផ្ទុកទឹកនៅអង្គរនិងសៀមរាបចំនួន៣ ដែលធ្វើឲ្យជួរភ្នំគូលែនគឺជាតំបន់ដ៏សំខាន់

ពិសេសបំផុត។

[ស្លាយ] ឧទ្យានជាតិដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងបរិស្ថានគឺស្ថិតនៅក្នុងទឹកដីខេត្តសៀមរាប។ ឧទ្យានជាតិនេះគ្របដណ្ដប់ទៅលើភូមិចំនួន៣ និងមានផ្ទៃក្រឡា៣៧៥០០ហិកតារ។ អាជ្ញាធរអប្សរាមានយុត្តាធិការនៅក្នុងខេត្ត ហើយតំបន់បុរាណវិទ្យាជាច្រើននៅលើភ្នំដែលត្រូវការពារ គឺស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរអប្សរានេះឯង។

[ស្លាយ] នៅលើភ្នំគូលែន មានប្រជាជនរស់នៅប្រមាណជា៤០០០នាក់ ភូមិចំនួន១០។ ការគ្រប់គ្រងទេសចរណ៍ត្រូវបានប្រគល់ជាសម្បទានឲ្យក្រុមហ៊ុនឯកជនមួយ។

[ស្លាយ] យើងនៅតែឃើញមានការគំរាមកំហែងធំៗចំនួន៦ដែលជាបញ្ហានៅភ្នំគូលែន។ ខ្ញុំធ្លាប់មានឱកាសបានសង្កត់ធ្ងន់លើការគំរាមកំហែងសំខាន់ជាងគេក្នុងចំណោមការគំរាមកំហែងទាំងនោះហើយ គឺការកាប់ព្រៃឈើ។

[ស្លាយ] មូលហេតុដំបូងគេគឺការធ្វើកសិកម្មដោយដុតព្រៃ ការកាប់ព្រៃគឺធ្វើដោយប្រជាជនជាង៣/៤ដែលរស់នៅលើភ្នំគូលែននោះ។ ជាមួយនឹងការកើនឡើងនូវចំនួនប្រជាជន បាតុភូតនេះកាន់តែមានសភាពខ្លាំងឡើង ស្ទើរតែពាសពេញភ្នំតែម្ដង កន្លែងដែលមាននៅសល់ព្រៃឈើគឺនៅតិចតួចណាស់។ បាតុភូតនេះក៏ជាបញ្ហាដែលឃើញកើតមានឡើងនៅតាមតំបន់ដែលគេចាត់ទុកថាជាតំបន់ការពារដែរ។

[ស្លាយ] ដើម្បីឲ្យដឹងពីទំហំនៃបញ្ហា ខ្ញុំសូមអញ្ជើញឲ្យឯកឧត្តម លោកជំទាវ មើលពីខាងលើមកវិញ មើលទៅតាមជ្រុងនៃជួរភ្នំ។ បែបនេះឯកឧត្តម លោកជំទាវនឹងឃើញច្បាស់ថាទិដ្ឋភាពដែលយើងឃើញពីក្រៅ ពិតជាធ្វើឲ្យគេមិនអាចស្មានបាន ពីព្រោះព្រៃឈើព័ទ្ធពីខាងក្រៅបាំងបាត់នូវអ្វីដែលនៅពីខាងក្រោយ នៅតាមចង្កេះភ្នំ នៅតាមបណ្ដោយផ្លូវធំ មានដើមឈើអមសងខាង ប៉ុន្តែនៅពីខាងក្រោយ ខាងក្នុង ដើមឈើត្រូវបានគេកាប់អស់ទៅហើយ។ ព្រៃអមសងខាងផ្លូវបែបនោះធ្វើឲ្យគេមានអារម្មណ៍ថាព្រៃឈើត្រូវបានគេអភិរក្ស នៅពេលគេធ្វើដំណើរទៅទស្សនាព្រះអង្គធំ ឬបើគេមើលពីក្រោមទៅលើកំពូលភ្នំវិញ ប៉ុន្តែការពិតមិនដូច្នោះឡើយ ពីព្រោះបើសិនជាគេមើលពីខាងលើមកវិញ ឬបើគេឆ្លងកាត់ព្រៃនៅតាមបណ្ដោយផ្លូវនេះ។ នេះគឺជារូបភាពមួយដែលមើលពីខាងលើបន្តិច ផ្នែកខាងត្បូងនៃជួរភ្នំ។

[ស្លាយ] ការអនុវត្តបែបនេះបូកផ្សំបន្ថែមជាមួយនិងការកាប់ព្រៃដាំដើមស្វាយចន្ទីដែលគេឃើញនៅគ្រប់ទីកន្លែង វាជាសកម្មភាពខុសច្បាប់នៅក្នុងឧទ្យានជាតិ ហើយការដាំដើមស្វាយចន្ទីនេះជំនួសបន្តិចម្តងៗកន្លែងឬក៏ដីដែលគេទុកសម្រាប់ធ្វើស្រែ។

[ស្លាយ] ការពង្រីកចម្ការនិងភូមិមួយចំនួនកាលពីពេលថ្មីៗនេះ នៅជើងភ្នំឧទ្យានជាតិគឺជាបញ្ហាមួយទៀតនៃការកាប់ព្រៃឈើ។ [ស្លាយ] ខ្ញុំសូមបង្ហាញជូនឯកឧត្តម លោកជំទាវ នូវរូបភាពមួយចំនួនដែលបានថតកាលពីពេលកន្លងមកនៅត្រង់កន្លែងដូចគ្នាកាលពីឆ្នាំ១៩៦០ ឆ្នាំ២០០១ ឆ្នាំ២០០៤ ឆ្នាំ២០០៧ ឆ្នាំ២០០៩ និងនៅដើមឆ្នាំនេះ។

[ស្លាយ] និងចុងបញ្ចប់ ការកាប់ព្រៃឈើក៏កើតមានដោយសារការកាប់ដើមឈើធំៗខុសច្បាប់ផងដែរ។ ការប្រព្រឹត្តបែបនេះគឺមានជាទូទៅនៅក្នុងឧទ្យានជាតិទាំងមូល។ [ស្លាយ] អំពើនេះនៅតែបន្តធ្វើ ព្រមទាំងធ្វើកាន់តែច្រើនឡើងទៀតផងនៅចន្លោះរវាងកិច្ចប្រជុំ អាយស៊ីស៊ី លើកមុន មកដល់ថ្ងៃនេះដូចដែលរូបភាពនេះមានកាលបរិច្ឆេទជាសក្ខីភាពស្រាប់។

[ស្លាយ] បាតុភូតទាំងនេះបានកើតមានឡើង គឺមួយផ្នែកដោយសារពុំមានការអនុវត្តច្បាប់។ មានច្បាប់ ប៉ុន្តែមធ្យោបាយដែលផ្តល់ជូនដើម្បីអនុវត្តច្បាប់នៅមិនទាន់គ្រប់គ្រាន់នៅឡើយ។

[ស្លាយ] ផលលំបាកខាងផ្នែកបរិស្ថានពិតជាធំធេងយ៉ាងខ្លាំង ប៉ុន្តែខ្ញុំសូមសង្កត់ធ្ងន់ជាពិសេសទៅលើផលលំបាកសេដ្ឋកិច្ច ហើយបើសិនយើងត្រូវចងចាំរូបមួយក្នុងចំណោមរូបទាំងអស់ដែលមាននៅក្នុងបទបង្ហាញនេះ គឺរូបនេះឯង។ យើងដឹងហើយថា ការងារជាវាសាស្រ្តត្រូវបានធ្វើ ប៉ុន្តែអវត្តមានព្រៃឈើបានបង្កនូវផលលំបាកផ្ទាល់ទៅលើសេដ្ឋកិច្ចនៅក្នុងតំបន់សៀមរាបទាំងមូលតែម្តង។

[ស្លាយ] ពាក់ព័ន្ធនឹងបេតិកភណ្ឌបុរាណវិទ្យាដ៏សម្បូរបែបនៅលើភ្នំ កិច្ចខិតខំប្រឹងប្រែងធ្វើឡើងដោយអាជ្ញាធរអប្សរាកាលពីពេលថ្មីៗនេះពិតជាធំធេងយ៉ាងខ្លាំង ប៉ុន្តែវានៅតែមានការគំរាមកំហែងមួយចំនួនដែលចោទទៅលើរមណីយដ្ឋាននេះដដែល ដូចជាប្រាង្គប្រាសាទមិនទាន់មានការឃាមកាមឲ្យបានជិតដល់ មានការបំពុលបរិស្ថាន ស្ថានភាពទ្រុឌទ្រោម និងការបាក់ធ្លាក់ចុះមកជាហូរហែ។

[ស្លាយ] និងចុងក្រោយការគំរាមកំហែងសំខាន់ដែរនោះពាក់ព័ន្ធនឹងរមណីយដ្ឋានព្រះអង្គធំ ដែលជាកន្លែងសម្បូរទេសចរទៅទស្សនាជាងគេ ព្រះអង្គធំគឺជាកន្លែងដែលមានសំពាធទេសចរណ៍ខ្លាំង ហើយដែលមានការគ្រប់គ្រងមិនបានល្អ និងមានមនុស្សច្រើន។

**សំណើ៖**

[ស្លាយ] ពាក់ព័ន្ធនឹងសំណើ យើងខ្ញុំពិតជាគាំទ្រយ៉ាងពេញទំហឹងចំពោះគំនិតក្នុងការបង្កើតគណៈកម្មាធិការនេះដែលបើតាមយោបល់យើងខ្ញុំ គួរតែបញ្ចូលគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលខ្ញុំនឹងមិនលើកឈ្មោះចំៗនៅពេលនេះទេ ប៉ុន្តែឯកឧត្តម លោកជំទាវនឹងឃើញនៅលើអេក្រង់ស្រាប់។ តួនាទីនិងទំនួលខុសត្រូវរបស់ភាគីនីមួយៗគួរតែបញ្ជាក់ឲ្យបានច្បាស់។ លក្ខណៈច្បាប់ពិសេសសម្រាប់ឧទ្យានជាតិគួរតែត្រូវកំណត់ ហើយជាពិសេសធនធានដែលផ្តល់ជូនភាគីពាក់ព័ន្ធនីមួយៗនេះ សម្រាប់អនុវត្តវិធានការទាំងឡាយ។ ចុងបញ្ចប់ ការងារទាំងអស់គួរតែរួមបញ្ចូលប្រជាជននៅក្នុងស្រុកផងដែរ។

[ស្លាយ] ចំណុចទី២ គឺការពង្រឹងច្បាប់និងបទដ្ឋានផ្សេងៗ និងការអនុវត្តច្បាប់បរិស្ថាន ព្រមទាំងការគ្រប់គ្រងរមណីយដ្ឋានព្រះអង្គធំ។ យើងខ្ញុំក៏សូមផ្តល់អនុសាសន៍ផងដែរ [ស្លាយ] ខ្ញុំសូមបង្ហាញជូនរូបថតមួយចំនួនជាឧទាហរណ៍ ឲ្យពង្រឹងមធ្យោបាយរបស់អាជ្ញាធរអប្សរា រួមនឹងការដ្ឋានជួសជុលដែលទើបបានចាប់ផ្តើមកាលពីពេលថ្មីៗនេះ។

[ស្លាយ] ការងារដែលត្រូវធ្វើដែរនោះគឺការកំណត់ព្រំប្រទល់តំបន់ការពារដែលយើងបានអនុវត្តកន្លងរួចមកហើយជាមួយអាជ្ញាធរអប្សរា ដោយមានជំនួយហិរញ្ញវត្ថុពីស្ថានទូតអាមេរិក។ [ស្លាយ] ហើយត្រូវបង្កើតគម្រោងដែលធ្វើឲ្យប្រជាជនទទួលបានផលចំណូលមកពីប្រភពផ្សេងទៀត ដើម្បីជួយឲ្យពួកគេជៀសវាងការកាប់ព្រៃឈើនិងបំផ្លាញបរិស្ថាន។

[ស្លាយ] ចុងក្រោយ យើងគួរលើកឡើងអំពីឧបករណ៍ដែលមានឈ្មោះថា LiDAR នៅភ្នំគូលែន ដែលយើងខ្ញុំយល់ថាពិតជាស័ក្តិសម ដើម្បីស្រាវជ្រាវដឹងឲ្យកាន់តែច្បាស់អំពីរមណីយដ្ឋាននេះ។ វាគឺជាឧបករណ៍មួយដែលជួយឲ្យយើងស្វែងយល់បានយ៉ាងច្បាស់អំពីភាពសម្បូរបែបនៃសំណល់បុរាណវិទ្យា។ ឯកឧត្តម លោកជំទាវ ឃើញនៅក្នុងរូបនេះនូវរចនាសម្ព័ន្ធដែលបង្ហាញឲ្យឃើញដោយរូបថត LiDAR នៅឆ្នាំ២០១២ នៅលើផ្ទៃដី៣០គីឡូម៉ែត្រក្រឡា [ស្លាយ] ពណ៌បៃតងគឺរចនាសម្ព័ន្ធដែលយើងធ្លាប់ដឹងរួចមកហើយ ចំណែកឯពណ៌ក្រហមគឺរចនាសម្ព័ន្ធដែល

យើងទើបបានឃើញកាលពីពេលថ្មីៗនេះ ដោយសារ LiDAR។ វាគឺជាឧបករណ៍មួយដែលយើងចង់យកមកប្រើប្រាស់នៅក្នុងក្របខណ្ឌនៃបេសកកម្ម KALC លើកទី២ម្តងទៀត ប្រសិនបើយើងមានជំនួយហិរញ្ញវត្ថុគ្រប់គ្រាន់ដែលអាចធ្វើទៅបាន ដោយថតពីលើភ្នំទាំងមូលតែម្តង។ វាក៏ជាកិច្ចសហប្រតិបត្តិការមួយដែលយើងអាចផ្តួចផ្តើមធ្វើជាមួយសហការីចិនរបស់យើងដែលទើបបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយអាជ្ញាធរអប្សរាកាលពីពេលថ្មីៗនេះ។

[ស្លាយ] ឯកឧត្តម លោកជំទាវបានយល់ហើយ គណៈកម្មាធិការដែលបានរៀបចំឡើង គឺជាសំណាងមួយក្នុងសំណាងចុងក្រោយទាំងឡាយដែលអាចជួយស្រោចស្រង់អ្វីដែលនៅសេសសល់ ជាបេតិកភណ្ឌបរិស្ថាននៅភ្នំគូលែន។ ក្នុងរយៈពេល២ឆ្នាំខាងមុខទៀត ប្រហែលជាយឺតពេលហើយ។ ការពង្រីកឧទ្យានអង្គរបេតិកភណ្ឌពិភពលោកឲ្យទៅដល់ភ្នំគូលែននឹងក្លាយជាចំណោទបញ្ហាមួយដ៏ធំ ប្រសិនបើយើងមិនអាចស្រោចស្រង់បានទាន់ពេលវេលាទេនោះ។ យើងឃើញមានការគំរាមកំហែងទាំងនេះហើយ ការសិក្សាក៏បានធ្វើរួចហើយដែរ យើងខ្ញុំសង្ឃឹមថាពេលវេលាដែលត្រូវចាត់វិធានការនឹងមកដល់។ ដំណោះស្រាយពិតជាមាន យើងត្រូវអនុវត្តដំណោះស្រាយទាំងនោះ ដោយសម្របទៅតាមករណីពិសេសនៅភ្នំគូលែន។

ដូច្នេះខ្ញុំសូមអនុញ្ញាតអំពាវនាវសាជាថ្មីម្តងទៀតដល់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងដល់ស្ថាប័នអន្តរជាតិផ្សេងៗ និងបណ្តាប្រទេសដែលអាចផ្តល់ជំនួយ ដើម្បីឲ្យមានការបង្កើតពិតប្រាកដនូវគណៈកម្មាធិការនេះ ហើយឲ្យសមាជិកនៃគណៈកម្មាធិការមានធនធានសមស្រប និងសូមឲ្យគណៈកម្មាធិការបំពេញបេសកកម្មជាបន្ទាន់ក្នុងការអភិរក្សបេតិកភណ្ឌបុរាណវិទ្យា ជាពិសេសការពារព្រៃឈើនៅលើភ្នំគូលែន។ ភ្នំគូលែនគឺជាភ្នំមួយក្នុងចំណោមភ្នំជាទីសក្ការៈសំខាន់ៗជាងគេនៅកម្ពុជា វាជាសួតនិងប្រភពទឹកនៃឧទ្យានអង្គរ និងតំបន់អង្គរទាំងមូល។

[ស្លាយ] យើងខ្ញុំប្រាកដជានឹងមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដែលអាចផ្តល់ជាប្រឹក្សាដល់គណៈកម្មាធិការនេះ។

ខ្ញុំសូមថ្លែងអំណរគុណដល់ការយកចិត្តទុកដាក់ស្តាប់របស់ឯកឧត្តម លោកជំទាវទាំងអស់គ្នា ហើយខ្ញុំសូមផ្តល់វេទិកានេះជូនលោកស្រី សុវណ្ណា ហ្គោឡែត្ត មកពីអង្គការ Wildlife Alliance បន្តទៀត។

**លោកស្រី សុវណ្ណា ហ្គោឡែត្ត៖**
សូមគោរពឯកឧត្តមបណ្ឌិត សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជាតំណាងរាជរដ្ឋាភិបាលកម្ពុជា។

សូមគោរពបណ្ឌិត គីស័រ រ៉ាវ តំណាងអគ្គនាយិកាអង្គការយូណេស្កូ។
សូមគោរពលោក សែហ្ស ម៉ូស្ស៊ា ឯកអគ្គរដ្ឋទូតបារាំង។
សូមគោរពលោកសាស្ត្រាចារ្យនិងសហការីទាំងអស់ជាទីគោរព។

ខ្ញុំឈ្មោះ សុវណ្ណា ហ្គោទ្បែត្ត ខ្ញុំជាប្រធានអង្គការ Wildlife Alliance។ អង្គការរបស់ខ្ញុំមិនធ្វើការលើវិស័យបុរាណវិទ្យាទេ ប៉ុន្តែធ្វើការខាងការពារព្រៃឈើ អស់រយៈពេលជាង១៣ឆ្នាំមកហើយដែលយើងខ្ញុំធ្វើការដាំព្រៃឈើឡើងវិញនៅកម្ពុជា។ មូលហេតុដែលជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជាត្រឡប់មករកអង្គការ Wildlife Alliance វិញគឺដើម្បីធ្វើការសិក្សាវិទ្យាសាស្ត្រ ស្តីអំពីស្ថានភាពព្រៃឈើ និងផ្តល់ជូននូវដំណោះស្រាយដើម្បីស្រោចស្រង់ភ្នំគូលែន។ វិធីសាស្ត្ររបស់យើងគឺជាវិធីសាស្ត្រចុះផ្ទាល់ទៅដល់មូលដ្ឋាន វិធីសាស្ត្រនេះបានផ្តល់នូវលទ្ធផលជាក់ស្តែង និងមានការទទួលស្គាល់រួចមកហើយ។

[ស្លាយ] ផែនទីនេះចង្អុលបង្ហាញអ្វីដែលលោក ហ្សង់បាទីស្ត៍ ស៊ីវ៉ង់ស៍ ទើបនឹងបានពន្យល់ឯកឧត្តម លោកជំទាវ លោក លោកស្រី រួចមកហើយ អំពីការពឹងពាក់គ្នាទៅវិញទៅមករវាងភ្នំគូលែននិងឧទ្យានអង្គរទាំងមូល។ ការសិក្សាអំពីការកាប់ព្រៃឈើនៅភ្នំគូលែន និងផលប៉ះពាល់របស់វាទៅលើធនធានទឹកនៅក្នុងឧទ្យានអង្គរទាំងមូលត្រូវបានធ្វើរួចហើយយ៉ាងស៊ីជម្រៅដោយឯកឧត្តម ហង់ ពៅ អគ្គនាយករងអាជ្ញាធរអប្សរា។ យោងតាមទិន្នន័យរបស់លោកកាលពីឆ្នាំ២០១០ ស្ទឹងសៀមរាបដែលទទួលបន្ទុកផ្តល់ទឹកទៅក្នុងស្រទាប់ទឹកក្រោមដីនៅក្នុងឧទ្យានអង្គរទាំងមូលបានបាត់បង់បរិមាណទឹករបស់ខ្លួនប្រមាណជា៥០%។ ម្យ៉ាងវិញទៀត អ្នកប្រើប្រាស់ទឹកនៅក្នុងក្រុងមានប្រមាណជា២០ម៉ឺននាក់ រួមទាំងទេសចរនិងប្រជាជន ហើយការបូមទឹកប្រមាណជា៧៥%ចេញពីទឹកក្រោមដីផ្ទាល់គឺគ្មានច្បាប់ទម្លាប់គ្រប់គ្រងឡើយ។

ការសិក្សាដែលយើងខ្ញុំបានធ្វើឡើង គឺចាប់ផ្តើមពីថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៣។ យើងខ្ញុំបានធ្វើផែនទីមួយដោយប្រើប្រាស់រូបថតជាច្រើនជាង២២០០០សន្លឹក ដើម្បីកុំឲ្យខ្វះចន្លោះត្រង់កន្លែងណាមួយ។ [ស្លាយ] នេះគឺជារូបពណ៌ខ្មៅដែលនឹងបង្ហាញឯកឧត្តម លោកជំទាវឲ្យឃើញពីវិសាលភាពនៃការកាប់ព្រៃឈើ។ [ស្លាយ] យើងខ្ញុំបានថតរូបនៅលើផ្ទៃដីមួយហិកតាម្តងៗនៅលើភ្នំគូលែន។ នេះគឺជារូបភាពធំហើយខ្ញុំសូមបញ្ជាក់ថាការ៉េនីមួយៗតំណាងឲ្យផ្ទៃដី២៥ហិកតារ។ ខ្ញុំនឹងនិយាយត្រួសៗប៉ុណ្ណោះ។

[ស្លាយ] ព្រៃឈើបន្តិចបន្តួចនៅចំកណ្តាលនេះគឺជាតំបន់ការពារដែលគេបានកាប់អស់ជាច្រើនទៅហើយ។

[ស្លាយ] នៅកន្លែងនេះទៀត គឺជាតំបន់សហគមន៍ដែលមានការការពារ។

គេបានសួរខ្ញុំថាតើការកាប់ព្រៃឈើចុះអន់ខ្លះដែរឬទេ។ ចម្លើយគឺមិនអន់ទេ ម្យ៉ាងទៀតចាប់តាំងពីពេលបោះឆ្នោត រហូតមកដល់ពេលនេះ ការកាប់ព្រៃឈើកាន់តែមានទំហំធំឡើងទៀតផង។ ការកាប់ព្រៃឈើនេះជាអកុសលត្រូវបានបញ្ជាក់បន្ថែមដោយតួលេខ ពីព្រោះកាលពីខែមិនា ផ្ទៃព្រៃឈើនៅសល់យ៉ាងហោចត្រឹម២២% ប៉ុន្តែបច្ចុប្បន្ននេះ វានៅសល់តែ១៩%ប៉ុណ្ណោះ។

[ស្លាយ] ខ្ញុំសូមបង្ហាញរូបភាពនេះជូនឯកឧត្តម លោកជំទាវ មើល ពីព្រោះវាបង្ហាញនូវប្រភេទព្រៃឈើដែលមានស្លឹកខៀវគ្រប់រដូវ គេត្រូវដាំឈើប្រភេទនេះឡើងវិញ ដើម្បីរក្សាទឹកនៅផ្ទៃខាងលើ និងទឹកនៅក្នុងស្រទាប់ដីខាងក្រោម។ ខ្ញុំសូមបញ្ជាក់ថា មានតែព្រៃធម្មជាតិប៉ុណ្ណោះ ដែលអាចដើរតួនាទីរក្សាទឹកនេះបាន ការដាំដើមឈើតែមួយមុខមិនអាចគ្រប់គ្រងធារទឹកធម្មជាតិបានទេ។

[ស្លាយ] នេះគឺជាតួលេខ៖ នៅឆ្នាំ២០០២ គេសង្កេតឃើញមានការកាប់ព្រៃឈើ៨% នៅឆ្នាំ២០១០ មាន៤៤% និងនៅឆ្នាំ២០១៣ គេឃើញមានរហូតដល់៧៣%។ [ស្លាយ] ការពាក់ព័ន្ធជាមួយនឹងទឹកក្រោមដី គឺមានដូចតទៅនេះ៖ ខ្ញុំនឹងសាកល្បងបង្ហាញជូននូវភាពយន្តមួយដែលខ្ញុំសង្ឃឹមថាវានឹងដើរ។ ចំណុចសំខាន់មួយគឺថា ព្រៃឈើមិនអាចកាត់ផ្តាច់ជាផ្នែកៗបានទេ ព្រៃឈើត្រូវតែគ្របដណ្តប់ក្នុងលក្ខណៈជាប់ៗគ្នា។

ប្រសិនបើគ្មានការការពារណាមួយត្រូវបានចាត់ឡើងនៅតាមមូលដ្ឋានផ្ទាល់ទេ ធារទឹកនៅក្នុងស្ទឹងក៏នឹងថយចុះ ហើយបរិមាណទឹកក្រោមដីនឹងថយចុះដែរ តម្រូវការទឹករបស់ប្រជាជននឹងកើនឡើង ដែលយើងដឹងថាចំនួនប្រជាជននឹងកើតឡើងដល់៤០ម៉ឺននាក់នៅឆ្នាំ២០២០។ ផ្ទុយទៅវិញ កម្រិតទឹកក្នុងបឹងទន្លេសាបនឹងបន្តថយចុះដែរ។

[ស្លាយ] នេះគឺជាភាពយន្តមួយដែលខ្ញុំសូមបង្ហាញជូនឯកឧត្តម លោកជំទាវនៅពេលនេះ។ អង្គការ Wildlife Alliance មានគម្រោងជាក់ស្តែងមួយនៅនឹងមូលដ្ឋានផ្ទាល់ ដែលផ្តោតទៅលើបទពិសោធន៍របស់យើងខ្ញុំ ជាគម្រោងដែលយើងខ្ញុំដាក់ជូនភាគីពាក់ព័ន្ធទាំងអស់ ហើយខ្ញុំបានសុំឲ្យគេចែកជូនគម្រោងទាំងនេះនៅតាមកន្លែងមួយចំនួនរបស់ឯកឧត្តម លោកជំទាវ រួចហើយ។

[ស្លាយ] យើងខ្ញុំស្នើឡើងនូវកម្មវិធីមួយដែលមានរយៈពេល៥ឆ្នាំ វាជាគម្រោងមួយដែលយកគំរូតាមកម្មវិធីនៃការការពារដែលយើងខ្ញុំធ្លាប់បានអនុវត្តនៅតាមជួរភ្នំក្រវាញ។ យើងខ្ញុំមានបទពិសោធន៍រយៈពេល២០ឆ្នាំមកហើយក្នុងការអនុវត្តគំរូប្រភេទនេះនៅក្នុងតំបន់ការពារដែលចំណាយទឹកប្រាក់អស់៩,៥លានដុល្លារអាមេរិក។ ការងារនេះមិនទាន់រួមបញ្ចូលនូវការដាំព្រៃឈើឡើងវិញនោះទេ។ ប្រវត្តិនៃការលូតលាស់របស់ព្រៃឈើនៅភ្នំគូលែនពិតជាល្អយ៉ាងខ្លាំង។ [ស្លាយ] ព្រៃឈើដែលដុះនៅលើភ្នំនេះពិតជាក្រាស់ៗ។ អនុសាសន៍របស់យើងខ្ញុំគឺបន្តសម្រេចគោលដៅពីរៈ ទី១ ធ្វើឲ្យភ្នំគូលែនមានព្រៃឈើគ្របដណ្តប់ប្រមាណជា៩០%ឡើងវិញ និងទី២ ធ្វើឲ្យជារទឹកមានលក្ខណៈធម្មតាឡើងវិញនៅក្នុងឧទ្យានអង្គរទាំងមូល និងក្នុងក្រុងសៀមរាប។

សហគមន៍តែម្នាក់ឯងមិនអាចអនុវត្តកម្មវិធីនេះឲ្យបានល្អនោះទេ។ [ស្លាយ] នៅតាមមូលដ្ឋានផ្ទាល់ ត្រូវធ្វើយ៉ាងណាឲ្យច្បាប់ត្រូវបានអនុវត្តដើម្បីបញ្ចប់ការកាប់ព្រៃឈើដោយខុសច្បាប់ ទប់ស្កាត់ប្រជាជនពីក្រៅមករស់នៅ និងទប់ស្កាត់ការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម ដែលផ្តល់ដោយអាជ្ញាធរមូលដ្ឋាន និងចុងក្រោយបង្កើតមធ្យោបាយដើម្បីរស់សម្រាប់ប្រជាជនជាង១០០០គ្រួសារ ដែលរស់នៅតាមភូមិនានា ហើយឈ្មោះភូមិទាំងនេះមាននៅលើអេក្រង់នេះស្រាប់។ គេត្រូវចាត់ចែងក្នុងពេលជាមួយគ្នានោះឲ្យមានការអនុវត្តច្បាប់នៅតាមមូលដ្ឋានផង និងបង្កើនមធ្យោបាយរស់នៅរបស់ប្រជាជនផង។

ជាទូទៅគេគិតថា មធ្យោបាយមួយដែលជួយលើកស្ទួយសហគមន៍ហើយដែលផ្តោតតែទៅលើមធ្យោបាយសម្រាប់ឲ្យប្រជាជនអាចរស់បាននឹងដើរដោយស្វ័យប្រវត្តិ។ បទពិសោធន៍របស់យើងបានបង្ហាញថាវាមិនដូច្នោះទេ។ វិធីសាស្ត្រនោះ មិនជួយជំរុញនិងលើកទឹកចិត្តដល់ប្រជាជន មិនផ្លាស់ប្តូរអត្តចរិតរបស់ពួកគេទេ វាគ្រាន់តែជួយធ្វើឲ្យប្រជាជនក្នុងស្រុកបង្កើនប្រាក់ចំណូលសម្រាប់រស់ដោយមិនផ្លាស់ប្តូររបៀបរបបដាំដុះរបស់ពួកគេដែលគ្មានលក្ខណៈនិរន្តរភាព។ គំនិតគឺថា ត្រូវអនុវត្តច្បាប់ និងបង្កើនមធ្យោបាយសម្រាប់ជីវភាពរស់នៅរបស់ប្រជាជនក្នុងពេលតែមួយ។

ដូចដែលខ្ញុំបានលើកឡើងកន្លងរួចមកហើយ អស់រយៈពេល២០ឆ្នាំហើយដែលអង្គការ Wildlife Alliance ធ្វើការលើបញ្ហាទាំងនេះ ហើយមានកិច្ចការមួយដែលយើងធ្វើបានល្អ គឺការគ្រប់គ្រងវិបត្តិ គឺវិបត្តិព្រៃឈើ។ យើងខ្ញុំនឹងមានសេចក្តីរីករាយទៅអន្តរាគមន៍នៅភ្នំគូលែនដើម្បីជួយស្រោចស្រង់ប្រាង្គប្រាសាទអង្គរ។ យើងខ្ញុំគិតថា បើផ្អែកទៅលើទិន្នន័យដែលយើងខ្ញុំមាន គឺថាស្រទាប់ទឹកក្រោមដីដែលនៅក្រោមប្រាសាទអង្គរបានបាត់បង់ប្រមាណជា២ម៉ែត្រនៃទំហំរបស់វា ហើយនេះនឹងអាចធ្វើឲ្យគ្រឹះប្រាសាទមិននឹងននិងអាចស្រុតបាក់នៅថ្ងៃណាមួយមិនខាន។

យើងខ្ញុំមិនអាចធ្វើការនេះដោយជោគជ័យតែម្នាក់ឯងបាននោះទេ យើងខ្ញុំត្រូវការការគាំទ្រពីអ្នកទាំងអស់គ្នា ហើយយើងខ្ញុំសង្ឃឹមថានឹងទទួលបាននូវការគាំទ្រផ្នែកហិរញ្ញវត្ថុចាំបាច់ដើម្បីឲ្យគម្រោងនឹងបានប្រែក្លាយជាសកម្មភាពជាក់ស្តែង។ ចំណុចមួយក្នុងចំណោមចំណុចគន្លឹះនានានៃកម្មវិធីនេះ គឺការចុះអន្តរាគមន៍ឲ្យបានលឿន។ ដូចដែលលោក ហ្សង់បាទីស្ត៍ សីវ៉ង់ស៍ បានមានប្រសាសន៍រួចហើយ "យើងគ្មានសិទ្ធិនឹងបាត់បង់ពេលវេលាទៀតទេ"។ សូមអរគុណច្រើន។

**សហប្រធានបារាំង៖** សូមអរគុណលោកស្រី ហ្គោឡែត្ត និងលោក សីវ៉ង់ស៍។ នៅពេលនេះយើងមានពេល១០នាទីសម្រាប់ការពិភាក្សាពេញអង្គ។ ខ្ញុំសូមបញ្ជាក់ថា នៅពេលនេះ គឺម៉ោង៣និង២០នាទី មានន័យថា យើងយឺត ៤០នាទីទៅហើយ បើមើលក្នុងកម្មវិធីដែលបានចែកជូននោះ។ តើមានអ្នកណាចង់មានប្រសាសន៍អ្វីទេ? គ្មានទេ។ បើអញ្ចឹងយើងចំណេញពេល១០នាទីដែរនៅក្នុងរបៀបវារៈរបស់យើង។

ប្រសិនបើគ្មានបទអន្តរាគមន៍ណាទេនៅក្នុងដំណាក់កាលនេះ ខ្ញុំសូមស្នើឲ្យសមាជិករបស់គណៈកម្មាធិការរបស់យើងស្តាប់លោកសាស្ត្រាចារ្យ គួ ហ័រតុង ដែលនឹងបង្ហាញយើងអំពីគម្រោងតាមដានបរិស្ថាននៅក្នុងរមណីយដ្ឋានអង្គរ ជាគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយមជ្ឈមណ្ឌលអន្តរជាតិចិនស្តីពីបច្ចេកវិទ្យាលំហសម្រាប់បេតិកភណ្ឌធម្មជាតិនិងវប្បធម៌ ក្រោមការគាំទ្រពីអង្គការយូណេស្កូ។ លោកសាស្ត្រាចារ្យ សូមអញ្ជើញមានប្រសាសន៍។

## ៣. គម្រោងថ្មីៗ

### *៣.១. បទបង្ហាញដោយសាស្ត្រាចារ្យ គួ ហ័រតុង ស្តីអំពីគម្រោងតាមដានបរិស្ថាននៅក្នុងឧទ្យានអង្គរ ផ្តល់ហិរញ្ញប្បទានដោយមជ្ឈមណ្ឌលអន្តរជាតិបច្ចេកវិទ្យាលំហ សម្រាប់បេតិកភណ្ឌវប្បធម៌ និងធម្មជាតិ ហៅកាត់ថា HIST របស់ប្រទេសចិន គាំទ្រដោយអង្គការយូណេស្កូ*

សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី។
សូមគោរពភ្ញៀវកិត្តិយសទាំងអស់ លោក លោកស្រីជាទីគោរព។

[ស្លាយ] មជ្ឈមណ្ឌលអន្តរជាតិបច្ចេកវិទ្យាលំហ សម្រាប់បេតិកភណ្ឌធម្មជាតិនិងវប្បធម៌ ដែលហៅកាត់ថា HIST ត្រូវបានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០១១ និងជាមជ្ឈមណ្ឌលយូណេស្កូប្រភេទទី២លើកដំបូងដែលផ្តោតទៅ

លើសេវាកម្មបច្ចេកទេសសម្រាប់អង្គការយូណេស្កូនិងប្រទេសជាសមាជិករបស់ខ្លួន ដែលប្រើប្រាស់បច្ចេកវិទ្យាលំហនៅក្នុងរមណីយដ្ឋានបេតិកភណ្ឌពិភពលោក។ មជ្ឈមណ្ឌលនេះស្ថិតនៅក្នុងវិទ្យាស្ថាន រ៉ាដា និងផែនដីឌីជីថល ដែលហៅកាត់ថា RADI នៃសភាវិទ្យាសាស្ត្រចិន។

វិទ្យាស្ថាន RADI គឺជាវិទ្យាស្ថានមួយក្នុងចំណោមវិទ្យាស្ថានល្អៗពិភពលោកនៅក្នុងការសង្កេតភពផែនដី។ វិទ្យាស្ថាននេះ មានបុគ្គលិក៧០០នាក់និងនិស្សិត៥០០នាក់ ដែលទើបទទួលសញ្ញាប័ត្រ មានបរិក្ខារវិទ្យាសាស្ត្រផ្សេងៗ ព្រមទាំងមានស្ថានីយចំនួន៣សម្រាប់ទទួលសញ្ញាពីផ្កាយរណប និងមានផ្កាយរណបចំនួនពីរ ដែលមានបំពាក់បរិក្ខាររ៉ាដាចាប់ពីចម្ងាយ។

[ស្លាយ] ស្ថានីយទាំងបីសម្រាប់ទទួលសញ្ញាផ្កាយរណបអាចទទួលបាននូវព័ត៌មានដែលគ្របដណ្តប់លើ៧០%នៃដែនដីក្នុងទ្វីបអាស៊ី។ វិទ្យាស្ថាន RADI និង HIST បច្ចុប្បន្ននេះមានផ្កាយរណបចំនួនពីរដែលមានបំពាក់គ្រឿងបរិក្ខាររ៉ាដាចាប់ពីចម្ងាយ និងមានគម្រោងបង្ហោះផ្កាយរណបពីរទៀតនៅពេលដ៏ខ្លីខាងមុខ។

ខ្សែវីដេអូនេះនឹងបង្ហាញជូនឯកឧត្តម លោកជំទាវ អំពីវិទ្យាស្ថានរបស់យើងខ្ញុំ [បញ្ចាំងវីដេអូ] ។

គម្រោងរ៉ាដាចាប់ពីចម្ងាយដើម្បីតាមដានពិនិត្យមើលបរិស្ថាននៅក្នុងរមណីយដ្ឋានអង្គរ ដែលហៅកាត់ថា REAS ត្រូវបានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០១៣ និងជាគម្រោងផ្តល់ជំនួយហិរញ្ញវត្ថុដោយមជ្ឈមណ្ឌល HIST អាជ្ញាធរអប្សរា និងការិយាល័យអង្គការយូណេស្កូនៅភ្នំពេញ។

ខ្ញុំសូមរំលឹកអំពីប្រវត្តិនៃគម្រោងនេះ។ [ស្លាយ] នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ អនុស្សរណៈនៃការព្រមព្រៀងមួយត្រូវបានចុះហត្ថលេខារវាងអាជ្ញាធរអប្សរានៃព្រះរាជាណាចក្រកម្ពុជានិងមជ្ឈមណ្ឌល HIST នៃសាធារណរដ្ឋប្រជាមានិតចិន ដែលមានគោលបំណងពង្រឹងសមត្ថភាពរបស់អាជ្ញាធរក្នុងការអនុវត្តបច្ចេកវិទ្យាលំហក្នុងវិស័យនៃការអភិរក្សនិងការគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ និងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃតំបន់សៀមរាបអង្គរ។

[ស្លាយ] ភាគច្រើននៃគម្រោងដែលកំពុងអនុវត្តក្នុងពេលបច្ចុប្បន្ននៅក្នុងរមណីយដ្ឋានអង្គរគឺជាគម្រោងពាក់ព័ន្ធនឹងការជួសជុលនិងការការពារប្រាង្គប្រាសាទ។ ការតាមដានប្រកបដោយថាមភាពលើបរិស្ថាននិងផលប៉ះពាល់

របស់បរិស្ថាននៅក្នុងរមណីយដ្ឋានអង្គរ ពិតជាមានសារៈសំខាន់ដ៏ធំក្នុងការអភិរក្សនិងការអភិវឌ្ឍប្រកបដោយចីរភាពនៃឧទ្យានអង្គរ។ បច្ចេកវិទ្យាលំហអនុញ្ញាតឲ្យមានការអនុវត្តជាលក្ខណៈស្វ័យប្រវត្តិនូវការសិក្សាអំពីបរិស្ថានធម្មជាតិនៃរមណីយដ្ឋានទាំងមូល និងអន្តរកម្មរបស់មនុស្សនៅក្នុងបរិស្ថានអង្គរដដែលនេះ ដែលមានផ្ទៃក្រឡា៤០០គីឡូម៉ែត្រក្រឡា និងក្នុងទីជុំវិញឧទ្យាន ដែលមានទំហំ៥០០០គីឡូម៉ែត្រក្រឡា។

រាជរដ្ឋាភិបាលកម្ពុជានិងអាជ្ញាធរអប្សរាបានបង្ហាញនូវចំណាប់អារម្មណ៍ដ៏ធំនៅក្នុងការប្រើប្រាស់ដោយស្វ័យប្រវត្តិនូវវិទ្យាសាស្ត្ររ៉ាដាចាប់ពីចម្ងាយសម្រាប់ការស្រាវជ្រាវនៅអង្គរ។ ឯកឧត្តមបណ្ឌិត សុខ អាន បានផ្តល់នូវការគាំទ្រយ៉ាងពេញទំហឹងទៅលើគម្រោងកិច្ចសហប្រតិបត្តិការនេះនៅពេលដែលឯកឧត្តមបានជួបគណៈប្រតិភូរបស់វិទ្យាស្ថាន HIST / RADI នៅភ្នំពេញកាលពីខែមិថុនាកន្លងទៅ។

[ស្លាយ] មជ្ឈមណ្ឌល HIST និងអាជ្ញាធរអប្សរាបានចុះទៅពិនិត្យនៅតាមមូលដ្ឋានរួមគ្នាកាលពីខែមិថុនា និងខែតុលាកន្លងទៅ។ គម្រោងនេះមានគោលបំណងបង្កើតយន្តការតាមដាននៅក្នុងរមណីយដ្ឋានអង្គរនិងនៅក្នុងទីជុំវិញ ដោយប្រើប្រាស់បច្ចេកវិទ្យាលំហ ដើម្បីស្វែងយល់ឲ្យបានកាន់តែប្រសើរឡើងនូវទំនាក់ទំនងរបស់វា។

គម្រោងនេះត្រូវបានបែងចែកដូចតទៅនេះ៖ ការគ្រប់គ្រងបរិស្ថាននៃទេសភាពអង្គរ ដែលរួមបញ្ចូលនូវការតាមដានប្រកបដោយថាមភាពលើភ្នំគូលែនដែលស្ថិតនៅខាងជើងឆៀងខាងកើតនៃក្រុងសៀមរាប និងការរៀបរយការតាំងទីរបស់ប្រជាជននៅជុំវិញរមណីយដ្ឋានអង្គរ ការគ្រប់គ្រងធនធានទឹក និងការបង្កើតឡើងវិញនូវប្រព័ន្ធធារាសាស្ត្របុរាណដោយប្រើប្រាស់រូបភាពផ្កាយរណបអុបទិក និងរ៉ាដាដែលមានលក្ខណៈសំយោគបើកចំហហៅកាត់ថាSAR ការប្រើប្រាស់កម្មវិធីកុំព្យូទ័រ SAR ដើម្បីត្រួតពិនិត្យការស្រុតចុះរបស់ដី និងការគំរាមកំហែងចំពោះប្រាង្គប្រាសាទអង្គរ ការបង្កើតឡើងវិញនូវបណ្តុំទិន្នន័យលំហស្តីអំពីរមណីយដ្ឋានអង្គរ និងការពង្រឹងសមត្ថភាព។

[ស្លាយ] តើយើងកំពុងស្ថិតនៅក្នុងស្ថានភាពណានៅពេលនេះចំពោះការផ្លាស់ប្តូរនៃការតាំងទីលំនៅស្ថាន និងការប្រើប្រាស់ដី? តំបន់ក្រុងត្រូវបានពង្រីកជាប់ជាប្រចាំហើយផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើមានសភាពមិនស្ថិតស្ថេរ តំបន់សំណើមបង្ហាញនូវការប្រែប្រួលទៅតាមរដូវ។

[ស្លាយ] ការប្រែប្រួលដែលគេសង្កេតឃើញនៅក្នុងក្រុងសៀមរាបបាននាំឲ្យយើងធ្វើសេចក្តីសន្និដ្ឋានដូចតទៅ

នេះ៖ នគរូបនីយកម្មមានល្បឿនលឿនខ្លាំងចាប់តាំងពីឆ្នាំ២០០០មក ខណៈដែលនៅឆ្នាំ១៩៨៥ គេពុំឃើញមានតំបន់ក្រុងទាល់តែសោះ (រូបភាពថតចម្លង) និងតំបន់ក្រុងបានជ្រៀតទៅលើដីកសិកម្មឬក៏ដីដែលមានព្រៃឈើដែលត្រូវគេកាប់ចេញ។

ការវិភាគអំពីការប្រែប្រួលនៃផ្ទៃដីដែលគ្របដណ្ដប់ដោយព្រៃឈើ៖ [ស្លាយ] សេចក្ដីសន្និដ្ឋានគឺមានដូចតទៅនេះ៖ តំបន់ដែលគ្របដណ្ដប់ដោយព្រៃឈើបានបាត់បង់អស់៥៩៣,២គីឡូម៉ែត្រក្រឡា (ស្មើនឹង១៨% នៃផ្ទៃដីដែលមានព្រៃឈើគ្របដណ្ដប់សរុប) ក្នុងរយៈពេល៣០ឆ្នាំ។ ការបាត់បង់នេះ សំខាន់គឺបណ្ដាលមកពីការប្រើប្រាស់ដីទាំងនេះ សម្រាប់ធ្វើកសិកម្មនិងចិញ្ចឹមសត្វ។

[ស្លាយ] ការវិភាគអំពីទឹកនៅលើផ្ទៃដីបានបង្ហាញនូវការប្រែប្រួលទៅតាមរដូវ រដូវវស្សានាំមកឲ្យមានទឹកជំនន់ដែលពេលខ្លះធ្វើឲ្យមានការខូចខាតធ្ងន់ធ្ងរ។ យើងបានប្រើប្រាស់ផ្កាយរណបនៅលើផែនដីដែលហៅកាត់ថា TM ឬ SPOT5 ដែលជាគំរូផ្កាយរណបមានប្រព័ន្ធឌីជីថល និងបណ្ដាឯកសារផ្សេងទៀតដែលយើងមាន។ លទ្ធផលបានបង្ហាញនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងផ្លូវទឹក ផ្លូវថ្នល់ និងការតាំងទីរស់នៅរបស់ប្រជាជន។

[ស្លាយ] ការត្រួតពិនិត្យលើដីស្រុត៖ យើងខ្ញុំបានវិភាគទៅលើដីចំនួន៤២កន្លែងដោយប្រើប្រព័ន្ធ SRA-X និងប្រព័ន្ធ SAR កាលពីខែកុម្ភៈ ឆ្នាំ២០១១ ដល់ខែកក្កដា ឆ្នាំ២០១៣។ យើងសង្កេតឃើញថាមានបន្លាស់ទីពី -៥០ ទៅ+១២មិល្លីម៉ែត្រក្នុងមួយឆ្នាំ។ តំបន់ដែលប៉ះពាល់ខ្លាំងជាងគេដោយការស្រុតដីនេះ គឺនៅប្រាសាទភ្នំបាខែង និងតំបន់ជិតៗនោះដែលមានសញ្ញារង្វង់ពណ៌ស។

[ស្លាយ] ទិន្នន័យលំហ៖ យើងប្រើប្រាស់ផ្កាយរណបបង្ហោះទៅក្នុងលំហ និងទិន្នន័យ LiDAR ដែលថតយករូបភាពដី ព្រមទាំងរូបថតនិងខ្សែវីដេអូផ្សេងៗ។ល។ ទិន្នន័យដែលបានដាក់បញ្ចូលនិងការគ្រប់គ្រងពហុលំហដើម្បីជានាការត្រួតពិនិត្យមួយប្រកបដោយថាមភាពលើបរិស្ថាន ការគ្រប់គ្រង និងការការពាររបស់វា។

[ស្លាយ] ការពង្រឹងសមត្ថភាពគឺជាបេសកកម្មមួយក្នុងចំណោមបេសកកម្មសំខាន់ៗរបស់មជ្ឈមណ្ឌល HIST។ អ្នកជំនាញរបស់អាជ្ញាធរអប្សរាបានទៅទទួលការបណ្ដុះបណ្ដាលនៅមជ្ឈមណ្ឌល HIST និងបានផ្លាស់ប្ដូរបទពិសោធន៍ជាមួយសហការីរបស់ពួកគេវិញក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ។

[ស្លាយ] គម្រោងផ្សេងៗសម្រាប់ការស្រាវជ្រាវ៖
- ប្រព័ន្ធតាមដានប្រកបដោយថាមភាពសម្រាប់ឧទ្យានអង្គរ និងតំបន់ជុំវិញអង្គរ។
- ផលប៉ះពាល់ផ្នែកបរិស្ថាន និងការត្រួតពិនិត្យចលករសំខាន់ៗនៃការផ្លាស់ប្តូរ។
- ប្រព័ន្ធវិភាគទិន្នន័យលំហានិងការសង្កេតមើលដោយប្រើរូបភាព 3D។
[ស្លាយ] ការផ្លាស់ប្តូរគ្នាជាមួយសាកលវិទ្យាល័យ៖
- វគ្គបណ្តុះបណ្តាលអន្តរជាតិស្តីអំពីបច្ចេកវិទ្យាលំហរ ដែលអនុវត្តនៅរមណីយដ្ឋានអង្គរ។
- ការប្រជុំបច្ចេកទេស
[ស្លាយ] ការពង្រឹងសមត្ថភាព៖
- ការបណ្តុះបណ្តាល
- បដិសណ្ឋារកិច្ចអ្នកជំនាញនិងអ្នករៀនថ្នាក់បណ្ឌិត
- ស្ថានីយផ្កាយរណបបែបអ៊ីនធឺណិត
សូមអរគុណ។

សហប្រធានជប៉ុន៖ សូមអរគុណលោកសាស្ត្រាចារ្យ គួ ហ័រតុង។ សូមឈានចូលដល់បទបង្ហាញជាបន្តទៀត។ ខ្ញុំសូមផ្តល់វេទិកានេះជូនលោក រស់ បូរ៉ាត់ អគ្គនាយករងអាជ្ញាធរអប្សរា។

## ៣.២. បទបង្ហាញដោយឯកឧត្តម រស់ បូរ៉ាត់ អគ្គនាយករងអាជ្ញាធរអប្សរា ស្តីអំពីគម្រោងជួសជុលប្រាសាទព្រះពិធូរ និងប្រាសាទអង្គរវត្ត

សូមគោរពសហប្រធាន។
សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី។
សូមគោរពសហការី លោក លោកស្រីជាទីគោរព។

ជាដំបូង មុននឹងឈានដល់ការចុះហត្ថលេខាជាផ្លូវការលើគម្រោងក្នុងពេលឆាប់ៗនេះ ខ្ញុំសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលជប៉ុនចំពោះអំណោយជាគ្រឿងបរិក្ខារធ្ងន់ៗ និងសម្ភារៈផ្សេងៗសម្រាប់ការងារជួសជុលប្រាសាទអង្គរ។

ឯកឧត្តមសហប្រធាន ខ្ញុំមានកិត្តិយសសូមបង្ហាញជូនឯកឧត្តមនូវគម្រោងថ្មីៗចំនួនពីរ ដែលជាកិច្ចសហប្រតិបត្តិការនៅអង្គរ។ គម្រោងទី១ គឺកិច្ចសហប្រតិបត្តិការរវាងជប៉ុននិងកម្ពុជា រីឯគម្រោងទី២គឺកិច្ចសហប្រតិបត្តិការរវាងកូរ៉េនិងកម្ពុជា។ កិច្ចសហប្រតិបត្តិការជាមួយកូរ៉េនេះ ធ្វើឲ្យចំនួនប្រទេសដែលធ្វើកិច្ចការនៅក្នុងតំបន់អង្គរឡើងដល់ចំនួន១៧។ វាជាការល្អដែលគួររំលឹកថា ទេសភាពអង្គរពោរពេញទៅដោយព្រៃឈើដែលមានលក្ខណៈល្អឯក ព្រមទាំងទឹក ប្រាង្គប្រាសាទ រួមទាំងមានមានប្រជាជនរស់នៅ ដែលធ្វើឲ្យទេសភាពនេះមានលក្ខណៈពិសេស មានន័យថាបរិស្ថានរបស់វាល្អដែលគួរត្រូវអភិរក្ស។

គម្រោងថ្មីមួយនៃកិច្ចសហប្រតិបត្តិការរវាងជប៉ុននិងកម្ពុជា គឺគម្រោងជួសជុលស្ពានហាលចូលប្រាសាទអង្គរវត្ត ដែលជាគម្រោងត្រូវបានដាក់ជូនប្រទេសជប៉ុនសុំជំនួយហិរញ្ញវត្ថុ។

ខ្ញុំសូមចាប់ផ្តើមនិយាយអំពីគម្រោងនេះមុន ដែលពាក់ព័ន្ធនឹងស្ពានហាលខាងលិចរបស់ប្រាសាទអង្គរវត្ត។ ស្ពានហាលនេះអនុញ្ញាតឲ្យគេដើរឆ្លងកសិណទឹកដែលមានប្រវែង១៩០ម៉ែត្រ និងជាស្ពានហាលដែលគេកសាងឡើងជិតមួយសតវត្សក្រោយពីប្រាសាទត្រូវបានសាងសង់រួច។ គម្រោងនេះជាគម្រោងមួយដែលបន្តពីគម្រោងមុន មានន័យថា ដំណាក់កាលថ្មីទាំងពីរនឹងចាប់ផ្តើមប្រតិបត្តិការជាក់ស្តែង នៅឆ្នាំ២០១៤ ហើយគម្រោងគ្រោងនឹងបញ្ចប់ការងារជួសជុលនេះនៅឆ្នាំ២០១៩។ ដំណាក់កាលទី១ ត្រូវបានសម្ពោធបើកការដ្ឋាន នៅឆ្នាំ២០០៧ ហើយដំណាក់កាលថ្មីនឹងត្រូវអនុវត្តដោយសកលវិទ្យាល័យ សូហ្វៀ និងអាជ្ញាធរអប្សរា។

[ស្លាយ] នេះគឺជាស្ថានភាពដែលឯកឧត្តម លោកជំទាវ ស្គាល់នៅពេលបច្ចុប្បន្ននេះនៅអង្គរវត្ត គឺស្ថានភាពស្ពានហាលនិងគម្រោងដែលខ្ញុំកំពុងនិយាយនេះ។ ការងារផ្សេងៗដែលបង្ហាញជូននៅក្នុងរូបថតនេះគឺឯកឧត្តម លោកជំទាវបានឃើញនៅក្នុងដំណាក់កាលទី១ ដែលពាក់ព័ន្ធនឹងផ្នែកខាងជើងទាំងមូល ពាក់កណ្តាលខាងកើត នៃស្ពានហាល ចំណែកឯដំណាក់កាលទី២ ដែលនឹងចាប់ផ្តើមនៅពេលខាងមុខនេះ ពាក់ព័ន្ធនឹងពាក់កណ្តាលខាងជើងនៃផ្នែកខាងលិចរបស់ស្ពានហាល បន្ទាប់មកផ្នែកដែលនៅខាងមុខនេះនឹងជាផ្នែកនៅក្នុងដំណាក់កាលចុងក្រោយ។

ខ្ញុំសូមអនុញ្ញាតរំលឹកអំពីប្រវត្តិរបស់វាត្រួសៗ។ [ស្លាយ] នៅក្នុងរូបថតដែលគេបានថតកាលពីខែតុលាឆ្នាំ១៩៥២ នេះ ឯកឧត្តម លោកជំទាវ ឃើញថា មានការបាក់ស្រុតជាច្រើន។ នៅពេលនោះគេក៏បានជួសជុលភ្លាមៗដែរ ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៥៦។ [ស្លាយ] រូបនេះបង្ហាញជូនឯកឧត្តម លោកជំទាវ នូវរូបភាពស្ពានហាលទាំងមូល

ដែលមានការបែងចែកជាផ្នែកៗទៅតាមការងារជួសជុលផ្សេងៗ។ ឯកឧត្តម លោកជំទាវ ឃើញថាផ្នែកនៃផ្ទៃខាងលើត្រូវបានជួសជុលដោយសាលាបារាំងចុងបូព៌ាប្រទេស ពីឆ្នាំ១៩៤៩ ដល់ឆ្នាំ១៩៦៤ បន្ទាប់មកផ្នែកនៅពាក់កណ្តាលខាងត្បូងត្រូវបានជួសជុលដោយសាលាបារាំងចុងបូព៌ាប្រទេសដែរ ហើយចំណែកឯផ្នែកខាងជើងទាំងអស់នេះត្រូវបានជួសជុលដោយសកលវិទ្យាល័យ សូហ្វៀ។ [ស្លាយ] ការងារជួសជុលគឺចាំបាច់ត្រូវធ្វើឡើងបន្ទាប់ពីមានការបាក់ស្រុតអស់ប្រវែង៤៥ម៉ែត្រ ដូចដែលរូបភាពកាត់ទទឹងនេះបង្ហាញឲ្យឃើញស្រាប់។ ឯកឧត្តម លោកជំទាវ ឃើញខ្សែបន្ទាត់នេះចង្អុលបង្ហាញពំនូកដីដែលស្រុតចុះ ហើយដែលគេប្រើដើម្បីចាក់បញ្ចូលទៅក្នុងរចនាសម្ព័ន្ធខាងក្នុងសម្រាប់ទប់ស្ពានហាល។ គេឃើញមានចន្លោះប្រហោង ហើយឯកឧត្តម លោកជំទាវ ឃើញថាផ្នែកនៃជញ្ជាំងខាងក្រៅនិងថ្មក្រាលនៅតាមផ្លូវដើរខាងលើ មិនអាចទប់ជាប់ឡើយ ដោយសារមានទឹកភ្លៀងហូរកាត់ ជ្រោះចូលតាមចន្លោះប្រហោងទាំងនោះ។

[ស្លាយ] រូបភាពដែលឯកឧត្តម លោកជំទាវ ឃើញនៅពេលនេះ គឺជារូបភាពរបស់សាលាបារាំងចុងបូព៌ាប្រទេសអនុញ្ញាតឲ្យឯកឧត្តម លោកជំទាវឃើញផ្នែកដែលបាក់ស្រុតចុះទៅ ហើយបង្កើតបានជាគំនរដែលបានស្រុតចុះយ៉ាងខ្លាំង។

[ស្លាយ] ការងារជួសជុលបានចាប់ផ្តើមឡើងវិញនៅឆ្នាំ១៩៥៤។ គេបានធ្វើគ្រឹះជាបេតុងមួយផ្នែក ដូចមាននៅក្នុងរូបនេះ ហើយកសិណជ្រាំងខាងក្រៅត្រូវបានជួសជុលដែរ។ [ស្លាយ] ជាថ្មីម្តងទៀត រូបថតទាំងនេះហាក់ដូចជាបង្ហាញថា ការងារត្រូវបានគេធ្វើទាំងយប់ទាំងថ្ងៃ ពីព្រោះឯកឧត្តម លោកជំទាវ ឃើញបង្គោលតូចទាំងនេះដែលបញ្ជាក់ថាជាអំពូលភ្លើងបំភ្លឺផ្លូវនៅពេលយប់សម្រាប់ឲ្យកម្មករធ្វើការ។

[ស្លាយ] ផ្នែកនេះ ពីឆ្នាំ១៩៦០ដល់ឆ្នាំ១៩៦៦ ជាកំណាត់ដែលជួសជុលដោយសាលាបារាំងចុងបូព៌ាប្រទេស។ រូបភាពកាត់ទទឹងបង្ហាញថា គេបានប្រើបេតុង បន្ទាប់មកចាក់ដីបំពេញ និងក្រាលថ្មពីលើ។ ទឹកមួយផ្នែកបានហូរកាត់តាមចង្អូរនេះដែលហូរចាក់ទៅខាងក្រៅ។

[ស្លាយ] នៅពេលដែលសាកលវិទ្យាល័យ សូហ្វៀ បានចាប់ផ្តើមដំណាក់កាលទី១នៃការងារជួសជុល ដំបូងយើងឃើញមានការវិភាគ មានន័យថា ធ្វើសម្រង់ គំនូរ ប្លង់ រូបភាព និងឯកសារ ព្រមទាំងការងារច្រើនផ្សេងទៀតមុននឹងធ្វើការជួសជុលជាក់ស្តែង។ នៅឆ្នាំ១៩៩៨ គេឃើញមានថ្មជាច្រើនដុំដែលគេយកមកដាក់តម្រៀបលើគ្នានៅសងខាងស្ពាន [ស្លាយ] នៅលើរូបនេះ មួយផ្នែកធំនៃកសិណត្រូវបានគេប្រើប្រាស់ដើម្បីធ្វើជាផ្លូវសម្រាប់ការដ្ឋាន។

[ស្លាយ] រូបនេះបង្ហាញថា  មានការងារបណ្តុះបណ្តាលអំពីការងារជួសជុលថ្ម ជាពិសេសគឺការងារបណ្តុះបណ្តាលបុរាណវិទូ វិស្វករ ស្ថាបត្យករវ័យក្មេងនៅនឹងការដ្ឋានផ្ទាល់។ ខ្ញុំសូមទាញចំណាប់អារម្មណ៍ឯកឧត្តម លោកជំទាវទៅលើការដែលថាសកលវិទ្យាល័យ សូហ្វៀ ក៏មានគោលដៅបង្ហាត់បង្រៀនអប់រំនិងបណ្តុះបណ្តាលយុវជនដែរ។ លោកស្រី  អាបេ  មកពីសកលវិទ្យាល័យ សូហ្វៀ បាននិយាយកាលពីម្សិលមិញអំពីចំនួនអ្នកជំនាញកម្ពុជាដែលបានទទួលការបណ្តុះបណ្តាលនៅក្នុងកម្រិតខ្ពស់។ រហូតមកទល់ពេលនេះ យើងមានអ្នកជំនាញវ័យក្មេងខ្មែរដែលទទួលការបណ្តុះបណ្តាលចំនួន១៦នាក់ក្នុងកម្រិតបរិញ្ញាប័ត្រជាន់ខ្ពស់ និង៧នាក់ក្នុងកម្រិតបណ្ឌិត។ ហើយបើតាមខ្ញុំដឹង គ្រប់គ្នា បន្ទាប់ពីបានបញ្ចប់ការសិក្សារបស់ពួកគេរួចមក បានត្រឡប់មកកម្ពុជាវិញ នៅខេត្តសៀមរាបដើម្បីជួយពង្រឹងការងារអាជ្ញាធរអប្សរានិងបម្រើឲ្យវិស័យបេតិកភណ្ឌ។

[ស្លាយ] ផ្នែកដែលខ្ញុំបង្ហាញជូនឯកឧត្តម លោកជំទាវនេះ      ឆ្លុះបញ្ចាំងអំពីភាពទន់ខ្សោយនៃជញ្ជាំងដោយសារសម្ពាធដុំថ្មទាំងនេះ ដែលបង្កើតបានជារចនាសម្ព័ន្ធមួយ។ ដូច្នេះ   តើដំណាក់កាលទី១នៃការងារបានប្រព្រឹត្តទៅយ៉ាងដូចម្តេច? សកលវិទ្យាល័យ សូហ្វៀ បានចាប់ផ្តើមដោយចាក់ដីបំពេញប្រហោង     បន្ទាប់មកបង្ហាប់ដីទាំងនោះដោយដៃ ទន្ទឹមនឹងគ្នានោះ   ពួកគេបានពង្រឹងជញ្ជាំងខាងក្រៅដោយដាក់ថ្មទល់ ដែលអនុញ្ញាតឲ្យគេពង្រឹងជញ្ជាំងនោះកាន់តែមាំឡើង ពីព្រោះជញ្ជាំងនោះហាក់ដូចជាត្រូវបានរៀបឡើងនៅលើគ្រឹះថ្មដែលមិនសូវមាំ។

ការងារនៅក្នុងដំណាក់កាលទី១ គឺសំដៅទៅពង្រឹងដីឥដ្ឋដែលមាននៅក្នុងរចនាសម្ព័ន្ធនៃស្ពានហាល   និងពង្រឹងជញ្ជាំងខាងក្រៅតាមរយៈជញ្ជាំងថ្មទប់ពីខាងក្រៅ ដូចដែលខ្ញុំបាននិយាយអម្បាញ់មិញនេះរួចហើយ។ ទឹកភ្លៀងហូរចាក់តាមធម្មតាទៅខាងក្នុងកសិណ។ ការរំលឹកឡើងវិញអំពីការងារដែលសម្រេចបាននេះ នាំជាប្រយោជន៍យ៉ាងច្រើនដល់យើងសម្រាប់ដំណាក់កាលទី២ និងដំណាក់កាលទី៣ទៅថ្ងៃអនាគត។ វិធីសាស្ត្រក្នុងការជួសជុលគឺដូចគ្នា ប៉ុន្តែយើងត្រូវវិភាគ និងមើល ត្រូវអភិរក្សឲ្យបានច្រើនបំផុត និងធ្វើការប្រុងប្រយ័ត្ន រុះរើតែកន្លែងណាដែលចាំបាច់ប៉ុណ្ណោះ។ ខ្ញុំជឿថាខ្ញុំមានពេលវេលាតិចណាស់សម្រាប់និយាយអំពីផ្នែកនេះនៃស្ពានហាល។

[ស្លាយ] ខ្ញុំចង់បញ្ជាក់ជូនឯកឧត្តម លោកជំទាវ ថា ការងារដំណាក់កាលទី១ត្រូវបានបញ្ចប់ជាស្ថាពរ នៅថ្ងៃទី៣ ខែវិច្ឆិកា  ឆ្នាំ២០០៧។ [ស្លាយ] នេះជារូបភាពនៃផ្នែកដែលពាក់ព័ន្ធនៅក្នុងដំណាក់កាលទី២  និងដំណាក់កាលទី៣។ អ្វីដែលខ្ញុំបានជម្រាបជូននោះ គឺថា យើងត្រូវធ្វើការប្រុងប្រយ័ត្ន មិនត្រូវរុះរើទាំងអស់នោះទេ។ ដំបូងយើងត្រូវធ្វើការវិភាគរកមូលហេតុ រួចទើបធ្វើអន្តរាគមន៍ត្រង់កន្លែងដែលចាំបាច់ប៉ុណ្ណោះ។

[ស្លាយ] រូបភាពនេះសម្រាប់ខ្ញុំពិតជាសំខាន់ខ្លាំងណាស់ ពីព្រោះការដ្ឋានជួសជុលដែលនឹងត្រូវរៀបចំឡើងចាំបាច់ត្រូវធ្វើការដែលមានវត្តមានទឹកជាប់ជាប្រចាំ។ [ស្លាយ] នេះគឺជារូបស្ពានហាលស្របតាមបណ្តោយជញ្ជាំងខាងក្រៅដែលត្រូវស្តារឡើងវិញ ប៉ុន្តែនៅឆ្នាំ២០០២ ហើយបច្ចុប្បន្ននេះក៏ដូចគ្នាទៀត គឺទឹកនៅតែមានកម្រិតខ្ពស់១ម៉ែត្រពីលើកម្រិតនៃការដ្ឋាន។ ក្នុងពេលដែលយើងនឹងចាប់ផ្តើមធ្វើការ យើងត្រូវធ្វើយ៉ាងណាឲ្យទឹកអាចស្រកចុះយ៉ាងតិចក៏១ម៉ែត្រនៅពីក្រោមកម្រិតការដ្ឋាន។

[ស្លាយ] នេះគឺជារូបថតកាលពីខែមេសា ឆ្នាំ២០០៤ ហើយនេះគឺជារូបថតនៅឆ្នាំ២០១៣៖ គេចាំបាច់ត្រូវសិក្សាអំពីវង់ទស្សនាឡើងវិញនៅក្នុងប្រាសាទដើម្បីដោះស្រាយបញ្ហានេះ។ នៅពេលបច្ចុប្បន្ននេះ នៅឆ្នាំ២០១៣ យើងមិនអាចបិទស្ពានហាលមួយកំណាត់បាន ដូចកាលពីឆ្នាំ២០០៤នោះទេ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះផ្នែកទី១នៃបទបង្ហាញស្តីអំពីគម្រោងជួសជុលស្ពានហាលប្រាសាទអង្គរវត្ត។

នៅពេលនេះខ្ញុំ សូមឈានចូលដល់គម្រោង កិច្ចសហប្រតិបត្តិការ ជាមួយសាធារណរដ្ឋកូរ៉េ ដែលជាគម្រោងជួសជុលប្រាសាទព្រះពិធូរ។ តើប្រាសាទព្រះពិធូរនៅកន្លែងណា?

[ស្លាយ] ឯកឧត្តម លោកជំទាវ កន្លែងនេះគឺព្រះបរមរាជវាំង ហើយនេះគឺជារូបថត LiDAR ដែលបង្ហាញអំពីទីតាំងរបស់ប្រាសាទព្រះពិធូរក្នុងផែនទីទូទៅ។ ឯកឧត្តម លោកជំទាវ ឃើញហើយ រូបថតពីលើអាកាសដែលបង្ហាញនូវបរិយាកាសនិងបរិស្ថាននៃទីកន្លែងនេះ។ អម្បាញ់មិញខ្ញុំបានជម្រាបជូនថា មានប្រទេសចំនួន១៧ និងស្ថាប័នចំនួន២៨ដែលធ្វើការនៅក្នុងរមណីយដ្ឋានអង្គរ។ គម្រោងទាំងអស់ប្រមាណជា៧០ដែលបានបញ្ចប់ឬកំពុងបន្តអនុវត្តនៅអង្គរ។

[ស្លាយ] ជាថ្មីម្តងទៀត នេះគឺជាប្រាសាទព្រះពិធូរនៅក្នុងផែនទី ហើយខ្ញុំសូមទាញចំណាប់អារម្មណ៍ឯកឧត្តមលោកជំទាវទៅលើការដែលថា នៅជុំវិញព្រះបរមរាជវាំងនេះ យើងឃើញមានទង់ជាតិបារាំង ជប៉ុន ឥណ្ឌូណេស៊ីសាធារណរដ្ឋឆែក ហើយពេលនេះមានទង់ជាតិកូរ៉េមួយទៀតដែលមកបំពេញបន្ថែមលើបណ្តាទង់ជាតិទាំងនេះ។

[ស្លាយ] នេះគឺប្រាសាទព្រះពិធូរ។ ខ្ញុំនឹងសាកល្បងរៀបរាប់ជូនឯកឧត្តម លោកជំទាវបន្តិច ពីព្រោះមានមនុស្សតិចណាស់ដែលស្គាល់ប្រាសាទព្រះពិធូរ។ ភ្ញៀវដែលមកទស្សនាមិនស្គាល់ប្រាសាទព្រះពិធូរទេ។ ពេលខ្លះ គេដើរ

កាត់មុខប្រាសាទនេះហើយ មិនទាំងចាប់អារម្មណ៍ មិនឈប់មើលទៀតផង។ ប្រាសាទនេះត្រូវបានសាងសង់ឡើងនៅសតវត្សទី១២ និងសតវត្សទី១៣។ វាមានរចនាបថដូចប្រាសាទអង្គរវត្តផង ក្រោយបាយ័នផង និងត្រូវបានកសាងឡើងក្រោមរជ្ជកាលព្រះបាទសុរិយវរ្ម័នទី២ និងជ័យវរ្ម័នទី៨។ ទីតាំងនេះដែលលោក ដៀវ តាខ្វាន់ បានរំលឹកឡើងវិញនៅចុងសតវត្សទី១៣ មានតាំងទង់ជាតិជាច្រើនដូចដែលខ្ញុំបានជម្រាបជូនអម្បាញ់មិញនេះរួចហើយ។ ទង់ជាតិចុងក្រោយនេះ គឺជាទង់ជាតិកូរ៉េដែលមានទីតាំងនៅត្រង់ជ្រុងខាងជើងឆៀងខាងលិច។

ក្រុមប្រាសាទព្រះពិធូរ មានប្រាសាទទាំងអស់ចំនួន៥ ដែលស្ថិតនៅកប់បាត់នៅក្នុងព្រៃដ៏ទ្រុបទ្រុល ប្រាសាទទាំងអស់ត្រូវបានដាក់ឈ្មោះទៅតាមអក្សរ។ ប្រាសាទពីរនៅក្នុងក្រុមនេះមានឈ្មោះអក្សរ T និងអក្សរ U ដែលបែរមុខទៅខាងលិច ហើយប្រហែលជាត្រូវបានកសាងឡើងក្នុងពេលតែមួយ។ ប្រាសាទទី១ គឺប្រាសាទអក្សរ T មានទំហំ៤៥ម៉ែត្រគុណនឹង៤០ម៉ែត្រ និងប្រាសាទទី២ គឺប្រាសាទអក្សរ U មានទំហំ៣៥ម៉ែត្រគុណនឹង២៨ម៉ែត្រ។ ប្រាសាទទាំងពីរស្ថិតនៅតាមខ្សែបន្ទាត់ពីកើតទៅលិច និងមានកសិណទឹកតែមួយព័ទ្ធជុំវិញ។ នៅខាងលិចមានក្តារបែនមួយដែលសម្គាល់ថាជាផ្លូវចូល។

នៅខាងកើតប្រាសាទអក្សរ T និងប្រាសាទអក្សរ U ឆៀងខាងជើងបន្តិច មានប្រាសាទមួយឈ្មោះប្រាសាទអក្សរ X ប្រហែលជាប្រាសាទចុងក្រោយគេនៅក្នុងក្រុមនេះ កសាងឡើងនៅសតវត្សទី១៤ ដោយគ្មានកំផែងព័ទ្ធជុំវិញ និងមានកសិណទឹកធំជាងគេព័ទ្ធជុំវិញ។ កសិណទឹកចុងក្រោយនេះភ្ជាប់ទៅជ្រុងខាងត្បូងឆៀងខាងលិចនៃកសិណទឹកពីមុន។ ជណ្តើរពីរជាន់ដែលគេសាងសង់នៅលើទីលានមួយមានទំហំប្រមាណជា៤០ម៉ែត្រគុណនឹង៤០ម៉ែត្រ និងកម្ពស់៤ម៉ែត្រ ធ្វើឲ្យប្រាសាទមានរាងខ្ពស់ស្រឡៅទៅលើ។ ចំណែកឯប្រាសាទអក្សរ V នៅខាងជើងប្រាសាទអក្សរ U ក៏គ្មានកំផែងព័ទ្ធជុំវិញដែរ ហើយនៅខាងលិចប្រាសាទនេះមានស្ពានហាលមួយប្រវែងប្រមាណជា៧០ម៉ែត្រ។ នៅប្រមាណជា៣០ម៉ែត្រ ឆ្ងាយពីប្រាសាទនោះបន្តិចមានប្រាសាទទី៥មួយទៀត។ ប្រាសាទនេះកសាងឡើងនៅក្នុងកាលបរិច្ឆេទមួយថ្មីជាងប្រាសាទអក្សរ T អក្សរ U និងអក្សរ V។ ប្រាសាទទាំង៥ សុទ្ធតែជាប្រាសាទ ឧទ្ទិសដល់សាសនាហិណ្ឌូ មានតែប្រាសាទ អក្សរ Xប៉ុណ្ណោះ ដែលខុសពីគេ ឧទ្ទិសដល់ព្រះពុទ្ធសាសនា។ ខ្ញុំជឿថា ខ្ញុំអស់ពេលទៅហើយក្នុងរយៈពេល១៥នាទីសម្រាប់គម្រោងទាំងពីរ វាហាក់ដូចជាខ្លីបន្តិច។ [ស្លាយ] ខ្ញុំសូមទុកពេលឲ្យឯកឧត្តម លោកជំទាវ មើលស្លាយជាបន្តបន្ទាប់ឲ្យឃើញប្រាសាទទាំងអស់គឺប្រាសាទទាំង៥ ដែលនៅក្នុងនោះមាន៤ប្រាសាទដែលឧទ្ទិសដល់សាសនាហិណ្ឌូ និងប្រាសាទមួយឧទ្ទិសដល់ព្រះពុទ្ធសាសនាគឺប្រាសាទអក្សរ X។ ខ្ញុំសូមនិយាយត្រួសៗអំពីការប៉ះពាល់ និងការជួសជុលបន្តិចបន្តួចកាលពីពេលមុននៅប្រាសាទព្រះពិធូរ។ ខ្ញុំសូមអានត្រួសៗគឺថាការផ្លាស់ប្តូរពីសាសនាព្រាហ្មណ៍ទៅសាសនាព្រះសិវៈ

[ស្លាយ] ការប្រើប្រាស់ថ្មនៅក្នុងសំណង់ ហើយនេះគឺជាប្រាសាទផ្សេងទៀត។ ការជួសជុលក្រោយសម័យអង្គរដោយសហគមន៍សាសនា អន្តរាគមន៍របស់បារាំងនៅដើមសតវត្សទី២០ និងអន្តរាគមន៍កាលពីពេលថ្មីៗរបស់អាជ្ញាធរអប្សរា។

[ស្លាយ] នៅលើរូបភាពនេះគឺការប្រើប្រាស់ឡើងវិញនូវថ្ម ហើយក្នុងរូបនេះក៏ដូចគ្នាដែរ។ យើងបានប្រើប្រាស់ថ្មនៅប្រាសាទ X យកទៅដាក់ជួសជុលនៅប្រាសាទអក្សរ V។ នៅប្រាសាទព្រះពិធូរ យើងនឹងចាំបាច់ត្រូវធ្វើការឲ្យបានប្រុងប្រយ័ត្នបំផុតចំពោះបរិស្ថានធម្មជាតិ។ [ស្លាយ] ខ្ញុំសូមបង្ហាញត្រួសៗនូវរូបភាពបណ្ណសារស្តីអំពីប្រាសាទទាំង៥ បន្ទាប់មកអំពីស្ថានភាពបច្ចុប្បន្ននៅប្រាសាទនីមួយៗ ដោយមិនចាំបាច់ធ្វើការអត្ថាធិប្បាយពីព្រោះគេបានឲ្យសញ្ញាមកខ្ញុំជាញឹកញយថាខ្ញុំអស់ពេលហើយ។

[ស្លាយ] ខ្ញុំសូមឈប់បន្តិចនៅត្រង់កន្លែងនេះ ពីព្រោះតម្លៃបេតិកភណ្ឌនៃប្រាសាទព្រះពិធូរ គួរត្រូវគូសបញ្ជាក់៖ មានតួនាទី រចនាបថ ការប្រើប្រាស់ច្រើនបែបច្រើនយ៉ាងនៅក្នុងពេលកន្លងមក មានទម្រង់ លំហ ទេសភាព និងឋានលេខាយ៉ាងច្រើនសម្បូរបែប ស្ថានភាពអភិរក្សបរិស្ថានធម្មជាតិនៅក្នុងរមណីយដ្ឋាននេះមានសភាពល្អ និងមានភាពសម្បូរបែបអន្តរវប្បធម៌និងប្រវត្តិសាស្ត្រ។ យើងត្រូវបញ្ចេញព័ត៌មានទាំងនេះ ផ្សព្វផ្សាយកុំឲ្យសាធារណជនមិនដឹងតទៅទៀត។ យថាភាព៖ ប្រាង្គប្រាសាទមិនត្រូវបានប៉ះពាល់ដោយការជួសជុលនៅក្នុងសតវត្សកន្លងមកនេះទេ ក្រៅពីការងារថែទាំតិចតួច។

[ស្លាយ] ខ្ញុំសូមពន្យឺតបន្តិចនៅត្រង់រូបថតទាំងនេះ ខ្ញុំសូមអភ័យទោសផង។ នៅពេលដែលមានការជួសជុលនៅទីលានព្រះបរមរាជវាំង ដើម្បីរៀបចំតូបលក់ យើងបានគិតថា ចំណតឡាននិងតូបទាំងនេះនឹងត្រូវដាក់នៅកន្លែងនេះជាបណ្ដោះអាសន្នប៉ុណ្ណោះ ហើយយើងនឹងដោះស្រាយបញ្ហាលំហូរភ្ញៀវនិងការកកស្ទះរបស់ភ្ញៀវ។

[ស្លាយ] អ្វីដែលឯកឧត្តម លោកជំទាវ ឃើញនេះ គឺផ្តើមចេញពីប្រាសាទ យើងឃើញតូបនិងហាងលក់ចំណីអាហារមួយជួរនេះ។ តូបលក់ចំណីអាហារបានបោះសំរាមចោលទៅខាងក្រោយ មានន័យថា បោះសំរាមទៅខាងមុខប្រាសាទតែម្តង។ យើងលឺសម្លេងម៉ាស៊ីនភ្លើងដែលដើរឥតដាច់។ ខ្ញុំមិនទាន់និយាយដល់រឿងក្លិនទៀតផង ពីព្រោះជាអកុសល បទបង្ហាញ PowerPoint របស់ខ្ញុំ មិនអាចផ្តល់ក្លិនបានទេនៅពេលនេះ។ សូមអរគុណ និងសូមអភ័យទោសចំពោះពេលវេលា។

**សហប្រធានជប៉ុន៖** សូមអរគុណលោក រស់ បូរ៉ាត់ ជាពិសេសចំពោះការយោគយល់របស់លោកដោយត្រូវគោរព ដល់ពេលវេលាដែលបានកំណត់ជូនចំពោះបទបង្ហាញរបស់លោក។ បទបង្ហាញចុងក្រោយគឺជាបទបង្ហាញរបស់ បណ្ឌិត ហង់ ពៅ និងលោក ព្យែរ ក្លេម៉ង់។ លោកទាំងពីរ សូមអញ្ជើញ។

## ៣.៣. បទបង្ហាញដោយឯកឧត្តម ហង់ ពៅ អគ្គនាយករងអាជ្ញាធរអប្សរា និងលោក ព្យែរ ក្លេម៉ង់ ប្រធានសមាគមមិត្តភក្តិអង្គរ ស្តីអំពី ការរៀបចំនិងគ្រប់គ្រងប្រព័ន្ធទឹកនៅក្នុងឧទ្យានអង្គរ និងសៀមរាប

**លោក ហង់ ពៅ៖**
សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រធានអាជ្ញាធរអប្សរា។
សូមគោរពលោក លោកស្រី ជាទីគោរព។

[ស្លាយ] ខ្ញុំសូមអនុញ្ញាតបង្ហាញជូនអំពីគម្រោងរបស់យើងស្តីអំពីការរៀបចំ គ្រប់គ្រងទឹកនៅអង្គរ និងសៀមរាប។ គោលបំណងរបស់គម្រោងគឺការរៀបចំប្រព័ន្ធគ្រប់គ្រងពីចម្ងាយដើម្បីជានានូវការធ្វើសេចក្តីសម្រេចឲ្យបានកាន់ តែប្រសើរសម្រាប់ការគ្រប់គ្រងធនធានទឹកនៅក្នុងតំបន់សៀមរាប។ នេះគឺមានន័យថា អាចបញ្ចូលប្រព័ន្ធបុរាណ ដែលមានស្រាប់ដោយប្រើបច្ចេកវិទ្យាថ្មី ដែលអនុញ្ញាតឲ្យយើងទប់ទល់បានកាន់តែប្រសើរ ជាពិសេស ទប់ទល់ នឹងបាតុភូតដែលកើតឡើងជាញឹកញាប់នៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ជាពិសេសគឺទឹកជំនន់។

នៅពេលដែលប្រព័ន្ធនេះត្រូវបានរៀបចំរួចនៅតាមមូលដ្ឋានហើយ វានឹងអនុញ្ញាតឲ្យយើងគ្រប់គ្រងបាននូវជារទឹក មិនត្រឹមតែជារទឹកដែលបណ្តាលមកពីគ្រោះថ្នាក់ធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែយើងថែមទាំងអាចដោះស្រាយបាននូវ រាល់បញ្ហាប្រចាំថ្ងៃ ឬថែមទាំងក្នុងពេលមានភាពរាំងស្ងួតទៀតផង ដែលអាចកើតមានឡើងនៅក្នុងបណ្តាឆ្នាំមួយ ចំនួន។ ចំនុចទី៣គឺជានាឲ្យមានការគ្រប់គ្រងឲ្យបានកាន់តែប្រសើរបំផុតដែលអាចធ្វើទៅបាននូវធនធានធម្មជាតិ ក្នុងគោលដៅអភិរក្សបេតិកភណ្ឌអង្គរ ក៏ដូចជាគាំទ្រការអភិវឌ្ឍតំបន់សៀមរាបអង្គរ។

គេក៏មិនត្រូវភ្លេចផងដែរអំពីប្រជាជនក្នុងស្រុកដែលរស់នៅក្នុងឧទ្យានអង្គរ ពួកគាត់អាចទាញប្រយោជន៍ពីប្រព័ន្ធ នេះ។ យើងត្រូវចាត់វិធានការសំអាតទឹកនៅតាមភូមិមួយចំនួននៅក្នុងឧទ្យានអង្គរ ដែលប្រឈមមុខនឹងបញ្ហា ទឹក។ ផ្នែកមួយទៀតនៃគម្រោងរបស់យើង គឺការបណ្តុះបណ្តាលអ្នកជំនាញវ័យក្មេងជនជាតិខ្មែរ។

[ស្លាយ] ខ្ញុំសូមបង្ហាញរូបភាពនេះ ដើម្បីឆ្លុះបញ្ចាំងនូវអ្វីដែលខ្ញុំបានជម្រាបជូនរួចមកហើយ៖ ឯកឧត្តម លោកជំទាវ ឃើញចំណុចក្រហមៗដែលតំណាងឲ្យស្ថានីយសម្រង់ទិន្នន័យដែលមានក្នុងពេលបច្ចុប្បន្ននេះ។ យើងនឹងបង្កើតស្ថានីយបែបនេះបន្ថែមទៀត ដោយប្រើប្រព័ន្ធស្វ័យប្រវត្តិ។ ទិន្នន័យទាំងអស់នឹងត្រូវបញ្ជូនទៅវិភាគដោយស្ថានីយវាស់វែងកម្រិតទឹក និងស្ថានីយឧតុនិយម ហើយទិន្នន័យទាំងនោះនឹងត្រូវបានបញ្ជូនភ្លាមៗសំដៅទៅការិយាល័យអាជ្ញាធរអប្សរា។ បែបនេះ យើងទទួលបានព័ត៌មានក្នុងពេលវេលាជាក់ស្តែង ហើយយើងនឹងអាចដឹងយ៉ាងច្បាស់អំពីអ្វីដែលកំពុងកើតឡើងនៅតាមមូលដ្ឋាន។ នៅពេលដែលយើងទទួលបានចំណេះដឹងនេះហើយ ដំណាក់កាលទី២នៃគម្រោងគឺយើងអាចគ្រប់គ្រងដំណើរការធ្វើសេចក្តីសម្រេចពីចម្ងាយបាន។ អ្នកបច្ចេកទេសនឹងទទួលបានការបណ្តុះបណ្តាលដើម្បីស្វែងយល់អំពីបាតុភូតរូបវន្តទាំងមូលក៏ដូចជាគំរូនៃការរៀបចំគណិតវិទ្យាដែលបង្កប់នៅក្នុងទិន្នន័យទាំងនេះ មានន័យថា ជំនួសឲ្យការដែលចុះទៅបើកបិទទ្វារទឹកផ្ទាល់នៅនឹងកន្លែងដូចដែលយើងធ្លាប់បានធ្វើកន្លងមក គឺយើងអាចធ្វើពីចម្ងាយបានតាមរយៈប្រព័ន្ធនេះ។ ដូចដែលឯកឧត្តម លោកជំទាវជ្រាបស្រាប់ហើយ រមណីយដ្ឋានអង្គរលាតសន្ធឹងនៅលើផ្ទៃដី៤០១គីឡូម៉ែត្រក្រឡា ហើយបើសិនជាយើងគិតរួមបញ្ចូលទាំងអាងផ្ទុកទឹកចំនួន៣ថែមទៀតនោះ ផ្ទៃក្រឡាដែលយើងត្រូវគ្រប់គ្រងឡើងរហូតដល់១០០០គីឡូម៉ែត្រក្រឡា។ ដូច្នេះវាប្រហែលជាប្រសើរជាងដែលត្រូវបង្កើតប្រព័ន្ធស្វ័យប្រវត្តិដើម្បីគ្រប់គ្រងបញ្ហាផ្សេងៗពីចម្ងាយ។ វាជាប្រព័ន្ធដែលគេប្រើច្រើនជាងគេនៅក្នុងប្រភេទនៃគ្រោះថ្នាក់ធម្មជាតិបែបនេះ។ ជាបន្តទៅទៀតនេះ ខ្ញុំសូមអនុញ្ញាតផ្តល់វេទិកាបន្តជូនលោកសាស្ត្រាចារ្យ ព្យែរ ក្លេម៉ង់ ដើម្បីនិយាយអំពីគម្រោងនេះបន្ថែមទៀត។

**លោក ព្យែរ ក្លេម៉ង់៖**

យើងខ្ញុំពិតជាមានសេចក្តីរីករាយណាស់ដែលបានមករួមដំណើរជាមួយអាជ្ញាធរអប្សរា និងនាយកដ្ឋានគ្រប់គ្រងធនធានទឹកនៅក្នុងគម្រោងដែលសំខាន់បំផុតមួយនេះ ដែលអាជ្ញាធរអប្សរាបានចាប់ផ្តើមអនុវត្ត។ បទបង្ហាញផ្សេងៗជាច្រើនរបស់បណ្ឌិត ហង់ ពៅ នៅក្នុងរយៈពេល២ថ្ងៃកន្លងមកនេះ បង្ហាញនូវការចូលរួមរបស់ធនធានទឹកនៅក្នុងគ្រប់កម្រិតនៃជីវិតរស់នៅនិងការអភិវឌ្ឍនិងការអភិរក្ស ពោលគឺអ្វីដែលពាក់ព័ន្ធនឹងរមណីយដ្ឋានទាំងមូល។

រហូតមកដល់ពេលនេះ គឺអស់រយៈពេល៣ ទៅ៤ឆ្នាំហើយ ក្រោមការជួយជំរុញដ៏ខ្លាំងរបស់អគ្គវិស្វករ លោក ហ្វ្រង់ស័រ ឡឺហ្គ្រង់ ដែលបានចំណាយពេលវេលាមួយផ្នែកនៅក្នុងជីវិតរបស់លោកតាំងពីឆ្នាំ១៩៨០មកនៅទីក្រុងភ្នំពេញ និងនៅរមណីយដ្ឋានអង្គរ យើងពិតជាចាប់អារម្មណ៍ទៅលើបញ្ហានេះ ជាការងារបន្តពីសន្និសីទស្តីអំពីទឹក

និងជាពិសេសអំពីការស្រាវជ្រាវប្រវត្តិសាស្ត្រលើបុរីជាវាសាស្ត្រ យើងខ្ញុំពិតជារីករាយនឹងដាក់បញ្ចូលបទបង្ហាញបច្ចេកទេសនេះរបស់អាជ្ញាធរអប្សរានៅក្នុងទស្សនវិស័យមួយដ៏ទូលំទូលាយជាងនេះ ពោលគឺទស្សនវិស័យដែលសំដៅទៅស្វែងយល់អំពីប្រព័ន្ធប្រវត្តិសាស្ត្រនិងបុរាណវិទ្យានៃឧទ្យានអង្គរ តាមរយៈប្រព័ន្ធវាស់វែងដែលនឹងត្រូវរៀបចំឡើងក្នុងពេលដ៏ខ្លីខាងមុខនេះ និងអនុញ្ញាតឲ្យយើងបង្កើតនូវគំរូជាវាសាស្ត្រនៃអាងផ្ទុកទឹកទាំងអស់។

លោក ហ្វ្រង់ស័រ ឡឺហ្រ្គង់ បានធ្វើឲ្យ*សហជីពសំអាតទឹកនៃជ្រលងប៊ីយ៉ែវ្រ* ប្រទេសបារាំងបានយល់អស់ហើយរីឯប្រធានរបស់សហជីពនេះគឺលោក អាឡាំង វិចទ័រម៉ារសង់ ក៏បានមកចូលរួមក្នុងកិច្ចប្រជុំនេះជាច្រើនដងដែរ ដើម្បីបង្ហាញជូនឯកឧត្តម លោកជំទាវ អំពីដំណាក់កាលដំបូងនៃគម្រោង។ ជាអកុសល លោកបានទទួលមរណៈភាពបាត់ទៅហើយនៅឆ្នាំនេះ ពួកយើងពិតជាមានការសោកស្ដាយយ៉ាងខ្លាំង និងសូមឧទ្ទិសការដឹងគុណទាំងអស់ចំពោះការងាររបស់លោកដែលបានធ្វើកន្លងមក។ លោក ហ្សង់ប៉ូល ប៉ែកតឺឡូ ដែលបានមកជំនួសលោកក្នុងនាមជាប្រធានរបស់អង្គការ SIAVB ក៏មានវត្តមាននៅថ្ងៃនេះដែរ អមដំណើរដោយតំណាងជាច្រើនទៀតរបស់សហជីព SIAVB និងអ្នកបច្ចេកទេស ព្រមទាំងវិស្វករវ័យក្មេងដែលមានចំណាប់អារម្មណ៍ ព្រមទាំងតំណាងរបស់សហជីពសំអាតទឹក ក្រុងប៉ារីស៍ តំណាងដោយលោក ដូមីនីក រ៉ូបាំង ដែលជាអ្នករដ្ឋបាលនិងលោក គ្រីស្សង់ វ៉ែកណេ ដែលជាប្រធានផ្នែកទំនាក់ទំនងអន្តរជាតិ។

គម្រោងនេះបានកៀងគរឲ្យមានការចូលរួមពីស្ថាប័នជំនាញផ្សេងៗជាច្រើន ដែលបន្ទាប់ពីចំណាយពេលធ្វើការចាប់អារម្មណ៍លើកដំបូង និងការវិភាគវិទ្យាសាស្ត្ររួចមក នឹងត្រូវធ្វើការសិក្សាអំពីវិធានការនិងកិច្ចការបន្ថែមផ្សេងទៀត។ ភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍនិងភ្នាក់ងារ អាងសែនណ៉ាកម៉ង់ឌី ភ្នាក់ងារទឹក ដែលជាស្ថាប័នធំៗ បានជានាផ្ដល់ការគាំទ្ររបស់ពួកគេ រួមជាមួយអាជ្ញាធរកម្ពុជា និងដៃគូពាក់ព័ន្ធទាំងអស់របស់គម្រោង។ យើងខ្ញុំសង្ឃឹមថា ការចូលប្រលូកតាមរយៈខ្សែទឹកនេះប្រហែលជាអនុញ្ញាតឲ្យយើងចូលរួមដោះស្រាយបញ្ហាមួយចំនួនដែលបានលើកឡើងនៅថ្ងៃនេះ។

ជាការពិត គ្រប់គ្នាសុទ្ធតែមានការកោតសរសើរចំពោះ អាយស៊ីស៊ី ក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ និងកោតសរសើរចំពោះសកម្មភាពអន្តរជាតិ ព្រមទាំងសកម្មភាពរបស់រាជរដ្ឋាភិបាល ហើយអង្គរត្រូវបានស្រោចស្រង់ឲ្យផុតពីសភាពគ្រោះថ្នាក់ ប៉ុន្តែអស់រយៈពេល២ថ្ងៃកន្លងមកនេះ ជាអកុសលយើងបានលើកឡើងអំពីគ្រោះថ្នាក់ថ្មីៗជាច្រើនដែលកំពុងលេចមុខឡើង គឺដោយសារជោគជ័យរបស់រមណីយដ្ឋានខ្លួនឯង។ យើងនឹងប្រឈមមុខជាមួយវត្តមានរបស់មនុស្សរាប់លាននាក់ ជាមួយបាតុភូតនៃការបំពុលខ្យល់ និងបាតុភូតកាប់ព្រៃឈើដែលអាចនឹង

ចោទជាបញ្ហាទៅលើធនធានផ្សេងទៀត។ បាតុភូតទឹកមិនជ្រាបនិងទឹកហូរដែលបង្កើតបានជាទឹកជំនន់ តម្រូវឲ្យមានដំណោះស្រាយបច្ចេកទេសដែលនាំឲ្យមានការបង្កើតគម្រោងនេះឡើង ម្យ៉ាងទៀតវាអាចនាំមកជូនប្រជាជនក្នុងស្រុក ជាពិសេសប្រជាជនដែលរស់នៅក្នុងឧទ្យាន នូវផលប្រយោជន៍តាមរយៈគម្រោងសំអាតទឹកមួយទៀត។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន បានលើកឡើងរួចហើយអំពីការចុះហត្ថលេខាលើកិច្ចសន្យាមួយកាលពីល្ងាចម្សិលមិញជាមួយអភិបាលខេត្តនិងអាជ្ញាធរអប្សរា។ យើងខ្ញុំពិតជារីករាយណាស់ដែលពិធីចុះហត្ថលេខានេះបានប្រព្រឹត្តទៅនៅក្នុងឱកាសនៃការប្រារព្ធខួបលើកទី២០នៃគណៈកម្មាធិការបច្ចេកទេស ហើយយើងខ្ញុំពិតជារីករាយនឹងសហការជាមួយឯកឧត្តម លោកជំទាវ ទាំងអស់គ្នា។ ខ្ញុំសូមអរគុណ។

## កិច្ចពិភាក្សាពេញអង្គ

**សហប្រធានជប៉ុន៖** សូមអរគុណ បណ្ឌិត ហង់ ពៅ និងលោក ព្យែរ ក្លេម៉ង់។ យើងត្រូវទុកពេលសម្រាប់ការពិភាក្សាពេញអង្គ ប៉ុន្តែសហប្រធានចង់រំលងចំណុចពិភាក្សាពេញអង្គនេះ ដើម្បីឲ្យបានចំណេញពេល។ តើមានអ្នកណាម្នាក់ចង់និយាយទេ? តើឯកឧត្តម លោកជំទាវ មានបទអត្ថាធិប្បាយអ្វីដែលត្រូវធ្វើទៅលើគម្រោងដែលបានបង្ហាញជូនយើងនេះទេ? លោកស្រីអាន សូមអញ្ជើញ។

**លោកស្រី អាន ឡឺម៉ែត្រ៖**
សូមអរគុណលោកប្រធាន។ ខ្ញុំសូមអភ័យទោស ខ្ញុំនិយាយខ្លីទេ។ វាជាការពិចារណាដែលអង្គការយូណេស្កូ តែងតែធ្វើអស់រយៈពេលជាច្រើនឆ្នាំមកហើយ ពាក់ព័ន្ធនឹងបទបង្ហាញលើគម្រោងជួសជុលថ្មីៗទាំងអស់ យើងខ្ញុំសូមធ្វើការអំពាវនាវដល់គ្រប់ក្រុមជាតិ ក៏ដូចជាក្រុមអន្តរជាតិទាំងអស់ សូមយកចិត្តទុកដាក់ទៅលើលក្ខណៈបដិមាសាស្ត្ររបស់ប្រាសាទ។ នៅក្នុងករណីប្រាសាទព្រះពិធូរ យើងឃើញថា វាជាប្រាសាទដែលបានផ្លាស់ប្តូរសាសនាពីព្រហ្មញ្ញសាសនាទៅព្រះពុទ្ធសាសនា ដូច្នេះការសិក្សាអំពីបដិមាសាស្ត្រត្រូវតែជារឿងដែលត្រូវធ្វើសំខាន់បំផុតមុននឹងចាប់ផ្តើមការដ្ឋានជួសជុល។ ខ្ញុំគ្រាន់តែចង់និយាយចំណុចនេះឯង។ សូមអរគុណ។

**សហប្រធានជប៉ុន៖**
មានបទអត្ថាធិប្បាយអ្វីផ្សេងទៀតទេនៅក្នុងអង្គប្រជុំ? គ្មានទេ។ ដូច្នេះខ្ញុំសូមបន្តទៅចំណុចមួយទៀត គឺអង្គការយូណេស្កូនឹងធ្វើបទបង្ហាញ។ តើអ្នកណានឹងធ្វើបទបង្ហាញនេះ? សូមអញ្ជើញ លោកសាស្ត្រាចារ្យ។

# ៤. ចក្ខុវិស័យសម្រាប់ទសវត្សថ្មី

## ៤.១. បទបង្ហាញអំពីប្រធានបទសម្រាប់អនាគត

### លោក អាហ្សេឌីន បេសាអ៊ូសៈ

សូមអរគុណលោកសហប្រធាន។ ខ្ញុំគ្រាន់តែនិយាយដោយខ្លីដើម្បីរំលឹកថា យើងបានចែកជូននូវកំណត់ត្រាដែលយើងខ្ញុំបានត្រៀមរៀបចំដើម្បីជួយរាជរដ្ឋាភិបាលដែលទទួលយើង ក្នុងការរៀបចំកិច្ចប្រជុំដ៏សំខាន់នេះ ដូចនៅទីក្រុងប៉ារីស៍ និងនៅទីក្រុងតូក្យូ ហើយយើង ក្នុងនាមលេខាធិការដ្ឋាន យើងខ្ញុំបានបែងចែកការងារ ប៉ុន្តែសេចក្តីសម្រេចដែលគ្មានការតវ៉ាគឺនៅតែស្ថិតនៅក្នុងដៃរបស់រាជរដ្ឋាភិបាលដែលជាម្ចាស់ផ្ទះនៃសន្និសីទ។ យើងមានកំណត់ត្រាពាក់ព័ន្ធនឹងប្រធានបទនៃកំណាយបុរាណវិទ្យាបង្ការរហូតដល់តួនាទីរបស់ អាយស៊ីស៊ី និងមានកំណត់ត្រាផ្សេងទៀត។

គ្រួសៗខ្ញុំគ្រាន់តែចង់និយាយថា គឺអង្គការយូណេស្កូ លេខាធិការដ្ឋាន រួមទាំងអង្គការអ៊ីក្រូមទៀតផង ដែលបានយល់ព្រមជួយយើងក្នុងការបណ្តុះបណ្តាល ហើយអ្នកជំនាញ អាដហុក របស់យើង ជាពិសេសលោកសាស្ត្រាចារ្យ អុយប៉ែរ និង ហ្វូត៍ ដែលបានគិតគូរចូលរួមតាក់តែងកំណត់ត្រានេះដែរ។ កំណត់ត្រាទាំងនេះបានធ្វើរួចហើយ និងត្រូវបានធ្វើជូនគ្រប់គ្នារួចហើយ យើងខ្ញុំសង្ឃឹមថាកំណត់ត្រាទាំងនេះនឹងជួយសម្រួលដល់ការត្រិះរិះពិចារណារបស់លោក លោកស្រី រដ្ឋមន្ត្រី និងប្រធានគណៈប្រតិភូទាំងអស់។ វាគ្មានអ្វីដែលត្រូវសង្ស័យទេថា ពាក្យចុងក្រោយ ដូចដែលខ្ញុំបានលើកឡើងរួចមកហើយ គឺនឹងត្រូវនិយាយនៅពេលស្អែក។ កំណត់ត្រាទាំងនេះត្រូវបានចែកជូនក្នុងនាមជាព័ត៌មានតែប៉ុណ្ណោះ។

## ៤.២. បទបង្ហាញអំពីពង្រាងអនុសាសន៍និងសេចក្តីថ្លែងការណ៍របស់សន្និសីទអន្តររដ្ឋាភិបាលលើកទីបីស្តីពីអង្គរ

### លោក អាហ្សេឌីន បេសាអ៊ូសៈ

ពេលនេះខ្ញុំសូមឈានដល់សេចក្តីថ្លែងការណ៍និងអនុសាសន៍។ តើយើងបានធ្វើដូចម្តេចឯកឧត្តមសហប្រធាន ?

យើងខ្ញុំបានចាប់ផ្តើមត្រឹមកម្រិតលេខាធិការដ្ឋានដោយបានបែងចែកការងារគ្នាធ្វើ។ គម្រោងដំបូងត្រូវបានដាក់ជូនសហប្រធានបារាំង សហប្រធានជប៉ុន អង្គការយូណេស្កូ និងលេខាធិការដ្ឋាន អាយស៊ីស៊ី។ យើងខ្ញុំបានជួបប្រជុំគ្នាជាច្រើនដង និងបានពិនិត្យមើលលើពង្រាងទាំងនេះ។

គម្រោងដែលបានដាក់ជូនយើងនៅពេលនេះត្រូវបានចែកជូនជាភាសាបារាំងផង ជាភាសាអង់គ្លេសផង ហើយជាការពិត វាគ្រាន់តែក្នុងនាមជាព័ត៌មានប៉ុណ្ណោះ។ នៅថ្ងៃស្អែក វាគឺជាអភ័យឯកសិទ្ធិរបស់សន្និសីទដែលត្រូវអនុម័តដូចដែលធ្លាប់បានធ្វើនៅទីក្រុងតូក្យូ ឬក៏ធ្លាប់បានធ្វើនៅទីក្រុងប៉ារីស៍រួចហើយ ឬក៏ធ្វើយ៉ាងណាឲ្យសំណើនេះត្រូវបានពិនិត្យមើលឡើងវិញកែសម្រួលឲ្យបានត្រឹមត្រូវ។ល។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ដោយបានថ្លែងអំណរគុណដល់គ្រប់ក្រុមទាំងអស់ដែលបានធ្វើកិច្ចការការនេះ បានជម្រាបជូនយើងអម្បាញ់មិញនេះថា លោកមានសំណើកែសម្រួលខ្លះៗនៅលើចំនុចមួយចំនួន។

ចំនុចកែសម្រួលមានមិនច្រើនទេ ប៉ុន្តែ ប្រសិនបើឯកឧត្តមសហប្រធានទាំងពីរអនុញ្ញាត ខ្ញុំចង់និយាយថា វាជាអភ័យឯកសិទ្ធិរបស់អាជ្ញាធរអប្សរាទេដែលត្រូវចាប់ផ្តើមអនុម័តលើអត្ថបទពង្រាងដែលអាជ្ញាធរខ្លួនឯងចង់ដាក់ជូនសន្និសីទទាំងមូល យើងមិនកំណត់ឲ្យធ្វើបែបណានោះទេ។ បន្ទាប់មកចំណុចកែតម្រូវដែលឯកឧត្តមនិងក្រុមរបស់ឯកឧត្តមចង់ធ្វើ យើងខ្ញុំសូមឲ្យអត្ថបទកែតម្រូវទាំងនេះត្រូវបានផ្ញើមកយើងខ្ញុំ ហើយយើងខ្ញុំនឹងចែកជូន។

បែបនេះ យើងធ្វើការងាររបស់យើង ហើយគឺរាជរដ្ឋាភិបាលដែលស្នើជូនដល់អង្គសន្និសីទទាំងមូលនូវពង្រាងសេចក្តីថ្លែងការណ៍និងអនុសាសន៍។ យើងបានធ្វើបែបនេះនៅទីក្រុងតូក្យូក៏ដូចជានៅទីក្រុងប៉ារីស៍។ ប្រសិនបើគ្មានយោបល់អ្វីទេ ដើម្បីចំណេញពេលវេលា ពីព្រោះគ្មានអ្វីត្រូវនិយាយទៀតទេ ខ្ញុំសូមឲ្យឯកឧត្តមសហប្រធានចូលដល់ចំណុច ព័ត៌មានផ្សេងៗ។

### សហប្រធានជប៉ុន៖

សូមអរគុណចំពោះបទបង្ហាញរបស់លោក។ អ្នកចូលរួមមកពីបណ្តាគណៈប្រតិភូផ្សេងៗនឹងសិក្សាយប់នេះអំពីពង្រាងទាំងនេះ ដែលបានចែកជូនរួចហើយដូចដែលបានពន្យល់រួចហើយ ថ្ងៃស្អែកនឹងមានការពិភាក្សារួមគ្នាទៅលើពង្រាងនេះ ហើយយើងនឹងសាកល្បងអនុម័តទាំងអស់គ្នា។ តើមានព័ត៌មានផ្សេងទៀតទេស្តីអំពីចំណុចនេះនៅក្នុងរបៀបវារៈ? គ្មានអ្នកណាចង់មានប្រសាសន៍ទៀតទេ ដូច្នេះខ្ញុំសូមចូលដល់ចំនុចព័ត៌មានផ្សេងៗ។ ចំនុចទី៥ក្នុងរបៀបវារៈ ប្រធានបទទី១។ សូមអរគុណ។ សូមអញ្ជើញលោក។

# ៥. ផ្សេងៗ

## ៥.១. ព័ត៌មានផ្សេងៗ

### ១. កិច្ចព្រមព្រៀងអប្សរានិងវិទ្យាស្ថាន Inrap

សូមអរគុណ។ ខ្ញុំមិនដឹងថា តើអគ្គនាយកស្ថាប័ន Inrap មានវត្តមាននៅទីនេះ ឬក៏អត់នោះទេ។ ខ្ញុំគ្រាន់តែចង់រំលឹកឡើងវិញ ប្រសិនបើគាត់និយាយ គាត់នឹងនិយាយបានល្អជាងខ្ញុំ គឺខ្ញុំគ្រាន់តែចង់រំលឹកឡើងវិញថា មានកិច្ចព្រមព្រៀងមួយដែលត្រូវបានចុះហត្ថលេខារវាងអាជ្ញាធរអប្សរា និងស្ថាប័ន Inrap។ លោកអគ្គនាយកអាចមានពាក្យពេចន៍បន្ថែមផ្សេងទៀតដើម្បីផ្តល់ព័ត៌មានជូន អាយស៊ីស៊ី របស់យើង។ វាមិនមែនជារឿងដែលត្រូវបង្ហាញកិច្ចព្រមព្រៀងនោះទេ ពីព្រោះកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខារួចហើយ ប៉ុន្តែគ្រាន់តែផ្តល់ជាព័ត៌មានអំពីទិដ្ឋភាពទូទៅត្រួសៗស្តីអំពីកិច្ចព្រមព្រៀងនេះ។

**លោក ព្យែរ ឌុយប្រឺយ៍៖**
សូមអរគុណលោកសហប្រធានទាំងពីរ។
សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី។
សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីគោរព។

ខ្ញុំនឹងនិយាយយ៉ាងខ្លីបំផុតពីព្រោះខ្ញុំមានឱកាសកាលពីម្សិលមិញបាននិយាយរួចហើយជាមួយលោកព្យែរ បាទីស្ត៍ បង្ហាញជូននូវការងារដែល Inrap បានធ្វើកន្លងមកជាមួយអាជ្ញាធរអប្សរា។ ខ្ញុំគ្រាន់តែចង់គូសបញ្ជាក់ថាទំនាក់ទំនងរវាង Inrap និងអាជ្ញាធរអប្សរា ចាប់ពីពេលនេះតទៅ កាន់តែរឹងមាំថែមទៀត គឺទំនាក់ទំនងដែលមានតាំងពីឆ្នាំ២០០៤មក ពោលគឺចាប់តាំងពីអន្តរាគមន៍លើកដំបូងរបស់ក្រុម Inrap ទៅតាមសំណើរបស់អាជ្ញាធរអប្សរា។ យើងតែងតែធ្វើឲ្យទំនាក់ទំនងដៃគូរបស់យើងកាន់តែស៊ីជម្រៅថែមទៀត សម្រាប់ជាប្រយោជន៍ដល់វិស័យបុរាណវិទ្យាបង្ការ និងការអភិរក្សសំណល់បុរាណវិទ្យា ដែលយើងយល់អំពីសារៈសំខាន់របស់វាហើយនៅពេលនេះ នៅក្នុងតំបន់ជុំវិញ ឬជិតៗអាកាសយានដ្ឋានសៀមរាប។

ដូចដែលលោកបានបញ្ជាក់អម្បាញ់មិញនេះស្រាប់លោកសាស្ត្រាចារ្យបន្ទាប់ពីកិច្ចព្រមព្រៀងសម្រាប់ឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ មានកិច្ចព្រមព្រៀងថ្មីមួយទៀត ដែលយើងនឹងចុះហត្ថលេខានៅចំពោះមុខវត្តមានរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងផ្សព្វផ្សាយ នៅសប្តាហ៍នេះ ជាមួយឯកឧត្តម ប៊ុន ណារិទ្ធ អគ្គនាយកអាជ្ញាធរអេប្សរា។ កិច្ចព្រមព្រៀងថ្មីនេះ នឹងពន្យារកិច្ចសហប្រតិបត្តិការរវាងស្ថាប័ន Inrap និងអាជ្ញាធរអេប្សរា គឺនៅក្នុងក្របខណ្ឌនេះហើយ ដែលរហូតដល់ឆ្នាំ២០១៦ រួមជាមួយក្រុមហ៊ុន Cambodia Airport និងក្រុមហ៊ុន វ៉ាំងស៊ី យើងនឹងធ្វើការសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យានៅក្នុងក្របខណ្ឌនៃការពង្រីកអាកាសយានដ្ឋានសៀមរាប។

មុននឹងបញ្ចប់ ខ្ញុំគ្រាន់តែចង់សង្កត់ធ្ងន់នៅទីនេះចំពោះមុខឯកឧត្តម លោកជំទាវទាំងអស់គ្នាទៅលើលក្ខណៈជាគំរូនៃភាពជាដៃគូនេះរវាង Inrap និងអាជ្ញាធរអេប្សរា ដែលមានគោលដៅធ្វើឲ្យមាននិរន្តរភាព និងអនុញ្ញាតឲ្យសម្រេចបាននូវរឿងសំខាន់ៗចំនួន៣។ ទី១ គឺផ្សារភ្ជាប់ជាមួយគ្នារវាងការអភិវឌ្ឍសេដ្ឋកិច្ចនិងការអភិរក្សបេតិកភណ្ឌបុរាណវិទ្យានៅក្រោមដី។ ទី២ ដែលជាចំនុចពង្រឹងពិសេសនៅក្នុងកិច្ចព្រមព្រៀងចុងក្រោយនេះ ហើយដែលខ្ញុំទើបបាននិយាយរួចមកនេះ គឺការបណ្តុះបណ្តាលនិងការផ្ទេរចំណេះធ្វើនិងជំនាញផ្សេងៗដល់បុរាណវិទូខ្មែរ ហើយតាមរយៈកម្មវិធីនេះ យើងនឹងទទួលបុរាណវិទូខ្មែរឲ្យទៅធ្វើកម្មសិក្សានៅប្រទេសបារាំងដើម្បីទទួលការបណ្តុះបណ្តាលបន្ថែមទៀត។ នៅពេលបច្ចុប្បន្ននេះ ក៏យើងធ្វើដូចគ្នាដែរ ពីព្រោះនៅពេលដែលខ្ញុំកំពុងនិយាយនេះ មានបុរាណវិទូខ្មែរពីររូបបានទៅទីក្រុងប៉ារីស៍ ធ្វើកម្មសិក្សានៅក្នុងស្ថាប័នយើងតែម្តង ហើយខ្ញុំមានសេចក្តីរីករាយសូមប្រកាសជូនឯកឧត្តម លោកជំទាវ ទាំងអស់គ្នាថា នៅឆ្នាំ២០១៤ យើងនឹងដកស្រង់បទពិសោធន៍នេះជាថ្មីម្តងទៀត ហើយនៅក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងនេះ ជាមួយអាជ្ញាធរអេប្សរា យើងនឹងទទួលបុរាណវិទូខ្មែរពីរនាក់ទៀតឲ្យមកធ្វើកម្មសិក្សា។

នៅទីនេះ ខ្ញុំគ្រាន់តែចង់និយាយថា ខ្ញុំពិតជាមានមោទនភាពនិងមានសេចក្តីរីករាយយ៉ាងខ្លាំង ពីព្រោះលោកបានអញ្ជើញខ្ញុំមក គឺរីករាយនឹងបង្ហាញជូនជាមួយអាជ្ញាធរអេប្សរាថា បុរាណវិទ្យាបង្ការដែលជាប្រយោជន៍ដល់ការគ្រប់គ្រងប្រកបដោយចីរភាពនៃរមណីយដ្ឋានអង្គរ គឺជាទិដ្ឋភាពមួយដ៏សំខាន់នៃភាពជាដៃគូនេះ ហើយយើងខ្ញុំពិតជារីករាយនៅទីនេះដែលអាចបង្ហាញជូនអំពីក្របខណ្ឌនៃកិច្ចព្រមព្រៀងនេះ ដែលយើងនឹងចុះហត្ថលេខាជាថ្មីម្តងទៀតនៅសប្តាហ៍នេះ។ សូមអរគុណ។

## ២. បណ្តូរពិព័រណ៍វប្បធម៌រវាងប្រទេសចិន និងកម្ពុជា

**លោក អាហ្សេឌីន បេសាអ៊ូសៈ**

សូមអរគុណលោកអគ្គនាយក។ ចំណុចទី២៣ក់ព័ន្ធនឹងគម្រោងបណ្តុះវប្បធម៌។ ឆ្នាំនេះ មានការចាប់ផ្តើមកម្មវិធីបណ្តុះវប្បធម៌មួយដ៏សំខាន់រវាងអាជ្ញាធរអេប្សារា និងស្ថាប័នមួយរបស់ចិន ខាងផ្នែកទំនាក់ទំនងវប្បធម៌ជាមួយបរទេស។

ពិព័រណ៍មួយស្តីអំពីអង្គរត្រូវបានទទួលឲ្យរៀបចំ និងបង្ហាញជូនភ្ញៀវទស្សនានៅអតីតព្រះបរមរាជវាំងចិន ហើយជាការពិត នៅពេលដែលតួលេខភ្ញៀវចូលទៅទស្សនាពិព័រណ៍ឡើងដល់៥ម៉ឺនឬក៏១០ម៉ឺននាក់ នៅប្រទេសចិន វាហាក់ដូចជាតួលេខធម្មតាប៉ុណ្ណោះ ប៉ុន្តែសម្រាប់កម្ពុជា វា ជាតួលេខមួយដ៏ច្រើន ហើយវាបង្ហាញថា ពិព័រណ៍នេះគឺជាដើមដំបូងនៃដំណើរការមួយដ៏វែងឆ្ងាយ។ តាមរយៈមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវអន្តរជាតិរបស់ខ្លួន ប្រទេសចិនបានសម្រេចបញ្ជូនពិព័រណ៍ដ៏ធំមួយស្តីពីរមណីយដ្ឋាន នានាដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកចំនួនជាង៤៥រមណីយដ្ឋាន ដើម្បីយកមកដាក់តាំងនៅទីនេះនៅក្នុងអំឡុងឆ្នាំ២០១៤។

**៣. ពិព័រណ៍នៅសារមន្ទីរ ហ្គីមេៈ "អង្គរៈ ការចាប់កំណើតឡើងវិញនៃទេវកថាមួយ - លោក លូី ដឺឡាប៉កត៍ និងកម្ពុជា" (ពីថ្ងៃទី១៦ ខែតុលា ដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤)**

**លោក អាហ្សេឌីន បេសាអ៊ូសៈ**

ចំនុចទី៣ ប្រសិនបើឯកឧត្តមអនុញ្ញាត គឺមិនមែនខ្ញុំទេ ដែលត្រូវបង្ហាញជូន ពីព្រោះវាជារឿងមួយដ៏ល្អ នោះគឺពិព័រណ៍ដែលមានចំណងជើងថា "ការចាប់កំណើតឡើងវិញនៃទេវកថាមួយ - លោក លូី ដឺឡាប៉កត៍ និងកម្ពុជា" វាជាពិព័រណ៍មួយនៅសារមន្ទីរ ហ្គីមេ។ លោកស្រី សូមអញ្ជើញ។

**លោកស្រី សូហ្វី ម៉ាការីយូៈ**

សូមគោរពលោកសហប្រធានទាំងពីរ។

សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី។

ខ្ញុំគ្រាន់តែនិយាយពីរបីម៉ាត់ប៉ុណ្ណោះអំពីជោគជ័យនៃពិព័រណ៍ស្តីអំពី "អង្គរ ការចាប់កំណើតឡើងវិញនៃទេវកថាមួយ" ដែលរំលឹកគុណដល់មនុស្សដ៏សំខាន់ម្នាក់និងដល់ទីកន្លែងដែលធ្វើឲ្យយើងជួបជុំគ្នានៅទីនេះ មនុស្សម្នាក់នោះគឺលោក លូី ដឺឡាប៉កត៍។ តាមបែបម្យ៉ាង លោកគឺជាអ្នកបង្កើតរឿងអង្គរ ហើយខ្ញុំក៏អាចនិយាយថែមទៀត

ថា លោកគឺជាអ្នកបង្កើតនូវក្តីស្រមៃមួយសម្រាប់មនុស្សជាច្រើនអំពីអ្វីដែលជាសិល្បៈខ្មែរ ហើយខ្ញុំសូមប្រើឡើងវិញដោយក្តីសុទ្ធចិត្តនូវសំនួនវោហារស័ព្ទរបស់ឯកឧត្តម សុខ អាន ដែលលោកនិយាយថា៖ "ភាពល្បីល្បាញនៃបេតិកភណ្ឌដែលមានវិសាលភាពជាសាកល"។

ខ្ញុំជឿថាជោគជ័យដ៏ធំធេងនៃពិព័រណ៍និងសៀវភៅកាតាឡុកដ៏ល្អឯកនៃពិព័រណ៍នេះ ដែលជាឧបករណ៍យោងដ៏សំខាន់ពិតប្រាកដមួយ ក្រៅអំពីអំណានដ៏គួរឲ្យចាប់អារម្មណ៍យ៉ាងខ្លាំង និងការបោះពុម្ពមួយដ៏ល្អ វាបង្ហាញនូវការបន្តពេញនិយមចូលចិត្តពីសាធារណជន និងជាពិសេសពីសាធារណជនបារាំង ហើយមិនត្រឹមតែបារាំងប៉ុណ្ណោះនោះទេ ដែលនិយមចូលចិត្តរមណីយដ្ឋានអង្គរនេះ។ ខ្ញុំគិតថា គេត្រូវគិតដល់សារៈសំខាន់នៃការបង្ហាញជូននូវពុម្ពចម្លាក់ដែលបានធ្វើកន្លងមកដូចដែលឯកឧត្តម លោកជំទាវ ជ្រាបស្រាប់ហើយ នៅពេលលោក ដឺឡ៉ាប៉កត៍ បានមកបំពេញបេសកកម្មជាច្រើនដងនៅអង្គរ ក្នុងរយៈពេលពាក់កណ្តាលទី២នៃសតវត្សទី១៩។

នៅទីនេះខ្ញុំចង់គូសបញ្ជាក់ ខណៈដែលមានការរៀបចំឡើងនូវការងារទាំងនេះដែលយើងសុទ្ធតែយកចិត្តទុកដាក់អស់ពីចិត្តពីថ្លើម នូវសារៈសំខាន់នៃពុម្ពទាំងនេះសម្រាប់សហគមន៍វិទ្យាសាស្ត្រ ពីព្រោះសម្រាប់ពុម្ពមួយចំនួនធំ វាអភិរក្សក្បាច់ចម្លាក់អង្គរដែលជាចម្លាក់នៅតាមប្រាសាទមួយចំនួន ហើយដែលសព្វថ្ងៃនេះ ចម្លាក់ទាំងនោះមានភាពទ្រុឌទ្រោមណាស់ទៅហើយ។ ខ្ញុំសូមបួងសួង និងសង្ឃឹមថា ពុម្ពទាំងនេះ ដែលមានខ្លះត្រូវបានថតជាទម្រង់ឌីជីថលរួចហើយ អាចត្រូវបានគេថតទុកជាទម្រង់ឌីជីថលឲ្យបានច្រើនបំផុត ដើម្បីឲ្យវាក្លាយទៅជាបណ្ណាល័យរូបភាព 3D ស្តីអំពីចម្លាក់នៅអង្គរ អំពីប្រាង្គប្រាសាទអង្គរសម្រាប់សហគមន៍វិទ្យាសាស្ត្រទាំងអស់។ សូមអរគុណ។

**លោក អាហ្សេឌីន បេសាអ៊ូស៖**

សូមអរគុណ លោកស្រី។ ហើយខ្ញុំសូមឲ្យសហប្រធានជាទីស្រឡាញ់របស់យើងអនុញ្ញាតឲ្យខ្ញុំនិយាយបន្តបន្តិចអំពីចំណុចនេះ។ នៅពេលដែលយើងឃើញថា ពិព័រណ៍នេះល្អ សំខាន់ បង្ហាញអំពីទម្រង់ដើមរបស់ប្រាសាទដូចកាលពីពេលមុន ពីព្រោះយើងមានពុម្ពចាក់ស្រាប់ ហើយឃើញប្រាសាទបានក្លាយទៅជាយ៉ាងណានៅពេលនេះ វាក៏ផ្តល់ឲ្យយើងនូវគំនិតមួយស្តីអំពីការវាស់វែងពេលវេលាដែរ។ ដូចដែលសិលាចារឹកចំណាស់ៗបានចាររួចហើយថា៖ "គឺពេលវេលាដែលធ្វើឲ្យប្រាសាទសឹករិចរិល រួមទាំងជាតិពុលផងដែរ"។

## ៤. ការបោះពុម្ពផ្សាយនាពេលថ្មីៗនេះ៖

- ព្រឹត្តិបត្របេតិកភណ្ឌពិភពលោក (យូណេស្កូ)៖ លេខចេញពិសេសស្តីពីកម្ពុជា

- ពិភពនៃទេវកថាខ្មែរ និពន្ធដោយលោកសាស្ត្រាចារ្យ វិចតូរីយ៉ូ រ៉ូវេដា
- មហាសេនាបតីសង្គ្រាម និពន្ធដោយលោកសាស្ត្រាចារ្យ សច្ចិដានន្ទ សាហៃ

**លោក អាហ្សេឌីន បេសាអ៊ីសះ**

ដោយមានការអនុញ្ញាតពីលោក ខ្ញុំសូមនិយាយត្រួសៗអំពីសៀវភៅដែលបានបោះពុម្ពផ្សាយកាលពីពេលថ្មីៗនេះ។ ខ្ញុំពិតជារីករាយយ៉ាងខ្លាំងចំពោះមុខវត្តមានរបស់មិត្តភក្តិយើងដែលជានាយកមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក និងលើកឡើងអំពីចំនុចមួយដែលគ្រប់គ្នាសុទ្ធតែបានស្វាគមន៍ កោតសរសើរ។ បច្ចុប្បន្ននេះព្រឹត្តិបត្របេតិកភណ្ឌពិភពលោកផ្តោតការចេញផ្សាយរបស់ខ្លួនមួយលេខនិយាយអំពីបេតិកភណ្ឌប្រទេសមួយ។ លេខចេញផ្សាយមួយនេះពិតជាបានទទួលជោគជ័យយ៉ាងពិសេស អត្ថបទពិតជាល្អយ៉ាងខ្លាំង នោះក៏ជាជោគជ័យរបស់ អាយស៊ីស៊ី ដែរ ពីព្រោះអ្នកដែលសរសេរអត្ថបទនេះ ភាគច្រើនគឺជាសមាជិករបស់ក្រុមនៅក្នុង អាយស៊ីស៊ីនេះឯងមានបារាំង ជប៉ុន អាល្លឺម៉ង់។ល។ និងអង្គការយូណេស្កូ។ ព្រឹត្តិបត្រនេះត្រូវបានបោះពុម្ពផ្សាយជាភាសាបារាំង អង់គ្លេស និងអេស្ប៉ាញ៉ុល ហើយដោយមានការព្រមព្រៀងជាមួយអង្គការយូណេស្កូ យើងបានបោះពុម្ពជាភាសាខ្មែរទៀត។ ព្រឹត្តិបត្រនេះនឹងត្រូវចែកជូនតាមសាលា និងបណ្ណាល័យផ្សេងៗ។ វាគឺជាជោគជ័យមួយរបស់បេតិកភណ្ឌពិភពលោក។

នៅក្នុងឱកាសនៃសម័យប្រជុំលើកទី៣៧ រាជរដ្ឋាភិបាល តាមសំណើឯកឧត្តមបណ្ឌិត សុខ អាន ឧបនាយករដ្ឋមន្ត្រីបានឲ្យអាជ្ញាធរអប្សរាបោះពុម្ពសៀវភៅមួយដ៏ល្អឯកគួរឲ្យចាប់អារម្មណ៍ដែលនៅក្នុងនោះបណ្ឌិត រ៉ូវេដាដែលជាអ្នកស្រាវជ្រាវមួយដ៏ធំស្តីអំពីទេវកថាខ្មែរ បានយកការសិក្សាទាំងអស់របស់លោក ទាំងនៅក្នុងសៀវភៅទី១របស់លោក មកបញ្ចូលគ្នាទាំងអស់ បោះពុម្ពចេញជាសៀវភៅមួយដ៏ល្អបែបនេះ និងមានចំណងជើងថាពិភពនៃទេវកថាខ្មែរ។ វាជាសៀវភៅមួយដែលបោះពុម្ពបានយ៉ាងល្អ ទាំងខ្លឹមសារ ទាំងរូបថត ដែលនឹងក្លាយទៅជាឯកសារសំខាន់មួយសម្រាប់ការសិក្សាអំពីទេវកថា។

ទន្ទឹមគ្នានោះដែរ នៅក្នុងឱកាសនៃសម័យប្រជុំលើកទី៣៧ មានសៀវភៅមួយទៀត ដែលត្រូវបានបោះពុម្ពផ្សាយជាភាសាអង់គ្លេសផង និងជាភាសាខ្មែរផង។ សៀវភៅនោះពាក់ព័ន្ធនឹងវីរជនមួយរូបនៅក្នុងទេវកថា ហើយមិនត្រឹមតែនៅក្នុងចំណោមវីរជននៅក្នុងប្រទេសនេះប៉ុណ្ណោះទេ នោះគឺមហាសេនាបតីសង្គ្រាម។ មហាសេនាបតីសង្គ្រាមបានការពារអង្គរ និងព្រះវិហារ នៅចន្លោះឆ្នាំ ១០៥១ និងឆ្នាំ១០៦៥ លោកជាវីរជនម្នាក់នៅក្នុងចំណោមវីរជនទាំងឡាយក្នុងសតវត្សទី១១។ ស្នាដៃនេះ គឺជារបស់អ្នកប្រាជ្ញជនជាតិឥណ្ឌាម្នាក់ ដែលជាទីប្រឹក្សារបស់

អាជ្ញាធរអប្សរា គឺលោកសាស្ត្រាចារ្យ សាច្ចិដនន្ទ សាហៃ។ ខ្ញុំសូមរំលឹកថា លោកគឺជាសិស្សរបស់អ្នកប្រាជ្ញបារាំងដ៏ល្បីម្នាក់ ពីព្រោះលោកបានធ្វើនិក្ខេបបទរបស់លោកនៅប្រទេសបារាំង ស្តីអំពីអក្សរចារិកនិងប្រវត្តិសាសនា។ លោកបានត្រៀមរៀបចំស្នាដៃនេះឡើងក្នុងឱកាសនៃកិច្ចប្រជុំលើកទី៣៧ និងបានបោះពុម្ពជាភាសាអង់គ្លេសផង និងជាភាសាខ្មែរផង។

និងចុងក្រោយ មានការបោះពុម្ពសំខាន់ពីរផ្សេងទៀត។ សៀវភៅទី១ត្រូវបានបោះពុម្ព ដោយមានការយល់ព្រមពីព្រឹត្តិបត្រ National Geographic ដែលបានបោះពុម្ពកាលពី៣ឆ្នាំមុន នូវលេខពិសេសមួយដ៏ល្អ ពាក់ព័ន្ធការសិក្សាមួយដ៏សំខាន់ស្តីអំពីស្ថានភាពអង្គរមុនអង្គរបានធ្លាក់ចុះ បើសិនជាខ្ញុំអាចនិយាយបែបនេះបាន។ អត្ថបទដែលមានចុះផ្សាយនៅក្នុងព្រឹត្តិបត្រនេះ ត្រូវបានគេចាត់ទុកថា សំខាន់បំផុតសម្រាប់ការត្រិះរិះពិចារណា ស្តីអំពីប្រវត្តិសាស្ត្រអង្គរ។ ព្រឹត្តិបត្រនេះត្រូវបានបកប្រែជាភាសាខ្មែរនិងត្រូវបានចែកជូនតាមបណ្ណាល័យ សាលារៀន និងសាកលវិទ្យាល័យផ្សេងៗ។ កិច្ចខិតខំប្រឹងប្រែងនេះគួរទទួលបានការកោតសរសើរ និងស្វាគមន៍ ពីព្រោះយើងឈានពីវិទ្យាសាស្ត្រទៅវប្បធម៌ ហើយវាជារឿងសំខាន់ណាស់ ដែលត្រូវមានការបោះពុម្ពជាភាសាខ្មែរ។

ដើម្បីបញ្ចប់ គេទើបបានបោះពុម្ពរួច ហើយខ្ញុំរីករាយណាស់ សូមស្វាគមន៍សៀវភៅទី៣ ពីព្រោះគេបានបោះពុម្ពចំនួន៣ហើយរហូតមកទល់ពេលពេលនេះ នោះគឺមិត្តភក្តិរបស់យើងមកពីវិទ្យាស្ថានហុងគ្រី សម្រាប់ការសិក្សាស្រាវជ្រាវស្តីអំពីអាស៊ីអាគ្នេយ៍ ដែលបានផ្តល់មកឲ្យយើងនូវសៀវភៅទី៣ស្តីអំពីប្រាសាទមួយដ៏សំខាន់គឺប្រាសាទក្រចាប់នៅកោះកេរ្តិ៍ ពីព្រោះពួកគេធ្វើការងារនៅកោះកេរ្តិ៍ ដូចដែលឯកឧត្តម លោកជំទាវជ្រាបស្រាប់ហើយ។

កាលពីពេលមុនមានការបោះពុម្ពផ្សាយមួយស្តីអំពីអក្សរចារិក និងការបោះពុម្ពពីរទៀតស្តីអំពីបុរាណវិទ្យា។ ដូច្នេះនៅពេលនេះសៀវភៅទាំងនេះស្ថិតនៅក្នុងទស្សនវិស័យនៃការងាររបស់យើងនៅអង្គរ ដែលចាប់ផ្តើមយ៉ាងម៉ឺងម៉ាត់កាលពីមួយសតវត្សមុន ហើយជាងនេះទៅទៀត គឺចាប់ផ្តើមដោយសាលាបារាំងចុងបូព៌ាប្រទេស។

នេះហើយឯកឧត្តមសហប្រធានទាំងពីរ ស្នាដៃសំខាន់ៗដែលខ្ញុំចង់ជម្រាបជូន។ ជាការពិតវាការងារដែលធ្វើឡើងជាក្រុម។ ហើយចុងក្រោយ គឺមានការងារមួយដ៏ល្អគួរឲ្យកត់សម្គាល់ ដែលបានធ្វើរួចហើយ យើងមិនចង់ទុកឲ្យការងារនេះកន្លងផុតទៅក្រោមសភាពស្ងប់ស្ងាត់នោះឡើយ។

សៀវភៅនេះត្រូវបានបោះពុម្ពជាពីរភាសា គឺភាសាអង់គ្លេសនិងភាសាបារាំង វាជាសៀវភៅដែលនិយាយអំពី២០

ឆ្នាំនៃការងារនៅអង្គរ។ យើងធ្លាប់បានបោះពុម្ពម្តងរួចហើយនៅប៉ារីស៍កាលពី១០ឆ្នាំមុន ឥឡូវនេះគឺសម្រាប់២០ ឆ្នាំ។ នៅតូក្យូ ដូចឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានមានប្រសាសន៍រួចហើយ កាលនោះគឺជាសន្និសីទស្ថាបនិក យើងពុំមានពេលបោះពុម្ពសៀវភៅនោះឡើយ ប៉ុន្តែនៅប៉ារីស៍យើងបានបោះពុម្ពម្តងរួចហើយ ហើយ២០ឆ្នាំបន្ទាប់ពីសន្និសីទនៅតូក្យូ យើងបានបោះពុម្ពសៀវភៅថ្មីមួយទៀត។ ក្រុមការងារមួយបានយកចិត្តទុកដាក់លើការរៀបចំបោះពុម្ពសៀវភៅនេះ ហើយខ្ញុំសូមថ្លែងអំណរគុណសហប្រធានទាំងពីររបស់យើង ឯកឧត្តមបណ្ឌិត សុខ អាន អគ្គនាយិកាអង្គការយូណេស្កូ និងអ្នកទាំងឡាយណាដែលបានចូលរួមវិភាគទាននៅក្នុងកិច្ចការនេះ។

ប៉ុន្តែការងារនេះប្រហែលជាមិនអាចទៅរួចនោះទេ ប្រសិនបើគ្មានយុវជនម្នាក់នេះ តើគេនៅឯណា? សូមអញ្ជើញងើបឡើង នេះគឺយុវជននេះឯង។ ជាការពិត ខ្ញុំសូមធ្វើជាសាក្សី គេបានធ្វើការពេញមួយអាទិត្យ មិនបានដេកមិនបានពួនផង គឺ លីម ប៊ុនហុក។ តើអ្នកណាដែលមិនស្គាល់ លីម ប៊ុនហុក? ការងារគ្រប់ក្រុមទាំងអស់សុទ្ធតែមាននៅក្នុងសៀវភៅនេះ។ យើងបានផ្ទៀងផ្ទាត់មើលរួចហើយ គ្រប់គ្នាសុទ្ធតែមានវត្តមាននៅក្នុងសៀវភៅនេះ គ្រប់គ្នាសុទ្ធតែបានចូលរួមវិភាគទានរបស់ខ្លួន។ យើងអាចនិយាយបានថា បន្ទាប់ពី២០ឆ្នាំ ប្រសិនបើអ្នកណាម្នាក់ចង់ដឹងថាអ្វីជា អាយស៊ីស៊ី គឺគេអាចរកឃើញនៅក្នុងសៀវភៅនេះ។

**លីម ប៊ុនហុក៖**

ខ្ញុំសូមអភ័យទោស ចំពោះតូក្យូដែលមិនសប្បាយចិត្តចំពោះសៀវភៅជាភាសាអង់គ្លេស។ ស្លាកសញ្ញាឡូហ្គោដែលនៅតែជាឡូហ្គោភាសាបារាំងដដែល តាមពិតយើងចង់ទុកដោយចេតនានូវលក្ខណៈបារាំងបន្តិចនេះ។

**លោក អាហ្សេឌីន បេសាអ៊ូស៖**

សហប្រធានទាំងពីរជាទីគោរព យើងនៅមានចំណុចចុងក្រោយមួយទៀតមុននឹងចូលដល់វគ្គបិទបញ្ចប់អង្គប្រជុំ តាមពិតគឺពីរចំណុច។ ទី១ គឺការអនុម័តអនុសាសន៍មុននឹងកំណត់កាលបរិច្ឆេទសម័យប្រជុំបច្ចេកទេសលើកក្រោយ។ ពាក់ព័ន្ធនឹងអនុសាសន៍ គឺថាដោយសារសម័យប្រជុំលើកទី៣៧របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក បានជាយើងមិនបានរៀបចំសម័យប្រជុំបច្ចេកទេសកាលពីខែមិថុនាកន្លងទៅ ហើយលើកមកប្រជុំកាលពីម្សិលមិញនិងព្រឹកមិញវិញ។ គ្រប់គ្នាសុទ្ធតែបានតាមដានយ៉ាងយកចិត្តទុកដាក់នៅក្នុងកិច្ចប្រជុំនេះ ហើយក្រោមការដឹកនាំដ៏យកចិត្តទុកដាក់របស់សហប្រធានបច្ចេកទេសរបស់យើងទាំងពីរ ក្នុងនាមប្រទេសបារាំងនិងប្រទេសជប៉ុន យើងបានធ្វើការល្អ អនុសាសន៍ទាំងនេះត្រូវបានចែកជូនរួចហើយ ជាភាសាបារាំងនិងជាភាសាអង់គ្លេស។

ប្រសិនបើគ្មានយោបល់ជំទាស់អ្វីទេ សូមអនុញ្ញាតឲ្យយើងខ្ញុំក្នុងលេខាធិការដ្ឋានស្នើសុំទៅសហការីរបស់យើង ប្រសិនបើពួកគេ ពិតជាគិតចង់អនុម័តលើអនុសាសន៍ទាំងនេះ។ ទម្រង់ចុងក្រោយដូចសព្វមួយដងដែរនឹងផ្តល់ជូនទាំងអស់គ្នានៅពេលដែលបានអនុម័តហើយ។ យើងមានទម្លាប់នេះ ហើយការងារសម្រេចចុងក្រោយតម្រូវឲ្យយើងធ្វើការបន្តិចហើយសមាជិកក្រុមទាំងអស់នៅទីនេះដើម្បីធ្វើការនេះ។

យើងក៏មានសៀវភៅមួយក្បាលនេះទៀតដែលបានចែកជូនឯកឧត្តម លោកជំទាវទាំងអស់គ្នាហើយ។ រៀងរាល់ឆ្នាំយើងតែងតែចែកជូននូវរបាយការណ៍មួយជាភាសាបារាំងនិងជាភាសាអង់គ្លេស ដែលនិយាយអំពីការងារទាំងអស់ដែលបានធ្វើហើយ ហើយដូចអ្នកច្បាប់និយាយដូច្នោះដែរ គឺអត្ថបទជាច្បាប់។ យើងធ្វើការលើកំណែតម្រូវផ្សេងៗ ហើយដូចសព្វមួយដងដែរ អ្នកដែលចង់កែតម្រូវអ្វីផ្សេងនៅក្នុងអត្ថបទ សូមមេត្តាផ្ញើទៅការិយាល័យអង្គការយូណេស្កូ លេខាធិការដ្ឋាននៅទីនេះស្រាប់នឹងធ្វើការកែតម្រូវ ធ្វើយ៉ាងណាឲ្យទម្រង់ចុងក្រោយដែលផ្តល់ជូននោះ គឺជាទម្រង់ដែលឯកភាពដោយ អាយស៊ីស៊ី។

**សហប្រធានជប៉ុន៖**

សូមអរគុណ លោក បេសាអ៊ូស។ ខ្ញុំចង់បញ្ចប់ចំណុចទី៥នៃរបៀបវារៈមុននឹងធ្វើការអនុម័ត។ សូមអរគុណផងដែរចំពោះព័ត៌មានដែលលោកបានផ្តល់ជូនដែលជាការពិត ជាព័ត៌មានមានប្រយោជន៍យ៉ាងខ្លាំង។ ជាពិសេសសម្រាប់ សៀវភៅទាំងអស់ដែលបានបោះពុម្ពផ្សាយនេះ មើលទៅដូចជាស្អាតខ្លាំងណាស់ ហើយយើងខ្ញុំសូមកោតសរសើរក្រុមរបស់លោកដែលបានចូលរួមវិភាគទានក្នុងការចងក្រងសៀវភៅនេះឡើង។ ការងារដែលសម្រេចបានពិតជាល្អខ្លាំងណាស់ក្នុងការរៀបចំសៀវភៅស្តីអំពី២០ឆ្នាំនៃអង្គរ ហើយយើងខ្ញុំពិតជាចង់អានសៀវភៅនេះខ្លាំងណាស់។ ជាថ្មីម្តងទៀត យើងខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដល់ក្រុមរបស់លោក។

ឥឡូវនេះ សូមឈានចូលដល់ចំនុចទី៦នៃរបៀបវារៈ។ យើងទើបតែបានជម្រាបជូនឯកឧត្តម លោកជំទាវអំពីអនុសាសន៍របស់អ្នកជំនាញ ដែលបានពិនិត្យនិងពិភាក្សានៅក្នុងសម័យប្រជុំបច្ចេកទេសកាលពីម្សិលមិញនិងព្រឹកមិញនេះ។ អនុសាសន៍ទាំងនេះត្រូវបានចែកជូនអ្នកចូលរួមទាំងអស់គ្នារួចហើយ។ ខ្ញុំក៏មានមួយច្បាប់ដែរ សម័យប្រជុំពេញអង្គពេលនេះត្រៀមខ្លួនរួចហើយនឹងធ្វើការអនុម័ត។ សូមអញ្ជើញលោកមានប្រសាសន៍។

# ៦. អនុសាសន៍របស់ គណៈកម្មាធិការ អាយ ស៊ី ស៊ី

### A. អនុសាសន៍ពិសេស

អាយស៊ីស៊ី អង្គរ សូមរំលឹកអំពីអាយុកាលរបស់ខ្លួន (អាយស៊ីស៊ី ប្រារព្ធឆ្នាំនេះគឺឆ្នាំ២០១៣ នូវខួបលើកទី២០នៃសកម្មភាពការងាររបស់ខ្លួន) សំដែងជាពិសេសនូវក្តីបារម្ភជាឯកច្ឆ័ន្ទ សូមឲ្យគោរពបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

សកម្មភាពការងាររបស់អ្នកជំនាញ អាដហុក ពិតជាសំខាន់យ៉ាងខ្លាំងសម្រាប់ដំណើរការល្អរបស់ អាយស៊ីស៊ី អង្គរ របាយការណ៍របស់ពួកគេគឺជារបាយការណ៍របស់សមាជិកក្រុមរួមគ្នា ថ្វីត្បិតថារបាយការណ៍នោះត្រូវបង្ហាញជូនដោយអ្នកជំនាញជាបុគ្គលម្នាក់ម្តងៗក្តី ក៏របាយការណ៍នោះមិនឆ្លុះបញ្ចាំងនូវគោលគំនិតផ្ទាល់ខ្លួនរបស់អ្នកជំនាញណាតែម្នាក់នោះទេ។

ដូចគ្នានេះដែរ អាយស៊ីស៊ី អង្គរ សូមសង្កត់ធ្ងន់ទៅលើភាពចាំបាច់ដាច់ខាត ដោយមិនត្រូវធ្វើអន្តរាគមន៍ណាមួយដែលមានទ្រង់ទ្រាយធំ (ដូចជាការរុះរើថ្មនៃរចនាសម្ព័ន្ធប្រាសាទណាមួយ ទោះបីជារុះរើមួយផ្នែកក្តី) ដោយគ្មានការដាក់ជូនជាមុននូវសំណុំឯកសារបច្ចេកទេស ពន្យល់អំពីសំណើនៃការងារដែលត្រូវធ្វើ ជូនលេខាធិការដ្ឋាន ហើយដែលលេខាធិការដ្ឋាននឹងបញ្ជូនសំណុំឯកសារបច្ចេកទេសនេះទៅក្រុមអ្នកជំនាញ អាដហុក បន្តទៀត។

### B. អនុសាសន៍ទូទៅ

### A. ការគោរពលក្ខណៈជាទីសក្ការៈនៃរមណីយដ្ឋាន

តាំងពីបានធ្វើសំណើសុំចុះឧទ្យានអង្គរចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកមក ការប្រុងប្រយ័ត្នពិសេសត្រូវបានធ្វើចំពោះលក្ខណៈជាទីសក្ការៈនៃរមណីយដ្ឋាន។ សន្និសីទនៅទីក្រុងតូក្យូ (ឆ្នាំ១៩៩៣) និងសន្និសីទនៅទីក្រុងប៉ារីស (ឆ្នាំ២០០៣) សង្ឃឹមឲ្យមានសកម្មភាព ចលនាបំផុសបំផុលឲ្យភ្ញៀវទេសចរគោរពចំពោះលក្ខណៈជាទីសក្ការៈនេះ។ ការកើនឡើងជាប់ជាប្រចាំពីមួយឆ្នាំទៅមួយឆ្នាំនូវចំនួនភ្ញៀវទេសចរ និងការកត់សម្គាល់ឃើញជាច្រើនលើកច្រើនសារ នូវការមិនគោរពដួងព្រលឹងនៃរមណីយដ្ឋាននិងថែមទាំងមិនយល់ មិនដឹងអំពីលក្ខណៈជាទីសក្ការៈរបស់ឧទ្យាន តម្រូវឲ្យមានការចាត់វិធានការសមស្រប ដោយមានការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយដើម្បីឲ្យភ្ញៀវស្គាល់និងយល់ដឹងឲ្យបានកាន់តែប្រសើរឡើងអំពីលក្ខណៈពិសេសមួយនេះរបស់ឧទ្យានអង្គរ និងតម្រូវឲ្យចាត់វិធានការប្រកបដោយប្រសិទ្ធភាពពាក់ព័ន្ធនឹងរឿងនេះ។ អាយស៊ីស៊ី អង្គរ សូមផ្តល់អនុសាសន៍ឲ្យ

ចាត់វិធានការនេះ និងសង្ឃឹមថានឹងទទួលបានព័ត៌មានអំពីលទ្ធផលនៃវិធានការនេះនៅថ្ងៃអនាគត។

B. ការអភិរក្សថ្ម

អាយស៊ីស៊ី អង្គរ សូមកោតសរសើរចំពោះចំណាប់អារម្មណ៍កាន់តែខ្លាំងឡើងរបស់ក្រុមអន្តរជាតិ ដល់វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការងារអភិរក្សថ្ម។ អាយស៊ីស៊ី អង្គរ សូមស្វាគមន៍ជាពិសេសនូវសកម្មភាពការងាររបស់ក្រុម GACP របស់សាកលវិទ្យាល័យ ប៉ាឡែម និងរបស់ក្រុម GIZ/SCU។ អាយស៊ីស៊ី អង្គរ សូមផ្តល់អនុសាសន៍ឲ្យមានការសម្របសម្រួលនូវការងារទាំងឡាយរបស់ក្រុមទាំងនេះ ដើម្បីធ្វើមានសុខដុមភាវូបនីយកម្មនៃកម្មវិធីបណ្តុះបណ្តាលទាំងអស់។

C. ផែនការថែទាំ

ដោយយល់អំពីសារៈសំខាន់នៃការងារថែទាំនៅតាមប្រាសាទនីមួយៗក្នុងឧទ្យានអង្គរ អាយស៊ីស៊ី អង្គរ សូមផ្តល់អនុសាសន៍ជាថ្មីម្តងទៀត ពាក់ព័ន្ធនឹងភាពចាំបាច់នៃការរៀបចំផែនការថែទាំដោយក្រុមដែលទទួលបន្ទុកគម្រោងអភិរក្ស ឬជួសជុល ឬដោយអាជ្ញាធរអប្សរា។ ថវិកាត្រូវតែគ្រោងទុកជាមុនសម្រាប់ការងារនេះ ចាប់តាំងពីដំណាក់កាលដំបូងនៃការត្រៀមរៀបចំគម្រោង ហើយក៏ត្រូវធ្វើដូចគ្នាដែរចំពោះនាយកដ្ឋានផ្សេងៗនៅក្នុងអាជ្ញាធរអប្សរា។

D. ការតាមដានគម្រោង

ជាលក្ខណៈទូទៅ អាយស៊ីស៊ី អង្គរ សូមផ្តល់អនុសាសន៍ឲ្យក្រុមអ្នកជំនាញ អាដហុក ត្រូវបានពិគ្រោះយោបល់ឲ្យបានមុន មានពេលគ្រប់គ្រាន់ សម្រាប់គម្រោងដែលគ្រោងនឹងអនុវត្តដោយក្រុមផ្សេងៗ ដែលធ្វើការនៅតាមរមណីយដ្ឋាននិងប្រាសាទទាំងអស់ ហើយប្រសិនបើចាំបាច់ ទោះបីជាក្រៅពីសម័យប្រជុំ អាយស៊ីស៊ី អង្គរ ក៏ដោយ ការពិគ្រោះយោបល់ជាមួយអ្នកជំនាញ អាដហុក អាចធ្វើទៅបានតាមរយៈអ៊ីនធឺណិត ដោយឆ្លងកាត់តាមលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់ អាយស៊ីស៊ី អង្គរ (យូណេស្កូ)។

អាយស៊ីស៊ី អង្គរ ក៏សូមផ្តល់អនុសាសន៍ផងដែរឲ្យអាជ្ញាធរអប្សរាត្រូវមានតំណាងជាលក្ខណៈស្វ័យប្រវត្តិនៅក្នុងកម្រិតខ្ពស់មួយនៅពេលក្រុមអ្នកជំនាញអាដហុកចុះទៅពិនិត្យការដ្ឋានគម្រោងផ្សេងៗ (មិនមែនមានតំណាងអាជ្ញាធរអប្សរា តែនៅក្នុងការចុះទៅពិនិត្យវាយតម្លៃការដ្ឋានដែលស្ថិតនៅក្រោមបន្ទុករបស់អាជ្ញាធរអប្សរាប៉ុណ្ណោះទេ) ហើយការងារនេះគឺដើម្បីជៀសវាងរាល់ហានិភ័យទាំងឡាយដោយថាហេតុ ដែលអាចធ្វើឲ្យមានភាពចម្រូងចម្រាស់គ្នាក្នុងការចេញបទបញ្ជារវាងអ្នកពាក់ព័ន្ធទាំងអស់។

C

## អនុសាសន៍សម្រាប់ការអភិរក្ស

អាយស៊ីស៊ី អង្គរ សូមផ្តល់អនុសាសន៍៖

### ១. ស្រះស្រង់ (ការដ្ឋានអាជ្ញាធរអប្សរា)

a.វាយបំបែកចោលនូវស្រទាប់បេតុងខាងលើដែលចាស់ទ្រុឌទ្រោមទៅហើយនៅពេលបច្ចុប្បន្ននេះ។

b.ចាក់ដីបង្ហាប់ខាងក្នុង បន្ទាប់មកដាក់បន្ទះ ហ្សេអូតិចស្វាយ និងបន្ទះ ហ្សេអូហ្គ្រី ទៅតាមគោលការណ៍ដីអាមេ ដូចដែលក្រុមអ៊ីតាលីធ្លាប់បានអនុវត្តនៅក្នុងការដ្ឋានជួសជុលកសិណអង្គរវត្ត ឬដូចអ្វីដែលបានត្រៀមរៀបចំឡើង ដោយក្រុមបារាំងខ្មែរនៅក្នុងការដ្ឋានមេបុណ្យខាងលិច បែបនេះនឹងអនុញ្ញាតឲ្យជានាបាននូវលំនឹងល្អមួយ ព្រមទាំងជៀសវាងកុំឲ្យខ្សាច់ហូរចេញទៅក្រៅតាមទឹកដែលហូរជ្រោះ។

c.ជំនួសបន្ទះបេតុងអាមេខាងលើដោយរចនាសម្ព័ន្ធដែកថែបមិនច្រេះមួយ មុននឹងរៀបថ្មនៅផ្ទៃខាងលើនិងថ្មជណ្តើរចុងក្រោយ។

d.សូមអញ្ជើញក្រុមដែលទទួលបន្ទុកគម្រោងនេះ អស់រយៈពេលជាច្រើនខែមកហើយ ប្រមែប្រមូលកម្លាំងឲ្យមានប្រសិទ្ធភាពជាងមុន និងមានគុណវុឌ្ឍិជាងមុន ដើម្បីបញ្ចប់ការដ្ឋាននេះឲ្យបានឆាប់បំផុត។

### ២. លានជល់ដំរី នៅអង្គរធំ (ការដ្ឋានអាជ្ញាធរអប្សរា)

a.សូមធ្វើបញ្ចប់ការសិក្សាស្រាវជ្រាវដើម្បីទទួលបាននូវរូបភាពកាត់ទទឹងដី សំដៅទៅទទួលបានព័ត៌មានអំពីដីនិងរចនាសម្ព័ន្ធរបស់វា។

b.ស្វែងរកព័ត៌មានអំពីទ្រង់ទ្រាយពិតប្រាកដនៃរចនាសម្ព័ន្ធជញ្ជាំង និងអំពីបច្ចេកទេសខួងភ្ជាប់ជញ្ជាំងនេះ។ ក្នុងន័យនេះ អនុសាសន៍ក៏ត្រូវបានផ្តល់ជូនផងដែរឲ្យទាក់ទងក្រុមឥណ្ឌាដែលសុខចិត្តចែករំលែកបទពិសោធន៍របស់ខ្លួន ដែលធ្លាប់ទទួលបានក្នុងការងារបច្ចេកទេសខួងថ្មភ្ជាប់គ្នាក្នុងពេលដែលខ្លួនធ្វើការងារជួសជុលនៅប្រាសាទតាព្រហ្ម។

### ៣. ប្រាសាទមេបុណ្យខាងកើត (ការដ្ឋានអាជ្ញាធរអប្សរា)

a.ដុំថ្មបាយក្រៀមកាន់តែខូចខាតទៅៗ ដូច្នេះគេចាំបាច់ត្រូវរៀបចំកសាងសំណុំឯកសារឲ្យបានឆាប់ លំអិតអំពីជញ្ជាំងប្រាសាទ ហើយយើងសង្ឃឹមថា នឹងប្រើបុគ្គលិកច្រើននាក់និងសម្ភារៈបរិក្ខាសមស្រប។

b.ការរុះរើថ្មនិងពង្រឹងដុំថ្មទាំងអស់នៅតាមជ្រុងត្រូវធ្វើឲ្យបានរីកចំរើនទៅមុខ យោងទៅតាមគោលការណ៍នៃការធ្វើអន្តរាគមន៍តិចតួចបំផុត។
c.នៅក្នុងការងារអន្តរាគមន៍ពង្រឹងរចនាសម្ព័ន្ធនេះ ត្រូវគ្រោងឲ្យមានទ្រនុលទល់ទ្រសមស្រប ទប់ចម្លាក់ដំរីធំធ្ងន់ៗដែលនៅខាងលើជ្រុងនីមួយៗ។
d.ចង្អូរបង្ហូរទឹកចេញពីសម័យដើម ត្រូវលាងសំអាតឲ្យបានស្អាត និងថែទាំឲ្យបានសមស្រប។
e.ចលនាដីនៅតាមជ្រុងនីមួយៗ ត្រូវវិភាគឲ្យបានល្អ ដើម្បីជាប្រយោជន៍ក្នុងការងារពង្រឹងជ្រុងទាំងអស់។
f.អាទិភាពនៃអន្តរាគមន៍ត្រូវផ្តល់ទៅជ្រុងខាងត្បូងឈៀងខាងលិច។
g.អន្តរាគមន៍លើរចនាសម្ព័ន្ធក៏ត្រូវគ្រោងធ្វើផងដែរលើតួប៉មដែលទ្រេតនៅជាន់ទី២។ ទ្រនុលទល់ទ្រធ្វើអំពីឈើត្រូវផ្លាស់ជំនួសដោយរចនាសម្ព័ន្ធធ្វើអំពីដែកវិញ ទោះបីជាបណ្តោះអាសន្នក៏ដោយ។

៤. ប្រាសាទតាព្រហ្ម (ការដ្ឋានក្រុម ASI)
a.នៅខាងក្នុងគោបុរៈទី៣ ដុំថ្មដែលបាក់ធ្លាក់ចុះមកគរលើគ្នាសង្កត់លើជញ្ជាំងខាងលិច ហាក់ដូចជាធ្វើឲ្យជញ្ជាំងកាន់តែផ្អៀងខ្លាំងឡើងទៅខាងក្រៅ។ ដុំថ្មទាំងនេះ បន្ទាប់ពីបានកត់ត្រាជាឯកសារបានត្រឹមត្រូវហើយ គួរត្រូវយកចេញដើម្បីបន្ថយទម្ងន់ទៅលើជញ្ជាំងដែលផ្អៀងនេះ ហើយដែលអាចបណ្តាលឲ្យមានការខូចខាត។
b.លក្ខណៈរចនាសម្ព័ន្ធនៃជញ្ជាំងគោបុរៈទី៣ ត្រូវតាមដានដោយមានការយកចិត្តទុកដាក់ ហើយការវិភាគរចនាសម្ព័ន្ធត្រូវតែធ្វើឡើងដោយផ្អែកទៅលើការប្រមែប្រមូលព័ត៌មាននៅក្នុងរយៈពេលវែង។ ផ្អែកទៅលើមូលដ្ឋាននៃការស្វែងយល់អំពីលក្ខណៈរចនាសម្ព័ន្ធនៃផ្នែកនេះ ក្លោងទ្វារដែលមានហោជាងដ៏ធ្ងន់អាចនឹងត្រូវរុះរើថ្មចេញខ្លះៗ និងរៀបឡើងវិញនៅផ្នែកខាងលើ ដើម្បីជៀសវាងកុំឲ្យមានការបាក់ធ្លាក់ចុះមក អាចបង្កគ្រោះថ្នាក់ និងអនុញ្ញាតឲ្យធ្វើការពង្រឹងផ្នែកខាងក្រោមនៃរចនាសម្ព័ន្ធដែលទប់ផ្នែកខាងលើ។
c.បន្ទាប់ពីបានកត់ត្រាជាឯកសាររួចរាល់ហើយ ក្លោងទ្វារខាងត្បូងគួរតែត្រូវជួសជុលឡើងវិញ ដោយផ្អែកទៅលើមូលដ្ឋាននៃការរុះរើនិងរៀបថ្មឡើងវិញ ដោយអនុលោមទៅតាមគោលការណ៍នៃការធ្វើអន្តរាគមន៍តិចតួចបំផុត។
d.វាជាការចាំបាច់ដែលត្រូវពង្វាងផ្លូវធំក្នុងទិសពីកើតទៅលិច ដើម្បីរៀបចំទីកន្លែងមួយសម្រាប់ទទួលភ្ញៀវ។ ការសិក្សាអំពីផលប៉ះពាល់ត្រូវរួមបញ្ចូលនូវការវិភាគនៃលំហូរភ្ញៀវនិងយានយន្ត ដើម្បីធានាការរៀបរយនិងគ្រប់គ្រងភ្ញៀវនិងយានយន្តទាំងនោះឲ្យបានល្អនៅក្នុងទីកន្លែងថ្មីនោះ ហើយផ្លូវវាងចេញពីថ្នល់ក្នុងទិសពីកើតទៅលិចត្រូវតែមានទំហំតូចបំផុត។

៥. ប្រាសាទតាកែវ (ការដ្ឋានក្រុម CSA)
a.វាយតម្លៃលក្ខខណ្ឌសុវត្ថិភាពនៃរចនាសម្ព័ន្ធដែលខូចខាត កំណត់អាទិភាពការងារ ដើម្បីធានាឲ្យបាននូវកម្រិតសុវត្ថិភាពសមរម្យ។
b.បន្តកិច្ចសហប្រតិបត្តិការជាមួយក្រុម អាល្លឺម៉ង់ GACPនៅក្នុងវិស័យនៃការអភិរក្សថ្ម ការអភិរក្សចម្លាក់លឹប និងការងាររៀបចំកសាងឯកសារ។
c.ត្រួតពិនិត្យការវិវត្តទៅនៃស្នាមប្រេះតូចៗ ដែលលេចឡើងនៅតាមជ្រុងនៃជញ្ជាំង ដោយប្រើប្រព័ន្ធស្វ័យប្រវត្តិ ឬប្រព័ន្ធតាមដានដោយដៃ។ ប្រៀបធៀបចលនាទាំងនោះជាមួយសីតុណ្ហភាពខាងក្រៅ និងផ្ទៀងផ្ទាត់មើលថា តើចលនាទាំងនេះវិវត្តទៅមុខឬទេ។

៦. ប្រាំងខាងលិចនៃកសិណខាងលិចប្រាសាទអង្គរវត្ត (ការដ្ឋានក្រុម IGeS)
a.តម្រូវនិងធ្វើឲ្យផ្ទៃលើនៃកាំជណ្ដើរស្មើគ្នា ដោយជំនួស ប្រសិនបើចាំបាច់ នូវដុំថ្មភក់ដែលប្រើមិនកើតដោយថ្មថ្មី និងជួសជុលដុំថ្មភក់ដែលខូចខាតតែផ្នែកខ្លះៗប៉ុណ្ណោះ។
b.តម្រូវទីកន្លែងនិងទំហំនៃស្រទាប់ហ្សេអូតិចស្វាយ បន្ទាប់ពីរុះរើដុំថ្មទាំងអស់រួចហើយ និងជំនួសដុំថ្មបាយក្រៀមដែលប្រើប្រាស់លែងកើតដោយថ្មថ្មី។
c.សូមធ្វើការប្រុងប្រយ័ត្ន រក្សាទិដ្ឋភាពមើលពីខាងក្រៅត្រង់ជួរជណ្ដើរ រវាងការដ្ឋានរបស់ក្រុមអ៊ីតាលី ដែលកំពុងប្រព្រឹត្តទៅ និងការដ្ឋានអាដ្ឋាធរអប្សរាដែលនឹងចាប់ផ្ដើមនៅពេលខាងមុខដ៏ខ្លីនេះ។
d.សូមគិតគូរដល់ភាពខុសគ្នានៃរចនាសម្ព័ន្ធនិងភាពខុសគ្នាពីចំហៀង ត្រង់ម្ដុំដែលអាចជាកន្លែងមានស្ពានធ្វើអំពីឈើកាលពីសម័យមុន។

៧. ប្រាសាទភ្នំបាខែង (ការដ្ឋានក្រុម WMF)
a.សូមឲ្យក្រុម WMF បន្តធ្វើបញ្ជីសារពើភណ្ឌនៃដុំថ្មទាំងឡាយដែលត្រូវបានរក្សាទុកដោយអភិរក្សអង្គរក្នុងពេលដែលគេរុះរើរូបចម្លាក់ព្រះពុទ្ធ ដើម្បីសាកល្បងស្វែងរកដុំថ្មបន្ថែមដែលអាចត្រូវនឹងតួប៉មទាំង៥នៅផ្នែកខាងលើនៃប្រាសាទ។
b.សូមឲ្យក្រុម WMFដែលបច្ចុប្បន្ននេះទទួលបន្ទុកជួសជុលប្រាសាទភ្នំបាខែង ប្រមែប្រមូលធនធានថវិកាផ្ទាល់ខ្លួន ឬស្វែងរកដៃគូពីខាងក្រៅបន្ថែមទៀត ដើម្បីធ្វើការងារអភិរក្សបន្ទាន់ ពិសេសគឺអភិរក្សតួប៉មធ្វើអំពីថ្មជាង២០ដែលមាននៅជុំវិញប្រាសាទភ្នំបាខែងនេះ។

## ៨. ការដ្ឋានប្រាសាទមេបុណ្យខាងលិច (ការដ្ឋានអាជ្ញាធរអេប្សារានិងសាលាបារាំងចុងបូព៌ាប្រទេស)

a.សូមធ្វើការជួសជុលដកពិសោធន៍មួយផ្នែកនៃគ្រឹះដោយបង្ហាប់ដីអាមេ ដូចរបៀបសាងសង់ពីជំនាន់សម័យអណាចក្រខ្មែរ និងជួសជុលសាកល្បងមួយផ្នែកទៀតដោយចាក់គ្របពីលើដីបង្ហាប់នោះនូវគ្រឹះបេតុងស្មើគ្នាទាំងសងខាង។ ការជួសជុលទាំងពីរប្រភេទនេះ នឹងអនុញ្ញាតឲ្យគេធ្វើការវិភាគនៅនឹងកន្លែងអំពីការបែងចែកបន្ទុកទៅលើរចនាសម្ព័ន្ធគ្រឹះ និងជួយសម្រួលឲ្យធ្វើការសម្រេចលើយោបល់បច្ចេកទេសដែលត្រូវប្រកាន់យក។

b.បន្តរុះរើជញ្ជាំងកំផែងនិងតួប៉មជុំវិញ និងទទួលឲ្យបានលឿនបំផុតនូវការអនុញ្ញាតធ្វើកំណាយចាំបាច់នានាដើម្បីឲ្យការដ្ឋានរីកចម្រើនទៅមុខទៅតាមពេលវេលាមួយដែលកំណត់ដោយអាជ្ញាធរអេប្សារា។

c.សូមឲ្យបន្តធ្វើការប្រុងប្រយ័ត្នជាពិសេសដល់ការត្រួតពិនិត្យលើកម្រិតទឹកនៅក្នុងបារាយណ៍ ជាពិសេសនៅពេលទឹកឡើង ព្រោះថាកម្រិតទឹកក៏ពឹងផ្អែកផងដែរទៅលើការបើកទ្វារទឹកដែលស្ថិតក្រោមសមត្ថភាពរបស់ខេត្ត។

## ៩. ទីលានមុខប្រាសាទបន្ទាយស្រី (ការដ្ឋានអាជ្ញាធរអេប្សារា)

a.រៀបចំ អនុម័ត និងអនុវត្តឲ្យបានឆាប់បំផុត នូវផែនការថែទាំនិងគ្រប់គ្រងទូទៅ។ តាំងពីការងារដែលបានធ្វើកន្លងរួចជាយូរមកហើយ ដោយសាលាបារាំងចុងបូព៌ាប្រទេសនៅក្នុងប្រាសាទនេះ វាហាក់ដូចជាគ្មានប្រតិបត្តិការអភិរក្សណាផ្សេងទៀតដែលគេគ្រោងនឹងធ្វើនោះឡើយ។ ដូច្នេះអនុសាសន៍ត្រូវបានផ្តល់ជូនឲ្យធ្វើកិច្ចការដោយផ្អែកទៅលើមូលដ្ឋាននៃបញ្ជីសារពើភណ្ឌនៃដុំថ្ម និងត្រូវគ្រោងឲ្យមានកន្លែងរក្សាទុកថ្មមួយកន្លែងនៅក្នុងអគារមួយក្នុងចំណោមអគារធ្វើអំពីឈើដែលមានស្រាប់នៅខាងជើងប្រាសាទ។ កន្លែងរក្សាទុកថ្មនេះអាចនឹងមានប្រយោជន៍ទៅថ្ងៃអនាគតសម្រាប់ក្រុមណាមួយដែលចង់បន្តធ្វើការជួសជុលប្រាសាទនិងទីជុំវិញប្រាសាទនេះ។

b.គ្រប់គ្រងលំហូរភ្ញៀវទេសចរនិងវង់ទស្សនាដែលអ្នកទេសចរត្រូវធ្វើដំណើរតាម ទៅតាមការគ្រោងទុកដូចតទៅនេះ៖

-លើកស្ទួយការធ្វើផែនការទូទៅសម្រាប់រមណីយដ្ឋាននិងទីជុំវិញ ដែលពោរពេញទៅដោយព័ត៌មានល្អៗសម្រាប់អ្នកដែលចាប់អារម្មណ៍ទៅលើបរិស្ថានធម្មជាតិរបស់ប្រាសាទ។

-សម្រួលការសំអាតនិងបង្ហូរទឹកដក់ចេញ ពិនិត្យមើលប្លង់ចរាចរណ៍របស់ភ្ញៀវឡើងវិញ។

## អនុសាសន៍សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

អាយស៊ីស៊ី អង្គរ សូមផ្តល់អនុសាសន៍៖

### 1. ទីលានមុខប្រាសាទនៅក្នុងឧទ្យានអង្គរ

a.សូមឲ្យការសាងសង់អនាគតទីលានមុខប្រាសាទ នានា អនុវត្តតាមគំរូទូទៅនៃគម្រោងសាងសង់និងសៀវភៅបន្ទុកទីលានមុខប្រាសាទបន្ទាយស្រី ទាំងការងារសំណង់ (ជម្រើសនៃសម្ភារៈ ព័ណ៌ និងការរៀបចំទូទៅ) ក៏ដូចជាការងារសង្គម។

b.សូមឲ្យផែនទីលំអិតនៃការរៀបចំអនាគតទីលានមុខប្រាសាទតាព្រហ្មត្រូវបានបង្ហាញជូនអាយស៊ីស៊ី អង្គរ ដើម្បីបញ្ចូលអនុសាសន៍ខាងលើ។

### ១.១ ទីលានមុខប្រាសាទអង្គរវត្ត

a.ដើម្បីធានាការប្រើប្រាស់ឲ្យបានល្អនូវទីលានមុខប្រាសាទអង្គរវត្តដោយភ្ញៀវក្នុងរដូវភ្លៀង សូមរៀបចំប្រព័ន្ធបង្ហូរទឹកនៅក្នុងទីលានមុខប្រាសាទ និងទីជុំវិញ ដោយធ្វើយ៉ាងណាប្រុងប្រយ័ត្នឲ្យប្រព័ន្ធនោះមានសមត្ថភាពគ្រប់គ្រាន់ និងភ្ជាប់ទៅនឹងស្ថានីយសំអាតទឹកកខ្វក់។

b.ពាក់ព័ន្ធនឹងដំណើរការនិងការគ្រប់គ្រងទីលានមុខប្រាសាទនិងរចនាសម្ព័ន្ធរបស់វា សូមឲ្យមានការគ្រោងទុកនូវសេវាកម្មអគ្គិសនីមិនបំពុលបរិស្ថាន ឬក៏ភ្ជាប់ទៅនឹងបណ្តាញសេវាអគ្គិសនីរដ្ឋដែលមានលក្ខណៈច្បាស់លាស់ប្រាកដប្រជាផង និងសមរម្យផង ដើម្បីធានានូវការការពារបរិស្ថាននៅក្នុងឧទ្យានបុរាណវិទ្យា។

c.សូមឲ្យការវិវត្តប្រែប្រួលដែលអាចមានទៅថ្ងៃអនាគតចំពោះវង់ទស្សនា ទាំងវង់ទស្សនាខាងក្នុងប្រាសាទអង្គរវត្តក្តី ត្រូវបានគិតបញ្ចូលនៅក្នុងការរៀបចំសំណុំឯកសារគម្រោងចុងក្រោយ។

d.សូមឲ្យសេវាកម្មនិងអ្នកទទួលខុសត្រូវរបស់អាជ្ញាធរអប្សរាដែលមានសមត្ថភាពខាងវិស័យទេសចរណ៍ ផ្ទៀងផ្ទាត់និងបញ្ជាក់អំពីភាពសមរម្យនៃផ្ទៃដីដែលរក្សាទុកនៅក្នុងគម្រោងសម្រាប់មុខងារមិនធ្វើពាណិជ្ជកម្ម ពោលគឺសម្រាប់បដិសណ្ឋារកិច្ចភ្ញៀវ (ការត្រួតពិនិត្យ កន្លែងទុកសម្ភារៈ កន្លែងផ្តល់ព័ត៌មាន សុវត្ថិភាព កន្លែងស្តុកទុកសម្ភារៈ។ល។) យោងទៅតាមតម្រូវការជាក់ស្តែង ដើម្បីជៀសវាងកុំឲ្យគេគ្រោងទុកកន្លែងតូចពេក បើប្រៀបធៀបទៅនឹងកន្លែងដែលទុកសម្រាប់ធ្វើពាណិជ្ជកម្ម។

e.សូមឲ្យបោះបង់ចោលគំនិតប្រើក្បឿងធ្វើពីស៊ីម៉ងត៍ពណ៌បៃតងដែលស្នើឡើងសម្រាប់គ្របពីលើដំបូលអគារ ត្រូវប្រើក្បឿងបុរាណធ្វើពីដីឥដ្ឋដំនួសវិញ ដែលផលិតឡើងតាមបែបសិប្បកម្មនិងប្រើពណ៌ធម្មជាតិ។

f.សូមឲ្យការងារដែលកាន់តែល្អជាងនេះត្រូវបានធ្វើឡើង ទៅតាមសំណើនៃការដាំដើមឈើ និងរៀបចំទេសភាពក្នុងគម្រោង ដើម្បីជានាកុំឲ្យឃើញខុសគ្នាដាច់ស្រឡះរវាងការរៀបចំថ្មីនិងប្រាសាទអង្គរវត្ត។
g.ដើម្បីទុកឲ្យដើមឈើធំៗអាចដុះលូតលាស់ធំបាននៅខាងក្នុងទីលានមុខប្រាសាទ សូមឲ្យទុកដីនៅចន្លោះឆ្ងាយពីគល់ឈើយ៉ាងតិច១ម៉ែត្រ កុំចាក់កៅស៊ូ ឲ្យឫសឈើអាចដុះបានឆ្ងាយនិងជ្រៅ។
h.សូមបង្កើតក្រុមការងារពិសេសមួយដើម្បីអនុម័តនិងតាមដានគម្រោងនៅក្នុងដំណាក់កាលផ្សេងៗនៃការសិក្សានិងការអនុវត្តរួមមានការរៀបចំសំណុំឯកសារដំបូង គម្រោងដែលត្រូវអនុវត្ត ជម្រើសសម្ភារៈនិងពណ៌ ការប្រព្រឹត្តទៅនៃការដ្ឋាន ការតាមដានមើលផលប៉ះពាល់នៃការដ្ឋានទៅលើសំណល់បុរាណវិទ្យាក្រោមដី និងបេតិកភណ្ឌដើមឈើ។ល។

## ១.២ ប្រាសាទនិងទីលានមុខប្រាសាទបន្ទាយស្រី

a.រៀបចំ អនុម័ត និងអនុវត្តឲ្យបានឆាប់បំផុត នូវផែនការថែទាំនិងគ្រប់គ្រងទូទៅ។
b.ធ្វើបញ្ជីសារពើភណ្ឌនៃដុំថ្ម និងត្រូវគ្រោងឲ្យមានកន្លែងរក្សាទុកថ្មមួយកន្លែងនៅក្នុងអគារមួយក្នុងចំណោមអគារធ្វើអំពីឈើដែលមានស្រាប់នៅខាងជើងប្រាសាទ។ កន្លែងរក្សាទុកថ្មនេះអាចនឹងមានប្រយោជន៍ទៅថ្ងៃអនាគតសម្រាប់ក្រុមណាមួយដែលចង់បន្តធ្វើការជួសជុលប្រាសាទនិងទីជុំវិញប្រាសាទនេះ។
c.សំអាតនិងបង្ហូរទឹកដក់ចេញ។
d.ធ្វើផែនការទូទៅសម្រាប់រមណីយដ្ឋាននិងទីជុំវិញ ដែលពោរពេញទៅដោយព័ត៌មានល្អៗសម្រាប់អ្នកដែលចាប់អារម្មណ៍ទៅលើបរិស្ថានធម្មជាតិរបស់ប្រាសាទ។
e.ពិនិត្យមើលឡើងវិញឲ្យបានលឿនលើផែនទីចរាចរណ៍របស់ភ្ញៀវ ដោយសូមបើកឲ្យបានឆាប់នូវផ្លូវចេញត្រង់ទ្វារខាងលិចសំដៅទៅខាងត្បូង ដែលត្រូវបានបិទនាពេលនេះ ដើម្បីកុំឲ្យការខិតខំរៀបចំវាឡើងបែរជាគ្មានប្រយោជន៍។

## ២. គម្រោងក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌ (HMF)

a.សូមឲ្យក្របខណ្ឌគ្រប់គ្រងបេតិកភណ្ឌ (HMF) ទាំងមូលត្រូវបានអនុវត្តឲ្យបានឆាប់ ហើយសូមឲ្យប្រតិបត្តិការទាំងអស់ត្រូវបានតាមដានយ៉ាងប្រុងប្រយ័ត្ន។
b.ដើម្បីធ្វើឲ្យគុណភាពនិងភាពជឿទុកចិត្តបាននៃផែនទីហានិភ័យបេតិកភណ្ឌពិភពលោកអង្គរមាននិរន្តរភាព វាជារឿងសំខាន់បំផុតដែលត្រូវធ្វើបច្ចុប្បន្នភាពជាប់ជាប្រចាំនូវទិន្នន័យនៃផែនទីហានិភ័យនោះ។ ជាងនេះទៅទៀត វាជាភារកិច្ចរបស់គ្រប់នាយកដ្ឋានពាក់ព័ន្ធទាំងអស់ដែលត្រូវផ្តល់សុពលភាពលើភាពទុកចិត្តបាននៃទិន្នន័យដែល

ដាក់បញ្ចូលទៅក្នុងផែនទីហានិភ័យ (SIG)។
c.សូមឲ្យអាយស៊ីស៊ីទទួលយកសេចក្តីសម្រេចរបស់គណៈកម្មាធិការដឹកនាំគម្រោង ក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌ ដែលបានធ្វើឡើងកាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៣។

៣. គម្រោងសកម្មភាពកំសាន្ត (សម្រូតខ្សែព្ួរពីដើមឈើមួយទៅដើមឈើមួយ ជិះទូកកំសាន្ត)
សូមអនុវត្តគម្រោងសកម្មភាពកំសាន្តបែបនេះនៅក្រៅឧទ្យានបុរាណវិទ្យា។

គម្រោងសម្រូតខ្សែព្ួរពីដើមឈើមួយទៅដើមឈើមួយ (Flight of Gibbon)
a.សូមធ្វើការប្រុងប្រយ័ត្នជាប់ជានិច្ចទៅលើការរៀបចំរចនាសម្ព័ន្ធនៃគម្រោងនេះ ទោះបីជាប្រតិបត្តិករគម្រោងបញ្ជាក់ថា នឹងមិនប៉ះពាល់ ឬធ្វើឲ្យខូចខាតដល់ដើមឈើយ៉ាងណាក្តី យ៉ាងហោចណាស់ ត្រូវពិនិត្យស្ថានភាពដើមឈើយ៉ាងតិច១ដងក្នុងមួយឆ្នាំ ដើម្បីរកមើលរាល់ការវិវត្តអវិជ្ជមានទាំងឡាយដែលអាចធ្វើឲ្យខូចខាតដើមឈើក្នុងពេលកន្លងទៅ។
b.សូមឲ្យទីតាំងនៃការអនុវត្តសកម្មភាពគម្រោងនេះត្រូវបានកម្រិតត្រឹមបរិវេណប្រាសាទតាកែវ និងបារាយណ៍ខាងកើត។

គម្រោងជិះទូកកំសាន្តនៅក្នុងស្ទឹងសៀមរាប
a.សូមឲ្យការត្រួតពិនិត្យជាប់ជាប្រចាំអនុញ្ញាតឲ្យធ្វើការប្រុងប្រយ័ត្នបំផុតដែលអាចធ្វើទៅបាន ជៀសវាងសកម្មភាពនេះធ្វើឲ្យជ្រាំងឬបាតស្ទឹងសឹករិចរិល។ ក្នុងករណីដែលពិនិត្យឃើញមានផលអវិជ្ជមាន សូមឲ្យផ្តល់ព័ត៌មានជូន អាយស៊ីស៊ី និងចាត់វិធានការដែលចាំបាច់។
b.សូមឲ្យគុណភាពទឹក វត្តមានជាយថាហេតុនៃប៉ារ៉ាស៊ីត ឬសត្វល្អិតមិនល្អនៅក្នុងទឹក ការដើរពាសវាលពាសកាលអាវ៉ាសែរបស់សត្វផ្សេងៗ ត្រូវបានត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នមុននឹងអនុញ្ញាតឲ្យអនុវត្តគម្រោងនេះ។

កំពង់ភ្លុក
សូមឲ្យមានការពិភាក្សាស៊ីជម្រៅរវាងរដ្ឋបាលខេត្ត អាជ្ញាធរមូលដ្ឋាន ផ្នែកឯកជន និងអាជ្ញាធរអប្សរា ដើម្បីការពារតម្លៃវប្បធម៌និងធម្មជាតិនៃភូមិកំពង់ភ្លុកនេះដែលមានលក្ខណៈល្អឯកគ្មានពីរ។

## ៦.១. ការអនុម័តពង្រាងអនុសាសន៍ដែលបានពិនិត្យដោយសម័យប្រជុំបច្ចេកទេសកន្លងទៅ

**លោក រីឆាដ៍ ម៉ាយេះ**
លោកសហប្រធាន ខ្ញុំចង់លើកសំណើមួយចំណុច ពីព្រោះព្រឹកមិញនេះ យើងអត់មានពេល គឺចំណុចលេខ២ ពាក់ព័ន្ធនឹងអនុសាសន៍របស់អ្នកជំនាញអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលខ្ញុំសូមថ្លែងអំណរគុណចំពោះប្រឹក្សា និងការចូលរួមវិភាគទានរបស់ពួកគេ។ ខ្ញុំបានកត់ត្រាថា នៅក្នុងពេលធ្វើសុន្ទរកថាបើកសម័យប្រជុំពេញអង្គ ឯកឧត្តមបណ្ឌិត សុខ អាន បានលើកឡើងអំពីកិច្ចប្រជុំនៅថ្ងៃទី២ ខែធ្នូ ក្នុងសប្ដាហ៍នេះ ហើយបើមានការយោគយល់ពីឯកឧត្តម ខ្ញុំជឿថាវាស័ក្តិសមគួរគិតផងដែរដល់សន្និសីទអន្តររដ្ឋាភិបាល ដែលនឹងរៀបចំឡើងនៅថ្ងៃស្អែក ហើយសូមបន្ថែមចំណុចc.មួយទៀតដល់អនុសាសន៍លេខ២។ ចំណុចនេះ និយាយអំពីសេចក្ដីសម្រេចរបស់គណៈកម្មាធិការដឹកនាំគម្រោង HMF ពីព្រោះខ្ញុំគិតថា វាបំពេញបន្ថែមបានយ៉ាងល្អដល់ចំណុចនេះ។
សូមអរគុណ លោកសហប្រធាន។

**លោក ហ្វីលីព ដឺឡង់ហ្គ័៖**
ចំណុចបំភ្លឺមួយសម្រាប់ក្រុម HMF លេខាធិការដ្ឋានបានកត់ត្រាទុកសម្រាប់ធ្វើការពិនិត្យពិចារណាហើយ។

**សហប្រធានជប៉ុន៖**
តើការពន្យល់នេះសមរម្យទេសម្រាប់វាគ្មិនដែលទើបនឹងមានប្រសាសន៍? ខ្ញុំគិតថាវាសមរម្យហើយ។
សូមអញ្ជើញលោកមានប្រសាសន៍។

**លោក ប្រ៊ុយណូ ហ្វាវ៉េល៖**
សូមអរគុណលោកសហប្រធានឯកអគ្គរដ្ឋទូត។ នៅក្នុងផ្នែកអភិវឌ្ឍន៍ប្រកបដោយចីរភាព ចំណុចស្ដីពីសកម្មភាពកំសាន្តសកម្ម ការកំសាន្តដែលសម្រួតតាមខ្សែព្ធរពីដើមឈើមួយទៅដើមឈើមួយ ការជិះទូកកំសាន្តនៅក្នុងស្ទឹង ត្រង់ចំណុច a. ជាភាសាបារាំង វាមានភាពមិនច្បាស់លាស់មួយដែលខ្ញុំចង់លើកឡើង៖ "សូមអនុវត្តគម្រោងសកម្មភាពកំសាន្តទាំងនេះ ប្រសិនបើអាចទៅរួច ..."។ "ប្រសិនបើអាចទៅរួច" ពាក្យនេះមិនស័ក្តិសមទេ យើងខ្ញុំចង់សរសេរបែបនេះវិញ "សូមអនុវត្តគម្រោងសកម្មភាពកំសាន្តទាំងនេះនៅក្រៅឧទ្យានបុរាណវិទ្យា។ ពាក្យ "ប្រសិនបើអាចទៅរួច" ត្រូវតែលុបចេញ ប្រសិនបើអាច។ សូមអរគុណ។

សហប្រធានជប៉ុន៖ ខ្ញុំមើលទៅវាហាក់ដូចជាចោទជាបញ្ហា ដូច្នេះសូមលុបពាក្យទាំងនេះចេញ។ តើមានមតិយោបល់អ្វីផ្សេងទេ? ខ្ញុំគិតថាគ្មានទេ។ ខ្ញុំគិតថាសម័យប្រជុំពេញអង្គត្រៀមខ្លួនរួចហើយនឹងអនុម័តអនុសាសន៍ទាំងនេះ។ ដូច្នេះគឺអនុម័ត។ សូមអរគុណ។

**សហប្រធានបារាំង៖**
សូមអភ័យទោស ឯកឧត្តមសហប្រធាន គ្រាន់តែចង់បញ្ជាក់ថាចំនុច ៦. នៃអនុសាសន៍លេខ៣ គ្មានប្រយោជន៍ទៀតទេប្រសិនបើយើងលុបពាក្យ "ប្រសិនបើអាចធ្វើទៅបាន"។ តែប៉ុណ្ណឹងឯង។ សូមអរគុណ។

**សហប្រធានជប៉ុន៖**
ល្អណាស់។ តើយើងឯកភាពទេ? ឯកភាព។ ដូច្នេះយើងអនុម័តអនុសាសន៍ទាំងនេះ។ សូមឆ្លងចូលដល់ចំណុចកាលបរិច្ឆេទសម័យប្រជុំបច្ចេកទេស។ សូមអញ្ជើញលោកមានប្រសាសន៍។

## ៦.២. កាលបរិច្ឆេទសម័យប្រជុំបច្ចេកទេសលើកក្រោយ

**លោក អាហ្សេឌីន បេសាអ៊ីសះ**
ឯកឧត្តមសហប្រធាន ជាទូទៅគឺនៅខែមិថុនា។ ប្រសិនបើយើងធ្វើតាមទម្លាប់ល្អដែលយើងធ្លាប់ធ្វើកន្លងរួចមកហើយ យើងមិនកំណត់ថ្ងៃពិតប្រាកដនោះទេ ប៉ុន្តែយើងកំណត់សប្តាហ៍ណាមួយដើម្បីអនុញ្ញាតឲ្យឯកឧត្តមសហប្រធានទាំងពីរ ទៅតាមកាលវិភាគរបស់ឯកឧត្តម ទៅតាមកាលវិភាគរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៅតាមកាលវិភាគរបស់រាជរដ្ឋាភិបាល ក្នុងការជ្រើសរើសកាលបរិច្ឆេទណាមួយ។ ជាទូទៅ យើងស្នើឡើងពីរសប្តាហ៍ចុងក្រោយនៃខែមិថុនា បន្ទាប់មករវាងឯកឧត្តម និងការិយាល័យអង្គការយូណេស្កូ ឯកឧត្តមជ្រើសរើសកាលបរិច្ឆេទពិតប្រាកដណាមួយចំនួន២ថ្ងៃ។

ប្រសិនបើឯកឧត្តមមិនយល់ទាស់ទេ យើងសូមស្នើពីរសប្តាហ៍ចុងក្រោយនៃខែមិថុនា ឆ្នាំ២០១៤។ អស់រយៈពេលជាង៧-៨ឆ្នាំមកហើយដែលយើងធ្វើបែបនេះ ហើយកាលបរិច្ឆេទពិតប្រាកដនឹងត្រូវផ្តល់ជូនដោយការិយាល័យអង្គការយូណេស្កូ ទៅតាមការឯកភាពរបស់រាជរដ្ឋាភិបាល និងតំណាងរាជរដ្ឋាភិបាល គឺឯកឧត្តមបណ្ឌិត សុខ អាន និងសហប្រធានទាំងពីរ ដែលកំណត់ថ្ងៃពិតប្រាកដ ដូចជាថាថ្ងៃទី៧ ថ្ងៃទី១២ឬថ្ងៃទី១៥ជាដើម។ល។

ប្រសិនបើឯកឧត្តមឯកភាព យើងកត់ត្រាទុកថា នឹងយកពីរសប្តាហ៍ចុងក្រោយនៃខែមិថុនា ឆ្នាំ២០១៤។

ប៉ុន្តែ ឯកឧត្តមសហប្រធាន មានថ្ងៃមួយ នាយកមជ្ឈមណ្ឌលក៏នៅទីនេះ ហើយអតីតប្រធានក៏នៅទីនេះដែរ៖ លោកទាំងពីរត្រូវធ្វើដំណើរទៅប្រទេសកាតារ ពីព្រោះមុនថ្ងៃ១៥ ខែមិថុនា នឹងមានការរៀបចំនៅប្រទេសកាតារ នូវសម័យប្រជុំលើកទី៣៨ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក។ ដូច្នេះ យើងអាចថា យកសប្តាហ៍ទី១នៃខែមិថុនា ឆ្នាំ២០១៤វិញ។ ហើយកាលបរិច្ឆេទពិតប្រាកដនឹងបញ្ជាក់ជូនដោយការិយាល័យអង្គការយូណេស្កូ។

**សហប្រធានជប៉ុន៖**

ដូច្នេះយើងស្នើឡើងសប្តាហ៍ទី១នៃខែមិថុនា។ តើយើងឯកភាពលើកាលបរិច្ឆេទនេះទេ? ពិតណាស់កាលបរិច្ឆេទពិតប្រាកដនឹងបញ្ជាក់ជូនឲ្យបានឆាប់បំផុតដែលអាចធ្វើទៅបានទៅតាមពេលទំនេររបស់អ្នកចូលរួម។ លោក បេសាអ៊ូស ដូច្នេះយើងឯកភាពគ្នាលើសប្តាហ៍ទី១នៃខែមិថុនា សម្រាប់សម័យប្រជុំបច្ចេកទេស អាយស៊ីស៊ី អង្គរ លើកក្រោយ។ សូមអរគុណ។

**លោក អាហ្សេឌីន បេសាអ៊ូស៖**

ដូច្នេះ យើងបានបញ្ចប់ហើយ។ សូមអរគុណ លោកសហប្រធាន សូមអរគុណចំពោះការអត់ធ្មត់របស់លោក។ សហប្រធានជាទីគោរព យើងយឺត៧នាទី ប្រហែលជាមិនច្រើនប៉ុន្មានទេ ប៉ុន្តែនៅពេលដែលយើងត្រូវតាមឲ្យទាន់ពេលដែលយឺតខ្លាំងអម្បាញ់មិញវាធ្វើឲ្យយើងភ័យខ្លាំងណាស់។ ឥឡូវនេះ គឺសហប្រធានជាទីគោរពនេះហើយដែលត្រូវបិទបញ្ចប់ការងាររបស់យើង។

**សហប្រធានបារាំង៖**

សូមអរគុណច្រើន។ យឺត៧នាទី សម្រាប់រយៈពេល២០០០ឆ្នាំនៃប្រវត្តិសាស្ត្រឬក៏លើសពីនេះទៅទៀត ខ្ញុំជឿថាគេនឹងមិនប្រកាន់យើងទេ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដូច្នេះយើងនៅសល់តែកម្មវិធីបិទបញ្ចប់ការងារសម័យប្រជុំពេញអង្គលើកទី២០នៃ អាយស៊ីស៊ីអង្គរ របស់យើងតែប៉ុណ្ណោះ ដូច្នេះដើម្បីបិទបញ្ចប់នេះខ្ញុំសូមផ្តល់វេទិកានេះជូនឯកឧត្តម យូយី កាម៉ាម៉ារ៉ូ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា។ យូយី សូមអញ្ជើញមានប្រសាសន៍។

# ៧. ពិធីបិទអង្គប្រជុំ

## ៧.១. សុន្ទរកថាសហប្រធានជប៉ុន ឯកឧត្តម យូយី គូម៉ាម៉ារូ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

សូមគោរពឯកឧត្តមបណ្ឌិត សុខ អាន ឧបនាយករដ្ឋមន្ត្រីនិងជាប្រធានអាជ្ញាធរអប្សរា។
សូមគោរពលោក កុល ប៊ុនលី ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ។
សូមគោរពលោក ស៊ែហ្ស ម៉ូស្សូរ៉ា ឯកអគ្គរដ្ឋទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា។
សូមគោរពលោក គីស័រ រ៉ាវ នាយកមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ។
សូមគោរពលោកស្រី អាន ឡឺម៉ែត្រ តំណាងអង្គការយូណេស្កូប្រចាំព្រះរាជាណាចក្រកម្ពុជា។
សូមគោរពភ្ញៀវកិត្តិយស តំណាងរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងតំណាងស្ថាប័នទាំងអស់។
សូមគោរពលោក លោកស្រីទាំងអស់ជាទីគោរព។

ជាការចាប់ផ្តើម ក្នុងនាមសហប្រធាននៃសម័យប្រជុំពេញអង្គនេះ ខ្ញុំសូមសម្តែងនូវអំណរគុណដ៏ស្មោះស្ម័គ្ររបស់ខ្ញុំចំពោះអ្នកចូលរួមទាំងអស់ ចំពោះការចូលរួមវិភាគទានដ៏សកម្មរបស់ឯកឧត្តម លោកជំទាវ ដល់កិច្ចពិភាក្សាទាំងឡាយ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់សហប្រធានរបស់ខ្ញុំនៅក្នុងកិច្ចប្រជុំនេះគឺឯកឧត្តម ស៊ែហ្ស ម៉ូស្សូរ៉ា ចំពោះការគាំទ្រដ៏មានប្រយោជន៍របស់លោក និងការងារសម្របសម្រួលរបស់លោក ព្រមទាំងសូមអរគុណដល់លេខាធិការដ្ឋាន អាយស៊ីស៊ី អង្គរ ចំពោះការងារត្រៀមរៀបចំកិច្ចប្រជុំនេះឡើង។

សូមអរគុណដល់អ្នកទាំងអស់គ្នាចំពោះការគាំទ្រនិងកិច្ចសហប្រតិបត្តិការ។ ខ្ញុំជឿថា យើងអាចគិតថា សម័យប្រជុំនេះបានទទួលជោគជ័យ។ សូមអរគុណដល់អ្នកទាំងឡាយណាដែលបានធ្វើបទបង្ហាញអំពីការងារកិច្ចសហប្រតិបត្តិការរបស់ពួកគេ និងគោរពទៅតាមពេលម៉ោងដែលបានកំណត់ជូន។ សហប្រធានទាំងពីរមានសេចក្តីសោកស្តាយ ដែលយើងគ្មានពេលសម្រាប់ធ្វើការពិភាក្សាឲ្យបានយូរអំពីប្រធានបទនីមួយៗ ប៉ុន្តែខ្ញុំជឿថា ទោះជាយ៉ាងណាក៏ដោយ យើងក៏មានការពិភាក្សាល្អអំពីចំណុចជាច្រើនដែរ។ ខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំងដែលយើងបានពិភាក្សាគ្នាទៅលើប្រធានបទជាច្រើនដូចជាបច្ចេកវិទ្យាថ្មីៗ ការជួសជុល ការគ្រប់គ្រងទឹក ហើយដែលការពិភាក្សានីមួយៗរបស់យើងបាននាំទៅកាន់ចក្ខុវិស័យសម្រាប់អនាគត។

ជាពិសេស ខ្ញុំរីករាយជាពន់ពេក ដែលដូចសព្វមួយដងដែរ យើងបានអនុម័តនៅក្នុងសម័យប្រជុំពេញអង្គនេះ នូវអនុសាសន៍ល្អៗដែលត្រូវបានត្រៀមរៀបចំដោយអ្នកជំនាញ អាដហុក និងពិនិត្យមើលដោយសម័យប្រជុំបច្ចេកទេសរបស់ អាយស៊ីស៊ី។ ខ្ញុំសូមឲ្យអ្នកដែលពាក់ព័ន្ធទាំងអស់គោរពនិងអនុវត្តតាមអនុសាសន៍ទាំងនេះ ហើយស្នើឲ្យ អាយស៊ីស៊ី អង្គរ ធ្វើការត្រួតពិនិត្យនិងតាមដានការអនុវត្តអនុសាសន៍ទាំងនេះឲ្យបានម៉ត់ចត់។

ខ្ញុំបានកត់សម្គាល់ ឃើញប្រកបដោយក្តីរីករាយផងដែរថា ពង្រាង អនុសាសន៍និងសេចក្តីថ្លែងការណ៍របស់សន្និសីទអន្តររដ្ឋាភិបាលលើកទី៣ ត្រូវបានចែកជូនឯកឧត្តម លោកជំទាវរួចហើយ។ ស្អែកនេះយើងនឹងបន្តការពិភាក្សារបស់យើងអំពីរឿងនេះ។

ថ្ងៃស្អែកគឺជាថ្ងៃមួយដែលចារិកនៅក្នុងប្រវត្តិសាស្ត្ររបស់ អាយស៊ីស៊ី អង្គរ ពីព្រោះវាជាថ្ងៃសន្និសីទអន្តររដ្ឋាភិបាលលើកទី៣ ដែលរៀបចំឡើងនៅកម្ពុជា លើកទី១ បន្ទាប់ពី២០ឆ្នាំបានកន្លងផុតទៅ ក្រោយពីសន្និសីទស្ថាបនិកនៅទីក្រុងតូក្យូនៅឆ្នាំ១៩៩៣ និង១០ឆ្នាំក្រោយពីសន្និសីទអន្តររដ្ឋាភិបាលលើកទី២ស្តីពីអង្គរនៅក្រុងប៉ារីស៍នៅឆ្នាំ២០០៣។ ខ្ញុំសូមសម្តែងនូវក្តីសង្ឃឹមយ៉ាងមុតមាំថា យើងនឹងមានការពិភាក្សាដ៏ផុសផុល ផ្តោតទៅលើលទ្ធផលនៃសម័យប្រជុំ អាយស៊ីស៊ី នេះ ក៏ដូចជាទៅលើជំនាញនិងបទពិសោធន៍ដែលទទួលបានកន្លងមក រួមគ្នាតាំងពី២០ឆ្នាំមកហើយ។

ដើម្បីប្រារព្ធឱកាសដ៏ល្អវិសេសនេះ ពោលគឺខួបលើកទី២០នៃអាយស៊ីស៊ី អង្គរ ប្រទេសជប៉ុនដែលជាសហប្រធានរបស់ អាយស៊ីស៊ី បានអញ្ជើញក្រុមតន្ត្រី AUNJ ដែលមានតន្ត្រីករល្បីៗមកពីជប៉ុន ឲ្យមកសម្តែងនៅលើឆាករៀបចំជាពិសេសនៅប្រាសាទអង្គរវត្ត។ នៅរាត្រីនេះពួកគេនឹងសម្តែងការប្រគំតន្ត្រីដ៏អស្ចារ្យបំផុត ដោយសហការជាមួយតន្ត្រីករល្បីៗរបស់កម្ពុជា ថៃ ឥណ្ឌូណេស៊ី និងវៀតណាម។ ព្រឹត្តិការណ៍ដ៏ល្អឯកនេះក៏នឹងជាឱកាសមួយដែរនៅឆ្នាំ២០១៣នេះ សម្រាប់ប្រារព្ធខួបលើកទី៦០នៃមិត្តភាពខ្មែរ ជប៉ុន។

បន្ទាប់ពីការប្រគំតន្ត្រីនោះទៅ យើងនឹងមានរៀបចំពិធីលៀងសាយភោជនមួយនៅសណ្ឋាគារ Le Meridien Angkor។ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាពន់ពេក ដោយសូមអញ្ជើញយ៉ាងកក់ក្តៅអ្នកចូលរួមនៅក្នុងសម័យប្រជុំពេញអង្គ អាយស៊ីស៊ី អង្គរ ទាំងអស់គ្នាទៅចូលរួមក្នុងកម្មវិធីនេះ។

ខ្ញុំសូមបិទបញ្ចប់ ដោយសូមសម្តែងនូវអំណរគុណយ៉ាងស្មោះស្ម័គ្រជាថ្មីម្តងទៀតដល់ឯកឧត្តម លោកជំទាវទាំង

អស់គ្នាចំពោះវិភាគទានដ៏ល្អអស្ចារ្យរបស់ឯកឧត្តម លោកជំទាវនៅក្នុងកិច្ចប្រជុំអាយស៊ីស៊ី ប្រកបដោយជោគជ័យនេះ។ សូមអរគុណ។

**សហប្រធានបារាំង៖**

សូមអរគុណឯកឧត្តម លោកជំទាវទាំងអស់គ្នា ហើយតាមខ្លឹមសារដ៏គួរឲ្យលើកទឹកចិត្តនេះ ខ្ញុំសុំបិទអង្គប្រជុំតែត្រឹមនេះ។

*** ចប់សម័យប្រជុំពេញអង្គ អាយ ស៊ី ស៊ី អង្គរ លើកទី២០ ***

# បញ្ជីអ្នកចូលរួម

| លរ | ឈ្មោះ | ឋានៈ | អង្គការ | ទំនាក់ទំនង |
|---|---|---|---|---|
| 1 | André Pouillès-Duplaix | Directeur régional | AFD | AFDPhnomPenh@groupe-afd.org |
| 2 | Adelbert EBERHARDT | country director GIZ | GIZ/SCU | |
| 3 | AIM Chamroeun | | APSARA National Authority | 012 440 282 |
| 4 | AING Sovannroath | Deputy Secretary General | Ministry of Tourism | |
| 5 | AN Raksmey | Staff | JST | info@jst-cambodia.net |
| 6 | AN Sopheap | Dept. of Conservation of Monument and Archaeology | APSARA National Authority | 089 801 111 |
| 7 | Andrey VLADIMIROV | Deputy Head of Mission | Embassy of Russian Federation | |
| 8 | ANG Pheakdey | Department of Finance | APSARA National Authority | |
| 9 | Anne de COLBERT CHRISTOPHOROV | | APSARA National Authority | |
| 10 | Anne LEMAISTRE | UNESCO Representative in Cambodia | UNESCO Phnom Penh | a.lemaistre@unesco.org |
| 11 | Anne-Julie Peycam | Intern | UNESCO Phnom Penh | aj.peycam@unesco.org |
| 12 | Antonio RAVA | Professor | University of Palermo | antonio.ravaec@gmail.com |
| 13 | Aurélie Filippetti | Ministre | Ministre de la Culture et de la Communication | |
| 14 | Ayesha Fuentes | | | |
| 15 | Azedine BESCHAOUCH | ICC Scientific Secretary | UNESCO | azedinebeschaouch@hotmail.com |
| 16 | B.R.Mani | Additional Director General | ASI New Delhi | brmani@hotmail.com |
| 17 | BAEK Kyounghwan | | Korea Cultural Heritage Foundation | |
| 18 | BENG Born | Forestry,Cultural Landscape & Environment | APSARA National Authority | 012 313 923 |

| | | | | |
|---|---|---|---|---|
| | | Management Dept. | | |
| 19 | Bernard WILLINGER | | VEOLIA | |
| 20 | Bertrand PORTE | Archaeologist | EFEO | bertrandporte@yahoo.fr |
| 21 | Bill CARTER | Researcher | Ministry of Tourism | bcater@vsc.edu.au |
| 22 | BIN Sambatharath | | Ministry of Land Management | |
| 23 | Blaise KILIAN | ICC Secretariat | UNESCO Phnom Penh | b.kilian@unesco.org |
| 24 | BOUN Lim Heng | Department of Finance | Council of Ministers | |
| 25 | Brent Rapson | First Secretary | Embassy of New Zealand | brent.rapson@mfat.govt.nz |
| 26 | Bruno Favel | Chef du département | Ministère de la Culture | bruno.favel@culture.gouv.fr |
| 27 | BUN Narith | Director General | APSARA National Authority | b_narith@yahoo.com |
| 28 | BUN Tharith | Vice-Governor | Siem Reap Province | |
| 29 | BY Sopheap | Public Order & Cooperation Dept. | APSARA National Authority | |
| 30 | Cedric BOLLORÉ | Délégation | M. Bolloré | |
| 31 | CHAN Tani | Secretary of State | Council of Ministers | chantanim@gmail.com |
| 32 | CHAN Vathana | Department Director | APSARA National Authority | |
| 33 | CHAU SUN Kérya | ICC Secretariat | APSARA Authority | apsara.ddta@online.com.kh |
| 34 | CHEA Kosal | Cabinet Director | Ministry of Tourism | |
| 35 | CHEA Nol | Representative | JST | info@jst-cambodia.net |
| 36 | CHEA Sophat | Deputy-Director | Heritage Police | 011 863 325 |
| 37 | CHEAM Phally | Project Architect | World Monuments Fund | phallysiemreap@yahoo.com |
| 38 | CHEAN Sokpheaktra | Cultural Development, Museum & Heritage | APSARA National Authority | 092 400 436 |

| | | | | |
|---|---|---|---|---|
| | | Dept. | | |
| 39 | CHHAY Sokhahelene | Water Management Dept. | APSARA National Authority | 077 440 783 |
| 40 | CHHEAN Ratha | Deputy Director of Department | APSARA National Authority | 017 616 100 |
| 41 | CHHEUM Serey Vattanak | Cultural Development, Museum & Heritage Dept. | APSARA National Authority | |
| 42 | CHHIEU Nam | Deputy Director of Department | APSARA National Authority | |
| 43 | CHHIM Sokunthea | Dept. of Community and Agricultural Development | APSARA National Authority | |
| 44 | CHHIV Yiseang | Interpreter French-Khmer | APSARA Authority | yiseangch@yahoo.com |
| 45 | CHHONG Vira | Deputy Director of Department | APSARA National Authority | |
| 46 | CHHOR Thanat | Deputy-Director General | APSARA National Authority | |
| 47 | CHHORN Sopheap | | Ministry of Finance | |
| 48 | Chie ABE | Researcher | Sophia University | yoshia-i@sophia.ac.jp |
| 49 | CHOEURN Chean | Governor | Angkor Thom District | 012 949 784 |
| 50 | CHOURN Bunnath | Technical Support & Inter-Sector Project Dept. | APSARA National Authority | 012 459 658 |
| 51 | Christian VERNAY | Head of International Relations | SIAAP | Christian.VERNAY@siaap.fr |
| 52 | Christiane Garnero Morena | Expert | ICOMOS | garneromorena@gmail.com |
| 53 | Christophe Pottier | Archaeologist | EFEO | christophe.pottier@efeo.net |
| 54 | CHRUN Sophal | Department Director | APSARA National Authority | 067 678 888 |
| 55 | CHUCH Phoeurn | President | National Authority for Preah Vihear | chuch_phoeun@yahoo.com |
| 56 | CHUM Kim Leng | Monk in Siem Reap | APSARA National Authority | |

| | | | | |
|---|---|---|---|---|
| 57 | Claude JACQUES | Professor | HUNINCO | claude.jacques@sfr.fr |
| 58 | Clotilde LE COZ | Délégation | M. Bolloré | |
| 59 | CUNIN Olivier | | APSARA National Authority | oc.angkor@gmail.com |
| 60 | D.S. Sood | Team Leader | ASI Siem Reap | dssood2006@gmail.com |
| 61 | Dave GORDGE | First Secretary | Embassy of Australia | Dave.Gordge@dfat.gov.au |
| 62 | David RORKE | Interpreter English-French | UNESCO | emikostock@yahoo.com |
| 63 | David SANDILANDS | Depl. & Nutrition Manager | ADF | sandilands.david@gmail.com |
| 64 | DE ROCHECHOUART DE MORTEMART Rima | | APSARA National Authority | |
| 65 | DENG Sambath | Department of Administration | APSARA National Authority | 016 853 383 |
| 66 | DEP Sothon | Dept. of Tourism | APSARA National Authority | |
| 67 | Diane CAROEN | Senior Advisor | ADDA | mailto:dianecaroen@adda-cambodia.org |
| 68 | Didier MARGINEDES | Délégation | M. Bolloré | |
| 69 | Dinesh K. Patnaik | Ambassador | Embassy of India | |
| 70 | DOM Hak | Deputy-Director General | APSARA National Authority | |
| 71 | Dominique ROBLIN | Director | SIAAP | |
| 72 | Dominique SOUTIF | Archaeologist | EFEO | dominique.soutif@gmail.com |
| 73 | Dóra Egyházi | | HUNINCO | dora.egyhazi@gmail.com |
| 74 | DOUNG Sreita | | National Committee for World Heritage | |
| 75 | EA Darith | Deputy Director of Department | APSARA National Authority | 092 975 759 |
| 76 | Edgar Pang | Deputy Chief of Mission & Counsellor | Embassy of the Republic of Singapore | edgar_pang@mfa.gov.sg |

| | | | | |
|---|---|---|---|---|
| 77 | EK Tha | Deputy Director of Department | Council of Ministers | |
| 78 | Emmanuel MENANTEAU | Directeur général | Cambodia Airports | emmanuel.menanteau@cambodia-airports.aero |
| 79 | Emmeline DECKER | Diploma Restorer | GACP | |
| 80 | Eric Bourdonneau | Archaeologist | EFEO | eric.bourdonneau@efeo.net |
| 81 | Esther von Plehwe-LEISEN | Conservation Scientist Dipl.-Rest | GACP | |
| 82 | Francine d'Orgeval | expert auprès de la sous-direction de la recherche et des échanges scientifiques | Ministère des Affaires étrangères | |
| 83 | Franciscus Verellen | Directeur de l'Ecole Française d'Extrême Orient | EFEO | |
| 84 | Franciscus Verellen | Archaeologist | EFEO | franciscus.verellen@gmail.com |
| 85 | Franck Chaumont | Conseiller communication | Cabinet du Ministre | |
| 86 | François LEGRAND | | AAA | francois.legrand@cegetel.net |
| 87 | Gabriella D'AGOSTINO | Professor | University of Palermo | gabriella.dagostino@unipa.it |
| 88 | Georgina LIOYD | Siem Reap Project Officer | Heritage Management Framework | georgina.lloyd@sydney.edu.au |
| 89 | Ginevra BOTTO | Project Manager | World Monuments Fund | kvzmuehlen@wmf.org |
| 90 | Giorgio CROCI | Ad hoc Expert for conservation | UNESCO | mail@giorgiocroci.com |
| 91 | Giovanni RIZZO | Professor | University of Palermo | giovanni.rizzo@unipa.it |
| 92 | Glenn Boornazian | Project Director | World Monuments Fund | gboornazian@icr-icc.com |
| 93 | Gloria LEE | Intern | UNESCO Phnom Penh | gl.lee@unesco.org |
| 94 | Guo Huadong | Director of HIST and RADI | HIST | |
| 95 | HAB Touch | Director General | Ministry of Culture and Fine Arts | habtouch@yahoo.com |
| 96 | HANG Peou | Deputy-Director General | APSARA National Authority | hangpeou@yahoo.com |

| | | | | |
|---|---|---|---|---|
| 97 | Hans LEISEN | Project Director | GACP | hans.leisen@fh-koeln.de |
| 98 | HEAM Dyvisa | Urban Heritage Development Dept of Siem Reap | APSARA National Authority | 092 915 175 |
| 99 | Hedwige MULTZER | | | hedangkor1@yahoo.fr |
| 100 | Heigo NAKAFUSA | Deputy Director | Ministry of Foreign Affairs | |
| 101 | Helen Ibbitson Jessup | | FOKCI | h.i.jessup@att.net |
| 102 | Helene JARVIS | Advisor | Council of Ministers | helenjarvis@online.com.kh |
| 103 | HEM Sinath | Department Director | National Authority for Preah Vihear | |
| 104 | HEM Yany | Deputy Director of Department | APSARA National Authority | |
| 105 | HENG Jeudi | Technical Support & Inter-Sector Project Dept. | APSARA National Authority | hengjeudi@yahoo.com |
| 106 | HENG Kim Leng | Department Director | APSARA National Authority | |
| 107 | HENG Sophdy | Deputy Director of Department | Ministry of Culture and Fine Arts | |
| 108 | HENG Than | International Center for Research and Documentation of Angkor | APSARA National Authority | |
| 109 | Hiroko KAIZUKA | Senior Deputy Director | Ministry of Foreign Affairs | |
| 110 | HOK Peng Sè | Department Director | APSARA National Authority | 012 323 997 |
| 111 | HOR Ritheanou | Office Director General | APSARA National Authority | rt_nou@yahoo.com |
| 112 | Hou Nolamony | | GOPURA II | |
| 113 | HOU weidong | Chief engineer | CSA | houweidong@263.net |
| 114 | Hun BUNWAT | National Project Coordinator | World Monuments Fund | |
| 115 | Huo Sijia | Programme Assistant | HIST | |
| 116 | HUY Bouy | | APSARA National Authority | 012 52 02 88 |

| | | | | |
|---|---|---|---|---|
| 117 | Hyeonok Yoo | ODA Researcher | Korea Cultural Heritage Foundation | yoohyeonok@gmail.com |
| 118 | Igor KOSTYUCHENKO | second secretary | Embassy of Russian Federation | |
| 119 | IM Lim | Interpreter French-Khmer | APSARA Authority | imlim03@yahoo.fr |
| 120 | IM Sithol | Under Secretary of State-PCM | Council of Ministers | |
| 121 | IM Sokrithy | Deputy Director of Department | APSARA National Authority | 012 943 202 |
| 122 | Ishimura TOMO | Archaeologist | Nara Institute | tomoishi@nabunken.go.jp |
| 123 | István ZELNIK | | HUNINCO | izelnik@gmail.com |
| 124 | IT Peou | Deputy Director of Department | APSARA National Authority | |
| 125 | Jady Smith | Project Manager | Embassy of New Zealand | |
| 126 | Jahnwij Sharma | Director Conservation | ASI New Delhi | dircon.asi.@gmail.com |
| 127 | Jean Baptiste CHEVANCE | Program Manager | ADF | info@adfkulen.org |
| 128 | Jean Paul Berthelot | Président | SIAVB | |
| 129 | Jean-François CAUTAIN | Ambassador | European Commission | |
| 130 | Jean-Marie Furt | Ad hoc Expert for conservation | UNESCO | jmafurt@wanadoo.fr |
| 131 | Jean-Michel BORDES | Secrétaire Général | SIAVB | jm.bordes@siavb.fr |
| 132 | Joachim Freiherr von Marschall | Ambassador | Embassy of Germany | |
| 133 | John Simmons | Deputy Public Affairs Officer | US Embassy | SimmonsJA@state.gov |

| | | | | |
|---|---|---|---|---|
| 134 | Julia ESTEVE | Archaeologist | EFEO | esteve.julia@yahoo.fr |
| 135 | Kam Kmao | | APSARA Stone Conservation | |
| 136 | Katerina Blazek | Project Manager | GOPURA II | |
| 137 | KEAN Chenda | | GOPURA II | |
| 138 | KEM REATH Viseth | Advisor & Cabinet Directotr | Council of Ministers | |
| 139 | Kenichiro HIDAKA | Ad hoc Expert for conservation | UNESCO | akadih@heritage.tsukuba.ac.jp |
| 140 | KET Sophan | Permanent Delegation to UNESCO | Council of Ministers | |
| 141 | KHEAM Mony | Dept. of Conservation of Monument and Archaeology | APSARA National Authority | |
| 142 | KHEAV Sina | | Ministry of Economy | |
| 143 | KHIEU Chan | Communication Dept | APSARA National Authority | |
| 144 | KHIM Bunsong | Governor | Siem Reap Province | |
| 145 | KHOY Kim Tour | Advisor to President | APSARA National Authority | |
| 146 | KHUON Khun Neay | Deputy-Director General | APSARA National Authority | kaqc2004@yahoo.com |
| 147 | KHUT Sao | Cameraman | | |
| 148 | KIM Sameth | Cameraman | TVK | |
| 149 | KIM Samnang | Technical Support & Inter-Sector Project Dept. | I.Ge.S. | |
| 150 | Kishore Rao | Director of WHC | UNESCO HQ | k.rao@unesco.org |
| 151 | KOL Bunly | Under Sceretary of State | Ministry of the Royal Palace | bunly_royalpalace@yahoo.com |
| 152 | KONG Kanty | Staff chief | I.Ge.S. | igescamb@hotmail.com |

| | | | | |
|---|---|---|---|---|
| 153 | KONG Puthyka | Deputy Director General | National Authority for Preah Vihear | |
| 154 | KOU Vet | archaeological chief | JASA | kouvet12@yahoo.com.jp |
| 155 | Kumar Tuhin | Joint Secretary | Ministry of External Affairs | |
| 156 | Lady Street | | | |
| 157 | Léa CHAMBONCEL | Chargée de mission coopération universitaire | Ambassade de France | |
| 158 | LIM Bun Hok | ICC Secretariat | UNESCO Phnom Penh | bh.lim@unesco.org |
| 159 | Lim Kannitha | Archaeologist | EFEO | |
| 160 | LIM Ourk | Deputy Director of Department | APSARA National Authority | 012 267 707 |
| 161 | LIM Srou | Communication Dept. | EFEO | 012 239 241 |
| 162 | Lionel COURTY | Interpreter English-French | UNESCO | lionelcourty@hotmail.com |
| 163 | Liu Jie | Deputy Secretary General | HIST | |
| 164 | LIU Shuguang | Professor of Chinese Academy of Cultural Heritage-CACH | CSA | |
| 165 | LONG Kosal | Deputy Director General | National Authority for Preah Vihear | kosal_long9@yahoo.com |
| 166 | LONG Nary | Expert | APSARA Stone Conservation | longnary@hotmail.com |
| 167 | Lorella PELLEGRINO | Professor | University of Palermo | pelegelino@gmail.com |
| 168 | LOUK Sok Leng | Dept. of Tourism | APSARA National Authority | |
| 169 | Ludovica Nicolai | Professor | University of Palermo | ludovica.nicolai@libero.it |
| 170 | LUN Kanel | Director | Provincial Deparment of Environment, Siem Reap Province | 077 888 588 |
| 171 | LY Vanna | Director | Preah Norodom Sihanouk-Angkor Museum | vnsaro@gmail.com |

| | | | | |
|---|---|---|---|---|
| 172 | MAK Renita | Cameraman | TVB | |
| 173 | MAO Loâ | Department Director | APSARA National Authority | 017 888 667 |
| 174 | MAO Sokny | Dept. of Conservation of Monument and Archaeology | APSARA National Authority | 012 898 496 |
| 175 | MAO Vibol | Advisor | Council of Ministers | vibol.m9@gmail.com |
| 176 | Maric BEAUFEISTE | | EFEO | maric.beaufeist@gmail.com |
| 177 | Masahiko TOMODA | Head, Conservation Design Section | NRICP Tokyo | tomoda@tobunken.go.jp |
| 178 | MEAS KET David | Permanent Delegation to UNESCO | Council of Ministers | |
| 179 | MEN Sodany | Membre mission du partrimoine | Heritage Mission | sodanymen@gmail.com |
| 180 | Merré CARRINAL | | SIAVB | |
| 181 | MEY Kosal | Project Focal Point | UNESCO Phnom Penh | k.mey@unesco.org |
| 182 | MEY Marady | Deputy-Director General | APSARA National Authority | meyapsara@camintel.com |
| 183 | Michal Blazek | Leader of GOPURA II Project | GOPURA II | |
| 184 | Michel Zink | Secrétaire perpétuel | Académie des Inscriptions et Belles-Lettres de l'Institut de France | |
| 185 | Mitsumasa Ishizuka | Assistant to Director | JASA | mtms0709@gamil.com |
| 186 | MOAN Phanit | Water Management Dept. | APSARA National Authority | |
| 187 | MOM Saran | Office Director General | APSARA National Authority | 092 332 066 |
| 188 | Monika Kamille B. Limpo | Third Secretary and Vice Consul | Embassy of the Republic of the Philippes | |
| 189 | Monika Staziwa | Advisor | GIZ/SCU | |

| | | | | |
|---|---|---|---|---|
| 190 | MOT Lina | Department of Administration | APSARA National Authority | 012 445 088 |
| 191 | MOUNG Sowath | Advisor | Cambodian National Commission for UNESCO | |
| 192 | Mounir BOUCHENAKI | Ad hoc Expert for conservation | UNESCO | mounir.bouchenaki@gmail.com |
| 193 | Mr.H. Raghavendra | Draughtsman | ASI Siem Reap | hathikalraghavendra@gmail.com |
| 194 | Ms. Josephin Rösler | Technical Advisor to APSARA Stone Conservation Unit | GIZ/SCU | josephin.roesler@eh.giz.de |
| 195 | Nao OTSUKA | Research Adviser | Embassy of Japan | nao.otsuka@mofa.go.jp |
| 196 | Natacha Pakker | Chargée de mission Ecole de Chaillot | Ecole de Chaillot | npakker@citechaillot.fr |
| 197 | Natacha PAKKER | Architecte | École de Chaillot | npakker@citechaillot.fr |
| 198 | Nataranjan Ishwaran | Professor | HIST | |
| 199 | NEANG Soryda | Deputy Director of Department | Council of Ministers | |
| 200 | NGAN Dany | Department Director | APSARA National Authority | 012 303 030 |
| 201 | NGETH Sothy | Deputy Director of Department | APSARA National Authority | 092 627 776 |
| 202 | NGOV Seng Kak | Director | Department of Tourism, Siem Reap Province | 012 509 008 |
| 203 | NHEM Reaksmey | Water Management Dept. | APSARA National Authority | 092 847 836 |
| 204 | NIB Chanleaksmy | Dept. of Territory and Habitat management in Angkor Park | APSARA National Authority | 092 484 710 |
| 205 | Nick SELLS | Délégation | M. Bolloré | |
| 206 | Nicolas Baudouin | Premier Secrétaire | Ambassade de France | |
| 207 | NIN Chansamean | Department Director | APSARA National Authority | 012 981 556 |
| 208 | NONG Leangchhoeun | Dept. of Community and Agricultural Develp. | APSARA National Authority | |

| | | | | |
|---|---|---|---|---|
| 209 | Norinda KHEK | Directeur de la communication | Cambodia Airports | Norinda.Khek@cambodia-airports.aero |
| 210 | NOUTH Narang | Permanent Delegation to UNESCO | Council of Ministers | |
| 211 | NUON Krisna | Director | Department of Water Reservoir & Meteorology | |
| 212 | OM Chandara | Department Director | Council of Ministers | |
| 213 | OR Kim Song | Membre du Conseil d'Administration de AAA | AAA | or.kim.song@free.fr |
| 214 | OU Kongkea | Dept. of Territory and Habitat management in Angkor Park | APSARA National Authority | 010 706 850 |
| 215 | OUM Marady | | APSARA National Authority | 078 336 639 |
| 216 | Park Donghee | interpreter | Korea Cultural Heritage Foundation | |
| 217 | Pasquale Assennato | Professor | University of Palermo | pasquale.assennato@unipa.it |
| 218 | Patrick LEPINAY | Délégation | M. Bolloré | |
| 219 | Paul Zajac | Conseiller diplomatique | Cabinet du Ministre | |
| 220 | PHANG Makara | Communication Dept | APSARA National Authority | |
| 221 | PHAY Siphan | Secretary of State | Council of Ministers | siphanp@yahoo.com |
| 222 | Phaylam OUDOMKHAM | Counsellor and Deputy Cheif of Mission | Embassy of Lao P.D.R. | phaylam_59@yahoo.com |
| 223 | PHENG Sam Oeurn | Department Director | National Authority for Preah Vihear | |
| 224 | Philippe Barbat | Conseiller patrimoine | Cabinet du Ministre | |
| 225 | Philippe DELANGHE | Culture Programme Specialist | UNESCO Phnom Penh | p.delanghe@unesco.org |
| 226 | PHIN Samnang | Dep. Conservation Sites Outside Angkor Park | APSARA National Authority | 077 818 103 |
| 227 | PHOAN Phalla | Deputy Director | APSARA National Authority | |
| 228 | PHOK Chankrishna | | National Committee for World Heritage | |

| | | | | |
|---|---|---|---|---|
| 229 | PHOUY Savoeut | | UNESCO Phnom Penh | 098 572 077 |
| 230 | Pierre BÂTY | Archaeologist | INRAP | pierre.baty@inrap.fr |
| 231 | Pierre Clément | | AAA | |
| 232 | Pierre Dubreuil | Directeur général | INRAP | pierre.dubreuil@inrap.fr |
| 233 | Pierre-André LABLAUDE | Ad hoc Expert for conservation | UNESCO | lablaude.administration@orange.fr |
| 234 | Pierre-Henri DUB REUIL | President | INRAP | |
| 235 | PONN Pyus | Urban Heritage Development Dept of Siem Reap | APSARA National Authority | 088 507 0707 |
| 236 | PRAK Sonnara | | Ministry of Culture and Fine Arts | prak_sonnara@yahoo.com |
| 237 | Pratak SIKKHAMONTON | Minister Counsellor | Royal Thai Embassy | |
| 238 | Pratana DISYATAT | Counsellor | Ministry of Foreign Affairs of Thailand | |
| 239 | PRIM Vireak | Deputy Director of Department | APSARA National Authority | |
| 240 | PROM Chak | ICC Secretariat | UNESCO Phnom Penh | c.prom@unesco.org |
| 241 | PROM Karona | Deputy Director of Department | APSARA National Authority | |
| 242 | PROM Sam Ean | Deputy Director of Department | APSARA National Authority | 012 630 418 |
| 243 | PROM Sina | Forestry,Cultural Landscape & Environment Management Dept. | APSARA National Authority | |
| 244 | PUTH Soth | Dep. Conservation Sites Outside Angkor Park | APSARA National Authority | 097 774 5191 |
| 245 | REAK Smey | Chief | Tourism police | |
| 246 | RET Sophal | Cultural Development, Museum & Heritage Dept. | APSARA National Authority | 077 316 131 |
| 247 | Richard MACKAY | GML Team Leader | Heritage Management Framework | richardm@gml.com.au |

| | | | | |
|---|---|---|---|---|
| 248 | Rick VALENZUELA | Délégation | M. Bolloré | |
| 249 | Robert McCarthy | | | rmccarthy2004@yahoo.com |
| 250 | Roland FLETCHER | Director | Angkor Research Program, University of Sydne | roland.fletcher@sydney.edu.au |
| 251 | Romain Louvet | Conseiller de Coopération et d'Action culturelle | Ambassade de France | romain.louvet@diplomatie.gouv.fr |
| 252 | ROS Borath | President | National Committee for World Heritage | apsara.dma@online.com.kh |
| 253 | Ros Rotanak | | | |
| 254 | ROS Rotheany | Deputy Director of Department | APSARA National Authority | |
| 255 | SAMRETH Socheat | Cameraman | Council of Ministers | |
| 256 | SAMRETH Sopha | Interpreter English-Khmer | APSARA Authority | 016 85 17 84 |
| 257 | SAO Thy | Cameraman | SEA TV | |
| 258 | Saori Tanaka | Researcher | Sophia University | sophia_tanaka@online.com.kh |
| 259 | Sara Penoni | Professor | University of Palermo | faberestauro@libero.it |
| 260 | SARIN Borey | Dept. of Community and Agricultural Develp. | APSARA National Authority | 088 356 775 |
| 261 | SARKAR Sulata | | APSARA National Authority | |
| 262 | SARY Boramy | | APSARA National Authority | |
| 263 | SAT Nady | Commissioner of Police | Siem Reap Province | 012 900 930 |
| 264 | Satoru MIWA | Researcher | Sophia Asia Center | satoru@online.com.kh |
| 265 | SÈ Samuth | Director | Dept. of Urbanism & Land Management, Siem Reap | 097 688 7888 |
| 266 | SEN Rita | | | |
| 267 | SENG Ratana | Staff | I.Ge.S. | |

| | | | | |
|---|---|---|---|---|
| 268 | SENG Sotheara | | APSARA National Authority | 089 800 803 |
| 269 | Serge MOSTURA | Ambassadeur | Ambassade de France | dominique.mas@diplomatie.gouv.fr |
| 270 | Seu Pich | | ADF | |
| 271 | SEUNG Kong | Deputy-Director General | APSARA National Authority | 012 264 056 |
| 272 | SHENG Weiwei | First Secretary | Embassy of China | shengweiwei@vip.sina.com |
| 273 | Shin Boram | interpreter | Korea Cultural Heritage Foundation | |
| 274 | Shinji Tsukawaki | Ad hoc expert for Developmnent | UNESCO | shinji@se.kanazawa-u.ac.jp |
| 275 | SIM Leap | Photographe | Council of Ministers | |
| 276 | SIM Samnang | Reporter | Koh Santepheap News | |
| 277 | SIM Thân | Deputy Director of Department | APSARA National Authority | 012 87 33 34 |
| 278 | Simon WARRACK | Expert | ICCROM | swarrack@gmail.com |
| 279 | SISOWATH MEN Chandévy | Director | Heritage Mission | handevy@yahoo.com |
| 280 | SIV Sinet | Dept. of Territory and Habitat management in Angkor Park | APSARA National Authority | 092 135 673 |
| 281 | SIYONN Sophearith | | FOKCI | sophealriths@yahoo.com |
| 282 | SO Chheng | Archaeologist | CSA | sochheng@hotmail.com |
| 283 | SO Son | Governor | Banteay Srey District | 012 777 202 |
| 284 | SOEUR Sothy | Expert | JASA | ssoeru@yahoo.com |
| 285 | SOK An | Deputy Prime Minister | Council of Ministers | |
| 286 | SOK Leakhana | Deputy-Director General | APSARA National Authority | 012 555 557 |
| 287 | SOK Sangvar | Advisor | Council of Ministers | Sangvar.sok@gmail.com |
| 288 | SOK Sineth | Forestry, Cultural Landscape & Env. Management Dept. | Council of Ministers | |

| | | | | |
|---|---|---|---|---|
| 289 | SOK Sithan | Cameraman | TV11 | |
| 290 | SOK Sokan | Advisor | Council of Ministers | Sokan.sok@gmail.com |
| 291 | SOK Soseila | Technical Support & Inter-Sector Project Dept. | Council of Ministers | 012 578 961 |
| 292 | Soklim Tung | Attaché de presse | Ambassade de France | 012 666 302 |
| 293 | SOM Sopharath | Urban Heritage Development Dept of Siem Reap | APSARA National Authority | 012 834 118 |
| 294 | SONG Sopheakdey | Cameraman | Council of Ministers | |
| 295 | Sophie Makariou | Présidente | Musée national des Arts asiatiques Guimet | |
| 296 | SORN Chheang | Cameraman | CTN | |
| 297 | SOU Ny | Provincial Council | Siem Reap Province | 012 825 953 |
| 298 | SOU Phirin | Secretary of State | Council of Ministers | souphirin@camnet.com.kh |
| 299 | SOUN Sovann | | National Committee for World Heritage | 012 203 464 |
| 300 | SULATA Sarka | | | sulata@yahoo.com. |
| 301 | SUN Sovanny | Director | Department of Culture and Fine Arts, Siem Reap Province | 012 384 441 |
| 302 | Suvanna GAUNTLETT | | Wildlife Alliance | eth@wildlifealliance.org |
| 303 | SVAY Piseth | Deputy Director of Department | APSARA National Authority | |
| 304 | Sylvain Ulisse | Chargé de mission | Heritage Mission | sylvain.ulisse@gmail.com |
| 305 | T D Bhutia | Second Secretary | Embassy of India | polembindia@online.com.kh |
| 306 | T. S. Maxwell | Professor | University of Bonn | t.maxwell@web.de |
| 307 | Takeshi NAKAGAWA | Co-director | JASA | nakag@waseda.jp |
| 308 | TAN Boun Suy | Deputy-Director General | APSARA National Authority | tanbounsuy@yahoo.com |

| | | | | |
|---|---|---|---|---|
| 309 | TAN Sawathya | Deputy Director of Department | APSARA National Authority | 017 749 441 |
| 310 | TAN Sombon | Deputy-Director General | APSARA National Authority | 012 957 940 |
| 311 | TAN Theany | Secretary General | Cambodian National Commission for UNESCO | camnac@hotmail.com |
| 312 | TANG Makara | Department of Land Use and Habitat Management Dept.Land Managem | APSARA National Authority | 067 638 638 |
| 313 | TANG Somnang | | National Committee for World Heritage | |
| 314 | TEA Kimsoth | Director | Autorité Forestière du district | 092 225 555 |
| 315 | TEA Van | Dept. of Conservation of Monument and Archaeology | APSARA National Authority | 092 345 569 |
| 316 | TECH Touch | | APSARA Stone Conservation | |
| 317 | TEKRETH Somrach | Secretary of State | Council of Ministers | tekreth@yahoo.com |
| 318 | TEP Bun Chhay | Governor | Siem Reap District | 012 677 547 |
| 319 | TEP Tony | Deputy Director of Department | APSARA National Authority | 016 965 777 |
| 320 | TEP Vattho | Department Director | APSARA National Authority | vattho@angkorvillage.com |
| 321 | Teruo JINNAI | Advisor | Council of Ministers | teruojinnai@gmail.com |
| 322 | THAVY Saronich | Preah Norodom Shihanouk-Angkor Museum | | 010 237 724 |
| 323 | THOK Sokhom | Department Director | Ministry of Tourism | |
| 324 | Thomas JOLY | Maire de Verrières le Buisson | SIAVB | |
| 325 | THONG Khon | Minister | Ministry of Tourism | |
| 326 | TIN Tina | Deputy Director of Department | APSARA National Authority | |
| 327 | TITH Sopha | Deputy Director of Department | APSARA National Authority | 012 728 221 |
| 328 | Tom Chandller | Professor | University of Sydney | |

| | | | | |
|---|---|---|---|---|
| 329 | TUY Sina | Assistant to DPM | Council of Ministers | |
| 330 | UK Someth | Deputy-Director General | APSARA National Authority | someth_uk@yahoo.com |
| 331 | UK Topbotra | Director General | National Authority for Preah Vihear | topbotra@gmail.com |
| 332 | UNG Ratha | | National Committee for World Heritage | |
| 333 | Urasee THIRATANG SATHIRA JEONG | Fist Secretary | Ministry of Foreign Affairs of Thailand | |
| 334 | Valter M. SANTORO | Head of Project | I.Ge.S. | vm.santoro@igessnc.com |
| 335 | VANN Bunna | Director | Department of Cult, Siem Reap Province | 016 902 593 |
| 336 | Véronique Dez | Responsable du pôle diffusion et valorisation-département des affaires européennes et internationales | Ministère de la Culture | veronique.dez@culture.gouv.fr |
| 337 | Vincent Berjot | Directeur général des Patrimoines | Ministère de la Culture | |
| 338 | Vincent BOLLORÉ | Délégation | M. Bolloré | |
| 339 | Vincent CALZARONI | Délégation | M. Bolloré | |
| 340 | Vittorio Gallinaro | Field Director | I.Ge.S. | vittoriogallinaro@hotmail.com |
| 341 | Wang Cheng | professor | HIST | |
| 342 | YIN Soeum | Interpreter English-Khmer | APSARA Authority | 012 89 13 01 |
| 343 | YIN Sovath | Deputy Director of Department | APSARA National Authority | |
| 344 | YIT Chandaroat | Department Director | APSARA National Authority | Chandaroat.yit@gmail.com |
| 345 | YOS Eang | Deputy Secretary General | Cambodian National Commission for UNESCO | |
| 346 | Yoshiaki ISHIZAWA | Director | Sophia University | yoshia-i@sophia.ac.jp |
| 347 | Yoshihiro HIGUCHI | Minister & Consul General | Embassy of Japan | yoshihiro.higuchi@mofa.go.jp |

| | | | | |
|---|---|---|---|---|
| 348 | Yuji ARAKI | Associate Professor | ERDAC | arakiy@mail.saitama-u.ac.jp |
| 349 | Yuji KUMAMARU | Ambassador | Embassy of Japan | |
| 350 | YUN Savoeun | Cameraman | TV3 | |
| 351 | Yuni SATO | Archaeologist | Nara Institute | yuni@nabunken.go.jp |
| 352 | Zsuzsanna RENNER | | HUNINCO | renner.zsuzsanna@gmail.com |